ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-May-2012, 14:33
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៥៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក អេនឌ្រូ ចេមស៍ ម៉ាគិនថាយអ៊ឺរ
*(Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ ដារារស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr.Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោក សំ សុគង់

លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាង ឧត្ដម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក សាឡុត បាន (TCW-586) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សាឡូត បាន** (TCW-586)

សួរបន្តដោយ លោក ម៉ៃខល កាណាវាស ផ្តើមពី៖ ....... ទំព័រ ០១
សួរដោយលោក សុន អរុណ ផ្តើមពី៖ ....... ទំព័រ ៤៩
សួរដោយលោក ម៉ៃខល ផេសមិន ផ្តើមពី៖ ....... ទំព័រ ៦០
សួរដោយលោក លោក គង់ សំអុន ផ្តើមពី៖ ....... ទំព័រ ៨១

# កិច្ចដំណើរការនីតិវិធី

[០៩:០១:៣៣]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

អរុណសួស្តីលោក សាឡុត បាន! ហើយនៅថ្ងៃនេះអង្គសវនាការនឹងបន្តស្តាប់សក្ខីកម្មរបស់លោក ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តីទាំងបីក្រុម។ ហើយនៅពេលដំបូងនៃព្រឹកនេះគឺនឹងបន្តការសួរដេញដោលលោកដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ដែលបានតាំងសំណួរលោកកាលពីចុងសប្តាហ៍មុនហើយនៅមិនទាន់ចប់ ហើយអង្គជំនុំជម្រះសូមឲ្យលោកខិតខំផ្តង់អារម្មណ៍ដើម្បីឆ្លើយតបទៅនឹងការតាំងសំណួរផ្សេងៗ ដើម្បីឲ្យបានឆាប់រហ័សតាមពេលវេលា។ ប្រសិនបើអាចលឿន គឺអាចចប់នៅរសៀលនេះ-- អ៎! នៅថ្ងៃនេះ។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:០៣:០១]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម។ អរុណសួស្តីលោកសាក្សី អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី ខ្ញុំចង់បន្តចំណុចដែលយើងទុកចោលកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន។ ប្រហែលជាយើងខ្ញុំអាច យើងអាចចាប់ផ្តើមមើលអ្វីដែលលោកជម្រាបយើងទាំងអស់គ្នាកាលពីអាទិត្យមុន។ អ្វីដែលខ្ញុំសួរលោកនោះគឺពាក់ព័ន្ធទៅនឹងសមត្ថភាព-- លទ្ធភាពរបស់ឪពុកមារបស់លោក ក្នុងការធ្វើសេចក្តីសម្រេច។ តើលោកមានចាំថា ធ្លាប់បានពិភាក្សាជជែកជាមួយឪពុកមារបស់លោកអំពីការដែលគាត់ចេញសេចក្តីសម្រេចដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំអត់បានទេ។

[០៩:០៤:០២]

**ស៖** សូមអរគុណ។ យើងជម្រាបយើងខ្ញុំនៅពេលនោះថា ខ្ញុំយោងទំព័រ៩៥ នៃប្រតិចារឹកឲ្យអស់លោក លោកស្រីផ្សេងទៀតអាចតាមដានបាន បារាំង និងខ្មែរ គឺថ្ងៃលេខ 16.02.551 មួយទៀតគឺ 1605.17។ ដូច្នេះហើយ ខ្ញុំគិតថាយើងមានឯកសារជាក្រដាសឲ្យលោកសាក្សីអាចតាម-- អាចមើលបាន។

**លោក ម៉ៃខល កាណាវាស៖**

ដូច្នេះ ខ្ញុំស្នើសុំឲ្យអង្គជម្រះ-- អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីតុលាការបញ្ជូនឯកសារនេះទៅកាន់លោកសាក្សីដើម្បីពិនិត្យមើល។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:០៥:២៣]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅផ្នែកខាងលើដែលខ្ញុំលើកឡើងអម្បាញ់មិញ យើងឃើញមានសំណួរដែលបានសួរ។ ខ្ញុំបានយោងលើឯកសារមួយ-- ខ្ញុំបានបង្ហាញឯកសារមួយ យោងលើឯកសារមួយបង្ហាញជូនលោក ដែលក្នុងនោះលោកបានសន្និដ្ឋានថា "លោក ប៉ុល ពត មិនបានធ្វើសេចក្ដី-- មិនអាចធ្វើសេចក្ដីសម្រេចតែម្នាក់ឯងបានទេ"។ លោកបាននិយាយថា "នៅពេលដែលគេប្រាប់ខ្ញុំនៅពេលនោះ គឺខ្ញុំមិនអាចទាញសន្និដ្ឋានថា ឪពុកមារបស់ខ្ញុំ អាចធ្វើសេចក្ដីសម្រេចតែម្នាក់ឯងបាននោះទេ។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំឃើញស្ថានភាពក្រោយមក ដែលផ្ទុយ ប្រឆាំងទៅនឹង ប៉ុល ពត បានខ្ញុំឃើញថា នេះហើយដែលអ្វី ប៉ុល ពត ធ្វើជាលេខាមែន ដែលការគោរពពីដើមត្រូវតែបែរ-- ឥឡូវប្រែជាឈប់គោរពវិញ"។ ដូច្នេះបានន័យថា គាត់មិនអាចសេចក្ដីសម្រេចដោយខ្លួនឯងនោះទេ។

[០៩:០៦:២៨]

ចំណុចមួយទៀត សមូហភាពវាធំជាងបុគ្គល។ បុគ្គលភាគតិចត្រូវតែ គោរពបុគ្គលភាគច្រើន ហើយបន្ទាប់មកខ្ញុំបានសួរលោក។ ខ្ញុំបានសួរលោក នៅពេលដែលលោកនិយាយថា "ប៉ុល ពត ប្រឆាំង-- តាម៉ុក ប្រឆាំងជាមួយនឹង ប៉ុល ពត ជាពូរបស់លោក"។ ខ្ញុំបានយោងទៅលើឆ្នាំ៦៧-- ៩៦, ៩៧

"ចម្លើយ៖ បាទ ខ្ញុំយោងទៅឆ្នាំ៩៦, ៩៧។ សំណួរ៖ គឺក្រោយពេលដែល សុន សេន និងក្រុមគ្រួសារគាត់ទាំងមូលត្រូវបានគេសម្លាប់ចោល ប្រហែលជាគេសន្និដ្ឋានថា ដោយឪពុកមារបស់លោក។ តើត្រឹមត្រូវដែរឬទេ? ចម្លើយ៖ គឺថា បាទជាការត្រឹមត្រូវ"។

[០៩:០៧:៣៥]

អ្វីដែលខ្ញុំចង់ផ្តោតត្រង់ចម្លើយទាំងអស់នេះនោះគឺ ខ្ញុំចង់និយាយបន្ថែមបន្តិចបន្តួចទៀត។ ថាតើលោកដឹងអ្វីខ្លះនៅពេលនោះ?

ក៏ប៉ុន្តែជាបឋមនោះ តើយើងអាចសន្និដ្ឋានពីចម្លើយរបស់លោកបានដែរឬទេថា នៅពេលដែលលោកនិយាយឆ្លើយប្រាប់អ្នកស៊ើបអង្កេត លោកបានដឹងអំពីឆ្នាំ៩៦, ៩៧ ដែលនៅពេលនោះលោកបានជម្រាបអ្នកស៊ើបអង្កេតថា ប៉ុល ពត ខ្លួនឯងមិនអាចជាអ្នកចេញសេចក្តីសម្រេចដោយខ្លួនឯងតែម្នាក់នោះទេ។ តើមែនដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំបាននិយាយយ៉ាងដូច្នេះ នៅពេលដែលខ្ញុំសមាហរណកម្មហើយ បាទ។

**លោក ម៉ៃខល កាណាវ៉ាស៖**

លោកប្រធានខ្ញុំអនុញ្ញាតបើកមីក្រូហ្វូនជាប់តែម្តង ដើម្បីឲ្យខ្ញុំអាចងាយស្រួលរៀបចំសួរសំណួរ ហើយគឺអាចឲ្យខាងអ្នក*អាយធី* នោះ ជម្រាបខាង*អាយធី* នោះឲ្យខ្ញុំជាអ្នកចាត់ចែងលើមីក្រូហ្វូនខ្លួនខ្ញុំផ្ទាល់ទៅ មិនចាំបាច់ឲ្យគេចាំជួយបិទបើកនោះទេ។

[០៩:០៩:០៤]

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** លោកមិនលើកឡើងតាមចម្លើយនោះថា អំឡុងពេលដែលលោកដឹង និងនៅជាមួយឪពុកមារបស់លោកនៅក្រុងព្រៃវហូតមកដល់ទីក្រុងភ្នំពេញនោះ គឺថា លោកដឹងថា លោក ប៉ុល ពត មិនអាចចេញសេចក្តីសម្រេចតែម្នាក់ឯងនោះទេ។ អ៊ីចឹងមែនដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំនិយាយយ៉ាងដូច្នេះ ដោយលើកគោលការណ៍ដូចលោកបានមាន-- ដូចចម្លើយរបស់លោកសួរអ៊ីចឹង គឺថាប្រជាធិបតេយ្យប្រមូលផ្តុំ ភាគតិចគោរពភាគច្រើន បាទ។

[០៩:១០:០៤]

**ស៖** ចំណុចហ្នឹងហើយដែលខ្ញុំចង់លើកឡើង។ តើលោកអាចជម្រាបយើង ពន្យល់ជម្រាបយើងខ្ញុំបានដែរឬទេ តើញឹកញយប៉ុនណា? លោកអាចជាលើកជាឧទាហរណ៍ តើលោកឃើញដោយផ្ទាល់ភ្នែកញឹកញយប៉ុនណាដែរ ដែលនៅក្នុងពេលប្រជុំនោះ គឺគេធ្វើសេចក្ដីសម្រេចដោយផ្អែកទៅលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ? តើលោកអាចផ្ដល់ជាឧទាហរណ៍មួយដែរឬទេ នៅពេលណាដែលលោកបានឃើញដោយជាក់ស្ដែងនោះ?

**ឆ៖** ប្រជុំរបស់មជ្ឈិម ខ្ញុំមិនដែលបានចូលទេ។ ឯការរៀនសូត្ររបស់ខ្ញុំ គឺបានយល់ពីបញ្ហានេះ។

**ស៖** ការរៀនសូត្ររបស់លោកនោះ គឺគេបានបង្រៀនអំពីគោលការណ៍នេះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ការរៀនសូត្រ។ ខ្ញុំយល់បញ្ហានេះ។

[០៩:១១:២៥]

**ស៖** តើលោកអាចចង្អុលបញ្ជាក់ដែរឬទេនៅក្នុងថ្ងៃនេះ? ដែលឲ្យយើងទាំងអស់គ្នាជឿថា នៅក្នុងអំឡុងពេលនោះ នៅពេលដែលឪពុកមាររបស់លោកជាអ្នកនៅលើគេបំផុត នោះគឺគាត់គោរពទៅតាមគោលការណ៍ដែលលោកបានរៀនសូត្រនេះ? តើលោកអាចចង្អុលបញ្ជាក់ឲ្យបានជាក់លាក់ទេ?

**ឆ៖** ខ្ញុំបានជម្រាបរួចហើយ។ ឥឡូវខ្ញុំជម្រាបមួយទៀត គឺថាការរៀនសូត្ររបស់ខ្ញុំគឺមានតែមេរបស់ខ្ញុំមួយថ្នាក់ គឺមានលោក ប៉ង់ នេះមួយ មានបង អៀង សារី នេះមួយតែប៉ុណ្ណោះ។

**ស៖** ខ្ញុំយល់អំពីវគ្គរៀនសូត្ររបស់លោក។ ខ្ញុំយល់អំពីគោលការណ៍ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់សួរលោកនោះ គឺថាតើលោកអាចផ្ទៀងផ្ទាត់ថា គោលការណ៍ដូចដែលលោកបានរៀបរាប់ឡើងនោះ គឺអនុវត្តយ៉ាងខ្ជាប់ខ្ជួនដោយ ប៉ុល ពត ដែលគាត់ជាអ្នកនៅលើគេបំផុតនោះ?

**ឆ៖** ខ្ញុំមិនដឹង ប៉ុល ពត អនុវត្តខ្ជាប់ខ្ជួនបានប៉ុនណាៗទេ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំអនុវត្តខ្ជាប់ខ្ជួន។

[០៩:១៣:១៥]

**ស៖** ខ្ញុំយល់ ក៏ប៉ុន្តែលោកឯកភាពជាមួយយើងខ្ញុំដែរឬទេថា លោកមិនមានឋានៈមួយដែលវាអាចប្រៀបធៀបស្មើជាមួយនឹង ប៉ុល ពត នោះទេ។ អ្វីដែល ប៉ុល ពត ធ្វើការងាររបស់គាត់ គឺសម្ងាត់ ហើយលោកក៏មិនដឹងការងារដែល ប៉ុល ពត ធ្វើនោះដែរ។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** ប៉ុននេះ លោកពិចារណាទៅចុះ! បង្ខំឲ្យខ្ញុំឯកភាពទៅលោក ខ្ញុំមិនឯកភាពទេ ពីព្រោះខ្ញុំមិនចង់ដឹង។ ខ្ញុំមិនយល់សំណួររបស់លោកចង់ផ្ទឹះផ្ទៀលខ្ញុំសួរយ៉ាងម៉េច ខ្ញុំអត់ឯកភាពទេ។

**ស៖** លោកបានប្រាប់យើងខ្ញុំពីរដងថា មនុស្សម្នាក់ៗត្រូវដឹងតែរឿងខ្លួនឯងបានហើយ។ តើលោកចាំថា លោកនិយាយចំណុចហ្នឹងដែរឬទេ? ហើយលោកនៅតែរក្សាពាក្យសម្ដីនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំរក្សាពាក្យសម្ដីនេះ។

**ស៖** ប្រសិនបើយើងនិយាយម្យ៉ាងវិញទៀត តើយើងអាចនិយាយបានដែរឬទេថា វិធីធ្វើការងារ វិធីដំណើរការងារនៅពេលនោះ គឺមានតម្លាភាព ហើយតាមពិតទៅគឺជាការហាមឃាត់នោះវិញទេ តើមែនដែរឬទេ?

[០៩:១៥:០៧]

**ឆ៖** វិធីធ្វើការងារនៅពេលនោះចំពោះខ្ញុំ មានតម្លាភាព គ្មាននរណាហាមឃាត់ខ្ញុំទេ។ ឧទាហរណ៍ កុំច្រឡំ គឺក្របខ័ណ្ឌដែលខ្ញុំធ្វើការងារ ខ្ញុំត្រូវប្រឹងប្រែងធ្វើការងារនោះឲ្យអស់ពីចិត្ត ពីថ្លើម ឲ្យល្អ ប៉ុន្តែនរណាទៀតដែលមកពីក្រៅពន្ទល់ខ្ញុំ ខ្ញុំអត់ស្ដាប់ទេ។

**ស៖** ចុះការងារ ប៉ុល ពត វិញ និងការងាររបស់អ្នកផ្សេងវិញ តើការងារទាំងអស់នោះមានតម្លាភាពដែរឬទេ? តើអ្នកទាំងអស់នោះ ធ្វើយ៉ាងណាឲ្យបុគ្គលកម្មាភិបាលផ្សេង រួមទាំងលោកជាក្មួយផងដែរនោះ បានឲ្យដឹងទាំងអស់គ្នាថា តើនរណាធ្វើការអ្វីខ្លះ? ហើយមានហេតុផលអ្វីបានជាធ្វើការទាំងអស់នោះ? តើអីចឹងដែរឬទេ?

**ឆ៖** សំណួរនេះ ខ្ញុំពិបាកឆ្លើយ ប៉ុន្តែខ្ញុំប្រឹងឆ្លើយ ឆ្លើយជាសភាពការណ៍។ បើរៀនសូត្រជារួម ឧទាហរណ៍មាន ប៉ង់ មករៀនសូត្រជារួម។ រួមនេះក្នុង-- យកខ្ញុំទៅខ្លះ អីទៅក្រសួងអីផ្សេងៗខ្លះទៅកន្លែងមន្ទីរអីផ្សេងមករៀនសូត្រ មិនមែនជាធំដុំទេ។ រៀនសូត្រមានឯកសាររបស់ពីមជ្ឈិមមកឲ្យរៀន។

[០៩:១៧:០៥]

ឧទាហរណ៍ ដូចជារៀន សាមគ្គីជនជាតិក្រោមទង់បដិវត្ត រៀនសីលធម៌១២ប្រការ។ ខ្ញុំមានតម្លាភាពខ្លួនខ្ញុំតាមឯកសារ ខ្ញុំអនុវត្តត្រឹមត្រូវតាមឯកសារ ឯអ្នកដទៃទៀត ខ្ញុំមិនដឹងគេធ្វើតាម ឬមួយគេក្បត់ឯកសារ ខ្ញុំអត់ដឹងទេ។ អាហ្នឹងហើយ គេហៅថា បុគ្គលទទួលខុសត្រូវដោយឡែកគេក្ដាប់បានប៉ុន្មាន ឬមួយគេក្ដាប់មិនបាន គេយកទៅច្នៃអីទៀត គេយកទៅច្នៃមកសម្លាប់ខ្ញុំក៏បាន។ ឯខ្ញុំៗត្រឹមត្រូវតាមឯកសារ។ សូមជ្រាប បាទ។

**ស៖** ឯកសារទាំងពីរដែលលោកនិយាយអម្បាញ់មិញនេះ គឺឯកសារដែលបានផ្ដល់ជូនលោកមុនពេលបែកភ្នំពេញ គឺគេផ្ដល់ឲ្យលោក នៅពេលដែលលោកចេញទៅព្រៃ ឬរស់នៅជាមួយនឹង ប៉ុល ពត

តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ឯកសារសាមគ្គីជនជាតិក្រោមទង់បដិវត្ត គឺចាប់ផ្ដើមរៀនមុនដំបូងគេបង្អស់។ ឯកសារសីលធម៌១២ប្រការ រៀនប្រចាំថ្ងៃ។

[០៩:១៩:០៤]

**ស៖** ប្រសិនបើលោកមិនបានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ឬក៏មិនបានចូលរួមប្រជុំរបស់គណៈមជ្ឈិមនោះទេ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ថាតើលោកដឹងថាអ្នកណាខ្លះជាអង្គការ ហើយសមាជិករបស់អង្គការនោះ គឺមានអ្នកណាខ្លះ? តើលោកអាចជម្រាបបានដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចជម្រាបបានទេ។ ខ្ញុំអត់ដឹងច្បាស់ ខ្ញុំជម្រាបមិនបានទេ។

**ស៖** កាលពីថ្ងៃព្រហស្បត្តិ៍សប្ដាហ៍មុន លោកបាននិយាយថា ពូរបស់លោក គឺជាការសមាជិករបស់អង្គការ។ នៅក្នុងថ្ងៃនេះ តើលោកដឹងច្បាស់ដែរឬទេ ហើយចម្លើយដែលលោកឆ្លើយនោះ គឺលោកឆ្លើយច្បាស់លាស់ដែរឬទេ?

**ឆ៖** ពាក្យថា“អង្គការ” តាមខ្ញុំយល់ការរៀនសូត្រពេលនោះ អង្គការមិនមែនត្រឹមតែថ្នាក់មជ្ឈិមទេ។ អង្គការ គឺនិយាយតាំងពីប្រជាជនទូទៅ ដែលគេរួមមតិមកពីក្រោម រហូតមកសរុបមកជាប្រជាធិបតេយ្យសរុបមកជារួម ហើយមជ្ឈិមយកមកពិនិត្យសម្រេចជាអង្គការ នេះ។ ដូច្នេះ ខ្ញុំមិនយល់ថាអង្គការជានរណាទេ។

[០៩:២១:១៣]

**ស៖** អង្គការគឺស្ថិតនៅក្នុងក្រុម តើអ៊ីចឹងមែនដែរឬទេ? ឬក៏ជាគំនិតមួយដែលវាផុសចេញមកពីណាពីណីតែប៉ុណ្ណោះ?

**ឆ៖** អង្គការ គឺការចងក្រងពីគំនិតប្រជាជនទូទៅ គ្រប់ស្រទាប់វណ្ណៈ។

**ស៖** ដូច្នេះ មានន័យថា នៅពេលដែលលោកផ្ដល់ជាយោបល់ទៅដល់ពូ ប៉ុល ពត ដូច្នេះ អ្វីដែលលោកផ្ដល់ទៅជាយោបល់នោះ វាក្លាយទៅជាចំណុចសំខាន់ដែរនៅក្នុងអង្គការ ក្លាយជាការងាររបស់អង្គការដែរ មែនដែរឬទេ? នេះជាចម្លើយរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនបានផ្ដល់គំនិតផ្ដល់មាត់ទៅលោកទេ ប៉ុន្តែខ្ញុំក៏មានមតិនៅក្នុងក្របខ័ណ្ឌជាអង្គការមួយតូចដែរ ដូចជា ក្រុម។ ក្រុមនោះ គេរាយការណ៍ទៅតៗទៅ តៗទៅៗដល់បង អៀង សារី អ៊ីចឹងទៅបង អៀង សារី រាយការណ៍ទៅលើទៀតទៅ។ អ្ហ គេថា យោបល់ខ្ញុំវាអ៊ីចេះ យោបល់ខ្ញុំវាអ៊ីចុះអ៊ីៗអ៊ីចឹង

ទៅ ស្រេចតែលោកទេ ខ្ញុំមិនដឹងលោកទៅវាយការណ៍ខាងលើម៉េចទៀតទេ។ នេះហើយ ហៅថា លោកយល់ថា អាចផ្តល់ ឬមិនផ្តល់ស្រេចតែលោកគិតចុះ។

[០៩:២២:៥៨]

**ស៖** អរគុណ។ តាមចម្លើយរបស់លោក តើលោកជាម្ជុលមួយនៅក្នុងសមុទ្រដែរឬទេ តាមអ្វីដែលលោកប្រាប់យើងកាលពីថ្ងៃព្រហស្បតិ៍ នៅពេលដែលលោករៀបរាប់ថា ប៉ុល ពត គឺជាម្ជុលមួយនៅក្នុងសមុទ្រ បានន័យថា គឺជាសមាជិកមួយរូបរបស់អង្គការដែរ។ នេះជាអ្វីដែលលោករៀបរាប់ប្រាប់យើងអ៊ីចឹងមែនដែរឬទេនៅនេះ?

**ឆ៖** សំណួរលោកៗ ជាសំណួរខាងទស្សនវិជ្ជាហើយ។ ចង់ដឹងអំពីទស្សនវិជ្ជារបស់ ប៉ុល ពត យ៉ាងម៉េចហើយ នេះខ្ញុំដឹងអ៊ីចឹង។ យល់ព្រម ថា ប៉ុល ពត ជាម្ជុលមួយនៅក្នុងសមុទ្រ ខ្ញុំក៏ជាម្ជុលមួយនៅក្នុងសមុទ្រដែរ។

**ស៖** អរគុណ។ នៅពេលដែលលោកនិយាយថា ម្ជុលមួយនៅក្នុងសមុទ្រ។ ចំពោះយើងខ្ញុំទាំងអស់គ្នានោះ មិនយល់ទេថា តើលោកមានន័យយ៉ាងម៉េច ម្ជុលមួយនៅក្នុងសមុទ្រនោះ? តើលោកចង់មានន័យយ៉ាងម៉េច? យើងខ្ញុំដែលមកពីប្រទេសដែលមានប្រព័ន្ធវប្បធម៌មួយប្លែកពីប្រទេសនេះ តើលោកចង់មានន័យយ៉ាងម៉េច ម្ជុលមួយនៅក្នុងសមុទ្រ?

[០៩:២៤:២៨]

**ឆ៖** បើលោកសួរពីម្ជុលមួយនៅក្នុងសមុទ្រ ខ្ញុំក៏សួរលោកវិញដែរ។ តើលោកស្គាល់ទេ រូបសំណាកនេះៗ? ខ្ញុំស្គាល់រូបសំណាកទង់ជាតិកម្ពុជា ខ្ញុំស្គាល់រូបសំណាកអង្គការសហប្រជាជាតិ តែរូបសំណាកមួយនេះ ខ្ញុំអត់ទាន់ស្គាល់ច្បាស់ទេ មិនដឹងជារូបសំណាកមានន័យយ៉ាងម៉េច។ សូមលោកប្រធានអភ័យទោសបាទ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកមិនគប្បីមានតាំងសំណួរបកមកភាគីទាំងឡាយដែលតាំងសំណួរចំពោះលោកទេ ពីព្រោះនៅក្នុងនេះគឺលោកមានករណីកិច្ចឆ្លើយតបទៅនឹងសំណួរ ប៉ុន្តែនៅក្នុងសិទ្ធិយើងអត់ដែលប្រាប់សិទ្ធិថាលោកមានសិទ្ធិក្នុងការតាំងសំណួរបកទៅអង្គជំនុំជម្រះ ឬក៏បកទៅភាគីទេ។ សិទ្ធិនេះគឺយើងមិនបានប្រាប់ទេ បានន័យថាសិទ្ធិក្នុងនាមជាសាក្សីមិនមានទេ។ ហើយចំណែកឯសំណួរដែលសួរគឺលោកអាចឆ្លើយបាន ឬក៏ឆ្លើយមិនបាន នោះជារឿងជាក់លាក់នៃបញ្ហា ទម្ងន់ ឬក៏ភាពស្មុគស្មាញនៃ

បញ្ហា អាចឆ្លើយបាន ឬក៏ឆ្លើយមិនបាន នោះជាកិច្ចការរបស់មនុស្ស។ ធម្មតាមនុស្សធ្វើអ្វីវាមានកម្រិតមានសមត្ថភាពនៃការយល់ដឹងរបស់ខ្លួន។

[០៩:២៦:០៦]

អ៊ីចឹងសូម្បី-- សូមលោករៀបចំនូវការដំណើរការឲ្យបានឆាប់រហ័ស គឺឆ្លើយតបទៅនឹងសំណួរ ប្រសិនបើលោកអាចឆ្លើយបាន ហើយក្នុងករណីដែលមិនអាចឆ្លើយបានហួសពីសមត្ថភាពក្នុងការដែលលោកពន្យល់ អានោះជារឿងមួយផ្សេងទៀត។ ប៉ុន្តែអ្វីៗទាំងអស់គឺ គប្បីប្រឹងប្រែងឆ្លើយតបទៅនឹងសំណួរ។ ចៀសវាងតាំងសំណួរដែលខុសនឹងគោលការណ៍នីតិវិធីចំពោះមុខតុលាការបាទ។

**លោក សាឡុត បាន៖**

**ឆ៖** ដូច្នេះ ខ្ញុំឆ្លើយអត់បានទេ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ដើម្បីឲ្យយើងភ្លឺទាំងអស់គ្នា មុនឆ្នាំ៧៩ ឬក៏ក្រោយឆ្នាំ៧៩ តើលោកធ្លាប់ពិភាក្សាជជែកលេងជាមួយនឹងពូរបស់លោក ប៉ុល ពត ដែរឬទេ? ដែលនៅពេលជជែកលេងនោះ ប៉ុល ពត ជាពូរបស់លោកនោះប្រាប់លោកថា តើអង្គការជាអ្វី? ហើយសមាជិកអង្គការមាននរណាខ្លះ? តើមានដែរឬទេ? មានធ្លាប់ជជែកលេងដែរឬទេ?

[០៩:២៧:២៤]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំបាទអត់មានជជែកលេងទាល់តែសោះ។

**ស៖** តើធ្លាប់និយាយជាមួយនឹង ប៉ុល ពត តើអង្គការនោះដំណើរការងាររបស់គេនោះ ដោយរបៀបណាដែរឬទេ?

**ឆ៖** ខ្ញុំបានជម្រាបហើយ ពាក្យថា “អង្គការៗ” នេះខ្ញុំយល់តាមឯកសារ ដែលឲ្យមករៀនតែប៉ុណ្ណោះបាទ។

**ស៖** ក្រៅពីនេះ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ថាប្រសិនបើលោកដឹងអាចជម្រាបបានដែរឬទេថា តើសមាជិកអង្គការជាក់ស្តែងនោះមាននរណាខ្លះ? ខ្ញុំមិនឲ្យលោកធ្វើការស្មានទេ បើសិនជាលោកដឹង លោកជួយជម្រាបផង តើសមាជិកពិតប្រាកដរបស់អង្គការមាននរណាខ្លះ? សូមលោកកុំស្មាន។

[០៩:២៨:៣៨]

**ឆ៖** ពិតប្រាកដរបស់អង្គការ ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណច្រើន។ ចុះពាក្យថា "មជ្ឈិម" តើមាននិយមន័យនិយាយអំពីមជ្ឈិមហ្នឹងដែរឬទេ? មជ្ឈិមហ្នឹងជាអ្វីដែរ?

**ឆ៖** ពាក្យ "មជ្ឈិម" គឺបុគ្គលខ្ពង់ខ្ពស់ជាច្រើននាក់ ដែលធ្វើការពីលើគេ ពីលើអង្គការតូចៗទាំងអស់។

**ស៖** តើលោកធ្លាប់ចូលរួមនៅក្នុងកិច្ចប្រជុំណាមួយ ខ្ញុំដកស្រង់ពាក្យសម្ដីនេះថា "ជាមជ្ឈិម" តើលោកមានធ្លាប់ចូលប្រជុំទេជាមួយនឹងមជ្ឈិម?

[០៩:៣០:០២]

**ឆ៖** ខ្ញុំអត់ធ្លាប់បានចូលរួមជាមួយនឹងមជ្ឈិមទេ ខ្ញុំនិយាយជាច្រើនដងហើយបាទ។

**ស៖** តើលោកដឹងថា គណៈមជ្ឈិមបក្ស ដំណើរការរបស់ខ្លួនទៅដោយរបៀបណាដែរទេ?

**ឆ៖** ខ្ញុំបាទអត់យល់ទេ។

**ស៖** ថាតើមានឋានានុក្រមនៅក្នុងបក្សដែរឬទេ ដែលអាចឱ្យលោកកំណត់បុគ្គលជាក់លាក់ណាមួយដែលនៅលើកំពូលគេបំផុត ហើយបន្ទាប់មកក្រោមៗមកទៀតដែលមានការទទួលខុសត្រូវនិងមុខងារផ្សេងៗគ្នានោះ តើលោកដឹងដែរឬទេ?

**ឆ៖** រឿងនេះខ្ញុំអត់ដែលបានឃើញលក្ខន្តិកៈបក្សគេទេ តាំងពីរៀនមក តាំងពីឱ្យរៀនសូត្រមក ខ្ញុំអត់ដែលបានឃើញលក្ខន្តិកៈបក្សទេ។

**ស៖** ចុះពាក្យថា "ថ្នាក់លើ" តើមានឯកសារណាមួយដែលកំណត់និយមន័យ ដែលនិយាយអំពីសមាជិកថ្នាក់លើនោះ តើមានឯកសារណាមួយដែលបង្ហាញយ៉ាងដូច្នេះទេ?

**ឆ៖** បាទ អត់មានឃើញទេ។

**ស៖** ថាតើមានឯកសារណាមួយ ឬវគ្គបណ្ដុះបណ្ដាលណាមួយ ដែលបង្ហាញអំពីថា តើថ្នាក់លើ នោះដំណើរការទៅរបៀបណា ហើយថ្នាក់លើនោះមានការទទួលខុសត្រូវដោយរបៀបណាដែរឬទេ?

**ឆ៖** បាទ អត់មានឃើញទេបាទ។

[០៩:៣២:២០]

**ស៖** តើយើងអាចសន្និដ្ឋាន-- ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ លោកមិនដែលបានឃើញឯកសារ លោកមិនដែលបានចូលវគ្គបណ្តុះបណ្តាលបែបនេះ តើពូ ប៉ុល ពត ឬក៏អ្នកណាម្នាក់បានពិភាក្សាជាចំណុចនេះនៅថ្នាក់មជ្ឈិម ឬនៅថ្នាក់លើនៅពេលណាមួយនៅមុន ឬក៏នៅក្រោយឆ្នាំ១៩៧៩ដែលឬទេ?

**ឆ៖** បានឃើញតែការឧទ្ទេសនាម។ បើមន្ទីរមជ្ឈិមប្រើនរណាមក គឺទទួលស្គាល់ទៅ ពេលនោះគឺប្រើ ប៉ង់ ក្រសួងមានបង អៀង សារី។ ខ្ញុំទាក់ទងតែពីរនាក់នេះទេ ដែលជា ខ្ញុំគិតថា ថ្នាក់លើៗខ្ញុំ។

[០៩:៣៣:៤៩]

**ស៖** ឥឡូវខ្ញុំសូមនិយាយសង្ខេបអំពី ប៉ង់ ចុះ។ ប៉ង់ មកពីខាងក្រៅ មិនអ៊ីចឹងអី?

**ស៖** ខ្ញុំឃើញលោកគ្រវីក្បាលហើយ ខ្ញុំអត់បានទទួលចម្លើយ។ នៅពេល ប៉ង់ មកក្រសួងការបរទេស គាត់ជាមនុស្សមកពីខាងក្រៅ តើអ៊ីចឹងមែនទេ?

**ឆ៖** ប៉ង់ ជាមនុស្សមកពីខាងក្រៅ ប៉ុន្តែមកពីមន្ទីរមជ្ឈិម។

**ស៖** ថាតើថ្នាក់កណ្តាលខុសពីថ្នាក់មជ្ឈិម ឬក៏យ៉ាងម៉េចបើនិយាយអំពីទស្សនទាន និយាយអំពីន័យរបស់វា តើខុសគ្នាយ៉ាងម៉េច?

[០៩:៣៥:០០]

**ឆ៖** ឧទាហរណ៍ចុះ ថាខ្ញុំជាថ្នាក់កណ្តាលចុះ។ ខ្ញុំថ្នាក់នេះ ឃើញ ប៉ង់ មកគឺត្រូវគោរព ប៉ង់។

**ស៖** ខ្ញុំសូមសួរសំណួរនេះឡើងវិញ។ ថាតើមជ្ឈិមខុសពីមន្ទីរមជ្ឈិមឬក៏យ៉ាងម៉េច? លោកសូមៗលោកឆ្លើយទៅ បើលោកដឹងលោកឆ្លើយថាដឹង បើលោកមិនដឹងលោកឆ្លើយថាមិនដឹង។

**ឆ៖** មន្ទីរ ខុសពីមជ្ឈិម។

**ប្រធានអង្គជំនុំ៖**

ឆ្លើយៗទៀត លោកអត់បានទាន់នេះ អំមិញអត់ទាន់មានភ្លើង។

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខុសគ្នា។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ឆ៖** តើលោកគិតថា ប៉ង់ ជាថ្នាក់លើដែរឬទេ?

**ឆ៖** បាទ ប៉ង់ ជាថ្នាក់លើ។

[០៩:៣៦:៣៨]

**ស៖** លោកបានប្រាប់មកយើងខ្ញុំតាមដែលលោកយល់ តាមការកត់សម្គាល់របស់លោក ថាប៉ង់ នេះជាប្រធានមន្ទីរ៨៧០ ហើយលោកក៏ត្រូវបានសួរអំពីស-៧១ ផងដែរ។ លោកនៅចាំចំណុចនេះទេ?

**ផ៖** ខ្ញុំបាទអត់ចាំទេ។ ប៉ង់ ហើយនិងស-២១ អត់បានចាំទេបាទ។

**ស៖** តើ យ-១០ នោះមានទំនាក់ទំនងអីជាមួយនឹង ប៉ង់ ដែរឬទេ?

**ផ៖** បាទ ខ្ញុំអត់ស្គាល់ យ-១០ ទេ។

**ស៖** លោកបានប្រាប់មកយើងខ្ញុំថា ប៉ង់ ទទួលខុសត្រូវសន្តិសុខ ដែលមានក្បាលម៉ាស៊ីនរបស់វា ហើយលោកបានៗបានជម្រាបថា ប៉ង់ គឺថាមានសិទ្ធិចេញចូលដោយសេរីនៅក្នុងទីក្រុងភ្នំពេញ ដើរហើរដោយសេរីបាទ។ តើលោកចាំចំណុចនេះទេ?

[០៩:៣៨:២៦]

**ផ៖** បាទ ខ្ញុំចាំចំណុចនេះ។

**ស៖** ថាតើក្បាលម៉ាស៊ីនសន្តិសុខនោះ និយាយអំពីមន្ទីរសន្តិសុខ ប្រសិនណាជាលោកដឹង។ ថាតើមន្ទីរសន្តិសុខមានទីតាំងនៅមន្ទីរស-៧១ ឬក៏មានទីតាំងនៅកន្លែងណាផ្សេង នៅខាងក្រៅពីកន្លែងនេះ?

**ផ៖** ខ្ញុំនៅភ្នំពេញ ខ្ញុំដើរមានក្របខ័ណ្ឌខ្ញុំដើរ ប៉ុន្តែខ្ញុំដើរទៅឃើញ ប៉ង់ អាចចេញចូលគ្រប់កន្លែង។ ខ្ញុំដឹងថា ប៉ង់ នេះចេញចូលបានគ្រប់កន្លែង ហើយខ្ញុំសន្និដ្ឋានថា ប៉ង់ អាចចេញចូលទៅខេត្តបានទៀត តាមរួមខេត្តរួមអីបានទៀត។

**ស៖** សក្ខីកម្មរបស់លោកថ្ងៃនេះគឺថា ប៉ង់ មិនត្រឹមតែមានលទ្ធភាពដើរហើយរនៅទីក្រុងភ្នំពេញទេ គឺអាចដើរហើរនៅតាមបណ្តាខេត្តផង តើអ៊ីចឹងមែនទេ?

[០៩:៤០:០២]

**ផ៖** បាទ។

**ស៖** ត្រឡប់ទៅសំណួររបស់ខ្ញុំមុនវិញ។ តើក្បាលម៉ាស៊ីនសន្តិសុខនៅត្រង់ណា? ថាតើមន្ទីរសន្តិសុខនៅត្រង់ណាដែល ប៉ង់ ជាអ្នកដឹកនាំនោះ? តើមន្ទីរសន្តិសុខនេះមានទីតាំងនៅត្រង់កន្លែងណាដែរ? លោកដឹងដែរទេ?

**ផ៖** ខ្ញុំអត់ដឹងច្បាស់ទេ។

**ស៖** នៅពេលដែលលោកជាផ្នែកមួយនៃក្បាលម៉ាស៊ីនសន្តិសុខនេះ មុននឹងគេចាត់តាំង ប៉ង់ ឲ្យ

ទៅនៅក្រសួងការបរទេស ថាតើពេលហ្នឹងលោកធ្វើការនៅកន្លែងណា? ពេលដែលលោកធ្វើការនៅមន្ទីរសន្តិសុខហ្នឹង ថាតើលោកធ្វើការនៅកន្លែងណា?

**ឆ៖** ខ្ញុំ? និយាយពីខ្ញុំធ្វើការសន្តិសុខ ឬមួយក៏ ប៉ង់?

[០៩:៤១:១៧]

**ស៖** ខ្ញុំសួរលោកតែម្តង។ មុននឹងលោកមកចូលធ្វើការនៅក្រសួងការបរទេស លោកបានប្រាប់មកខាងយើងខ្ញុំថា លោកធ្វើការជាមួយ ប៉ង់។ ហើយលោកក៏បានរៀបរាប់ព្រឹត្តិការណ៍មួយដែលថា លោកបានផ្តល់សន្តិសុខនៅក្រោមការណែនាំរបស់ ប៉ង់ ហើយដែលសមមិត្តរបស់លោកគឺ ជាម ក៏បានចូលរួមនៅក្នុងកិច្ចការនេះដែរ។ ដូច្នេះសំណួររបស់ខ្ញុំ គឺថានៅពេលនោះ តើមន្ទីរសន្តិសុខនោះមានទីតាំងនៅត្រង់កន្លែងណាដែរ?

**ឆ៖** ពេលចូលភ្នំពេញ សភាពការណ៍គឺថាវាច្របូកច្របល់។ រុយ គ្រាន់តែនិយាយហ្នឹងចូលមាត់។ ប៉ង់ មកប្រជុំជាមួយខ្ញុំ គឺប្រជុំពាក្យថាសន្តិសុខនេះ មិនមែនជារឿងសន្តិសុខអីទៅចាប់ទៅចងទៅនេះទៅនោះអី ស៊ើបអង្កេតអ្នកនេះអ្នកនោះទេ។ រឿងសន្តិសុខហ្នឹង គឺសន្តិសុខធ្វើម៉េចឲ្យទាំងអស់គ្នានេះបានស្អាតបាត កុំឲ្យមានរោគាអីព្យាធិអី។ រឿងនេះវាទាក់ទងសម្អាតក្រុង ដែលមកជួបហ្នឹង រឿងសម្អាតក្រុង។ ហើយថាសម្អាតនេះ ខ្ញុំបានជម្រាបលោកហើយណ៎ា មួយឆ្នាំ អត់ទាន់បានស្អាតទេ។ ហើយក្រសួងការបរទេសរបស់ខ្ញុំនេះ មួយឆ្នាំនេះខ្ញុំនិយាយផ្សាររដ្ឋ ផ្សារអីបានជម្រាបពីមុនហើយ គឺថាមិនមែនផ្សាររដ្ឋដូចឥឡូវនេះទេ។ បាទ ពីកំប៉ិកកំប៉ុកមើលទៅដូចចាប់ហួយ ក៏មិនថាចាប់ហួយដែរ។ អានេះសូមលោកជ្រាបបាទ។

**ស៖** ខ្ញុំពេញចិត្តណាស់ចំណុចនេះ។ ប៉ុន្តែលោកបានប្រាប់មកខ្ញុំថា នៅពេលភ្នំពេញដួលរលំទៅលោកបានផ្តល់សន្តិសុខជូន ប៉ុល ពត ហើយនៅពេលលោកមកភ្នំពេញ គឺថា ប៉ង់ បានជួបលោក។ ហើយបន្ទាប់មកលោកប្រាប់ថា នៅមានពេលមួយនោះ លោកបានផ្តល់សន្តិសុខ លោកទទួលខុសត្រូវសន្តិសុខឲ្យ ប៉ុល ពត។ ថាតើលោកចាំទេនៅពេលនោះ ថាតើមន្ទីរសន្តិសុខហ្នឹងមានទីតាំងនៅត្រង់ណាដែរ? លោកអាចដឹង ឬក៏លោកមិនដឹង?

[០៩:៤៤:០៧]

**ឆ៖** នេះខ្ញុំជម្រាបសភាពការណ៍ទៀតបានយល់។ ពេលចូលភ្នំពេញ ខ្ញុំអត់ចូលមកតាមលោកប៉ុល ពត ទេ--

**សៈ** លោកសាក្សី ខ្ញុំមានពេលវេលាតិចណាស់។ ដូច្នេះសំណួរខ្ញុំច្បាស់ហើយ លោកឆ្លាតណាស់ ខ្ញុំមើលទៅ លោកអាចឆ្លើយនឹងសំណួររបស់ខ្ញុំបាន។ តើលោកដឹងថាមន្ទីរសន្តិសុខហ្នឹងស្ថិតនៅត្រង់ណាដែរ? បើថាលោកមិនដឹងខ្ញុំនឹងបន្តសំណួរផ្សេងទៀត។ ដូច្នេះសូមឆ្លើយមកសំណួររបស់ខ្ញុំ។

**ផៈ** អត់ដឹងទេ។ អត់មាន ដូចអត់មានមន្ទីរសន្តិសុខអីសោះបាទ អត់។

**សៈ** លោកបានជម្រាបមកខ្ញុំថា ជាម ក៏បានធ្វើការនៅក្នុងក្បាលម៉ាស៊ីនសន្តិសុខនេះដែរ មុនពេល ជាម ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្រសួងការបរទេស។ លោកចាំចំណុចដែលលោកលើកឡើងនេះទេ?

**ផៈ** បាទ ចាំ។

**សៈ** តើសមមិត្ត ជាម បានប្រាប់ថាតើគាត់ធ្វើការនៅមន្ទីរសន្តិសុខដែរឬទេ? ហើយថា ជាម និងលោកនៅជាមួយគ្នាឬក៏យ៉ាងណា?

**ផៈ** ជាម មិនដែលប្រាប់ខ្ញុំថា មានមន្ទីរសន្តិសុខទេ ហើយរឿងសន្តិសុខអីផ្សេងៗ ជាម មិនដែលពិគ្រោះជាមួយខ្ញុំទេបាទ។

[០៩:៤៥:៥១]

**សៈ** លោកដែលសួរទៅគាត់ទេ លោកដែលនិយាយជាមួយ ជាម ទេ ដោយសារតែ ជាម ជាកូនចៅរបស់លោក? ហើយលោកជាអ្នកទទួលខុសត្រូវ-- គាត់ជាអ្នកទទួលខុសត្រូវចំពោះមុខលោកនៅក្នុងក្រសួងការបរទេស លោកដែលនិយាយជាមួយគាត់ទេ? ដែលសួរគាត់ទេ?

**ផៈ** សួរពីរឿងអីលោក?

**សៈ** សួរពីមុខងាររបស់គាត់!

**ផៈ** ខ្ញុំមិនដែលសួរពីមុខងាររបស់គាត់ទេ ពីព្រោះគាត់នៅក្រោមខ្ញុំ។

**សៈ** លោកបានជម្រាបមកខ្ញុំថា ប៉ង់ គឺថាអាចចេញចូលក្រសួងការបរទេស។ គាត់អាចយកមនុស្សមកធ្វើ គាត់អាចយកមនុស្សចេញទៅវិញ តាមចិត្តរបស់គាត់។ ថាតើលោកនៅប្រកាន់យកចម្លើយនេះដដែលឬក៏យ៉ាងណា?

**ផៈ** បាទ។

**សៈ** លោកក៏បានប្រាប់មកយើងខ្ញុំដែរថា សមមិត្ត ជាម បានជួយ និងបានសម្របសម្រួលការដឹកជញ្ជូនមនុស្សដែលគេយកចូលមកក្រសួងការបរទេស និងយកចេញទៅវិញតាមរយៈ ប៉ង់ ហើយ

គាត់ដឹកអ្នកទាំងនេះយកទៅកន្លែងណាផ្សេងទៀត។ តើលោកនៅតែរក្សាចម្លើយនេះដដែល ឬក៏យ៉ាងណា?

[០៩:៤៧:៣០]

**ឆ៖** បាទ។

**ស៖** ចាតើនៅពេលនោះសមមិត្ត ជាម នៅតែធ្វើការ ឬក៏នៅតែជាអ្នកដែលស្ថិតនៅក្រោមក្បាលម៉ាស៊ីនសន្តិសុខដែលដឹកនាំដោយ ប៉ង់ ដែរឬទេ?

**ឆ៖** បាទ។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់បន្តិច ប្រហែលជាសំណួរខ្ញុំមិនច្បាស់។ តើ ជាម ធ្វើការដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ ប៉ង់ ឬក៏យ៉ាងណានៅពេលដែល ប៉ង់ នោះស្ថិតនៅក្រោមអំណាចរបស់លោកដែរនោះ?

[០៩:៤៨:២៥]

**ឆ៖** បាទ ប៉ង់ នេះនៅពីលើ ជាម ទៀត។

**ស៖** ឥឡូវខ្ញុំមិនសួរអំពីឋានានុក្រមទេ។ អ្វីដែលខ្ញុំកំពុងសួរលោកនេះ គឺលោកបានប្រាប់មកយើងខ្ញុំថា ជាម ធ្លាប់ធ្វើការឲ្យ ប៉ង់ ហើយនៅពេល ប៉ង់ មកក្រសួងការប្រទេស ជាម ជួយធ្វើការឲ្យ ប៉ង់។ ដូច្នេះ សំណួរខ្ញុំថានៅពេលដែលសមមិត្ត ជាម ធ្វើការនៅក្រសួងការបរទេស ដែលគាត់ជាកូនចៅរបស់លោកផ្ទាល់នោះ តើពេលដែល ជាម ក្លាយមកជាកូនចៅរបស់លោក មេរបស់ ជាម នៅតែ ប៉ង់ ដដែល ក្នុងពេលជាមួយគ្នា ឬក៏យ៉ាងណា?

**ឆ៖** បាទ ប៉ង់ ជាមេដដែល។

**ស៖** អ៊ីចឹង ហេតុអ្វីបានជាលោកប្រាប់មកយើងខ្ញុំ ថាពេលនៅមួយនោះ លោកធ្លាប់បានសួរទៅសមមិត្ត ជាម ថាតើពេលរបស់លោកដែល-- គឺថាពេលវេលារបស់លោកអាចនឹងៗមកដល់លោកនៅពេលក្រោយ។ លោកចាំទេ កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុននោះ លោកបាននិយាយថា ខ្ញុំសូមដកស្រង់សម្តីតែម្តងនៅទំព័រ១៦ "ខ្ញុំចង់បញ្ជាក់ចំណុចមួយលោកនិយាយអ៊ីចេះ--

**អ្នកបកប្រែ៖**

លោកប្រធានសូមអធ្យាស្រ័យអ្នកបកប្រែតាមម៉ោងអំមិញអត់ទាន់ សូមឲ្យលោកមេធាវីបញ្ជាក់ម្តងទៀត។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** គឺនៅម៉ោង [០៩:៥៣:៤១]។ "ខ្ញុំដឹងថា ជាម បានយកមនុស្សទាំងនោះទៅបាត់ទៅ ហើយខ្ញុំបានសួរ ជាម អំពីចំណុចហ្នឹង។ ខ្ញុំសួរថាតើអ្នកទាំងអស់-- អ្នកឯងយកអ្នកទាំងអស់នេះទៅណា?" ហើយលោកក៏បាននិយាយថា "វេនរបស់ខ្ញុំ គាត់ថាពេលវេលានៃជីវិតរបស់ខ្ញុំនឹងមកដល់ពេលក្រោយហើយ នឹងឈានមកដល់ពេលក្រោយហើយ"។ តើលោកចាំថាលោកបានិយាយអ៊ីចឹងទេ?

[០៩:៥១:០៦]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំមិននិយាយដូច្នេះទេ។ ប៉ុន្តែខ្លឹមសារវាផ្សេង ឲ្យខ្ញុំនិយាយម្តងទៀត ខ្ញុំក៏និយាយជម្រាបជូន។

**ស៖** បាទសូមលោកសាក្សីជួយពន្យល់ផង ដូច្នេះដើម្បីឲ្យខ្ញុំយល់ឲ្យបានច្បាស់ ដោយសារខ្ញុំអានជាភាសាអង់គ្លេស ហើយប្រតិចារឹកជាភាសាខ្មែរវាអាចខុសគ្នាខ្លះ។ ដូច្នេះ ខ្ញុំសូមឲ្យលោកពន្យល់ ហើយខ្ញុំនឹងបង្ហាញប្រតិចារឹកនេះទៅដល់លោកសាក្សីផងដែរ លោកសាក្សីសូមលោកជួយពន្យល់ផង!

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកប្រតិចារឹកដែលបង្ហាញសាក្សីត្រង់ចំណុចដែលមេធាវីប៉ុនប៉ងក្នុងការ --មានបំណងក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ ដើម្បីឲ្យគាត់បានពិនិត្យជាមុនៗនឹងឆ្លើយពីព្រោះសំណួរដូចជាឡប់ចុះឡប់ឡើង ច្រំដែលច្រើនលើកច្រើនសាណាស់។

[០៩:៥២:៤៩]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់សំណួរនេះដូចតទៅ៖ ពេល ប៉ង់ ឲ្យ ជាម មកយកមនុស្សពីក្រសួងការបរទេសទៅ ជាម គេយកទៅ។ ពេល ជាម មកវិញខ្ញុំក៏សួរ សួរហ្នឹងគឺថា ទាំងភិតទាំងភ័យផងទេណ៎ះ! គឺថា "គេយកទៅណាអ្នា?" "ខ្ញុំយកទៅគេទទួលយកៗទៅទៀត មិនដឹងទៅណាដែរ" ជាម ហ្នឹងឆ្លើយមកខ្ញុំ អ៊ីចឹង។ ដូច្នេះបានន័យថា ខ្ញុំសួរមែន ប៉ុន្តែសួរហ្នឹងក្នុងន័យថា យកទៅណាៗ ប៉ុន្តែ ជាម ឆ្លើយថា "គេបន្តទៅទៀតហើយ ខ្ញុំមិនដឹងទៅណាទេ"។ បានជាខ្ញុំគិតថា "យី!អារបៀបយកអ៊ីចឹងថ្ងៃណាដល់វេនអញទៀតហើយ! យករបៀបអ៊ីចឹងនោះ"។ នេះន័យដូច្នេះលោក។ សូមបញ្ជាក់ជូន។

[០៩:៥៤:១០]

**ស៖** ដូច្នេះ ខ្ញុំចង់បញ្ជាក់ចំណុចពីរ ដែលប្រតិចារឹកបានសរសេរថា យ៉ាងហោចណាស់ខ្ញុំអានជាភាសាអង់គ្លេស ហើយបន្ទាប់មកជាភាសាបារាំងអាចនឹងតាមក្រោយភាសាអង់គ្លេសទៅចុះ។ ចំណុចមួយលោកនិយាយថា លោកបានឆ្លើយទៅ ជាម ហើយខ្ញុំ-- លោកនិយាយថា “តិចៗមកដល់អញទៀតទៅ”។ ដូច្នេះសំណួររបស់ខ្ញុំ ថាតើពេលនុំងលោកបាននិយាយថា អ៊ីចឹង ឬក៏លោកគិតថា អ៊ីចឹង?

**ឆ៖** ពេលនោះ ខ្ញុំដូចនិយាយអ៊ីចឹងមែនថា អ្ហឹះ! ថាបន្តិចទៀតវេនអញទៀតហើយ នៅមុខជាម អ៊ីចឹងបាទ។

**ស៖** ហើយនៅពេលដែលលោកនិយាយបែបនេះ នៅពេលហ្នឹង ថាតើលោកនិយាយលេងសើចឬក៏លោកនិយាយបែបៗហ្មត់ចត់?

**ឆ៖** គឺថាអារម្មណ៍ពេលហ្នឹង ចេញឲ្យខ្ញុំនិយាយអ៊ីចឹងម្តងបាទ។ លោកពិចារណាទៅ ហ្មត់ចត់ឬមិនហ្មត់ចត់ ក៏ខ្ញុំមិនដឹងដែរបាទ។ ខ្ញុំនិយាយឲ្យត្រង់អ៊ីចឹងម្តង បាទខ្ញុំមិនចេះវិភាគដែរ។ ខ្ញុំនិយាយជារបៀបអ៊ីចឹងទៅ កុំឲ្យខ្ញុំគិតថា យី! បើនិយាយទៅ ថាឯងជម្រិតសួរ ជាម សួរអីខ្ញុំនិយាយថា កុំឲ្យខ្ញុំថាជម្រិតសួរគេណ៎ា ចិត្តខ្ញុំអ៊ីចឹងទេ ខ្ញុំនិយាយថា “អ្ហឹះ! ប្រហែលអញថ្ងៃណាមួយមិនខានទេអ៊ីចឹង”។ ន័យនេះ គឺន័យប្រយ័ត្នប្រយែងហើយ។

[០៩:៥៦:០២]

**ស៖** នៅពេលលោកនិយាយបែបដូច្នេះ ប្រហែលជាសំណួរនេះដូចថាវាមិនសូវច្បាស់លាស់លឿនពេក។ នៅពេលដែលលោកនិយាយទៅកាន់សមមិត្ត ជាម តើលោកបានគិតថា ក្រៅពីលោកដែលជាក្មួយបង្កើតរបស់ ប៉ុល ពត ដែលថាថ្ងៃណាមួយនោះអាចនឹងដល់វេនលោកហើយ--

**ប្រធានអង្គជំនុំ៖**

មេធាវីតាំងសំណួរសាជាថ្មីម្តង ជាភាសាខ្មែរ មិនដឹងថា លោកសួរ ឬក៏លោកនិយាយឲ្យសាក្សីស្តាប់ទេ។ អ៊ីចឹងសាក្សី គាត់អត់ដឹងឆ្លើយថាម៉េចទេ ពីព្រោះសំណួរ ឬក៏មិនមែនជាសំណួរ?

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន ព្រឹកថ្ងៃចន្ទ ហាក់ដូចអស់កម្លាំងបន្តិច។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី នៅពេលដែលលោកនិយាយថា ខ្ញុំចង់ឲ្យលោករំឭកទៅដល់ពេលក្រោយបន្តិចដោយគិតទៅកាលៈទេសៈពេលនោះ តើលោកពិតជាបានគិតថា សូម្បីតែលោកជាក្មួយបង្កើតរបស់ ប៉ុល

ពត ក៏ដោយ ក៏ប្រហែលជាថ្ងៃណាមួយ វាអាចនឹងដល់ពេលលោកហើយ តើៗលោកគិតថាអ៊ីចឹងទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ គិតអ៊ីចឹង។

[០៩:៥៧:៥៤]

**ស៖** លោកនិយាយអំពីការបង្ហាញឲ្យឃើញនូវការភ័យខ្លាច ទាំងក្នុងក្រសួងការបរទេស ទាំងក្រៅក្រសួងការបរទេស។ អានេះនិយាយជារួម។ តើលោកនៅចាំថាលោកបាននិយាយអ៊ីចឹងទេ?

**ឆ៖** បាទ។

**ស៖** អ្វីដែលខ្ញុំចង់បាននៅពេលនេះ គឺថាសុំឲ្យលោកគិតទៅដល់ពេលនោះ ចន្លោះពីឆ្នាំ៧៥ ទៅ ៧៩ ដែលយើងខ្ញុំ គឺថាមិនមានបទពិសោធន៍នៅក្នុងចន្លោះពេលនោះទេ។ ដូច្នេះសូមឲ្យលោករៀបរាប់មើលថា តើអារម្មណ៍របស់លោកនៅចន្លោះពេលហ្នឹង វាមានអារម្មណ៍យ៉ាងម៉េចដែរ?

[០៩:៥៨:៤៩]

**ឆ៖** អារម្មណ៍ពេលនោះ គឺខ្ញុំគិតដល់ក្រុមគ្រួសារខ្ញុំ ដែលមានគ្រោះថ្នាក់ដូចគេ ដូចឯងដូច្នេះដែរទាំងឪពុក ទាំងម្ដាយ។ ដូច្នេះ ខ្ញុំព្រួយបារម្ភទៅក្រុមគ្រួសារខ្ញុំ ហើយផ្ទាល់ខ្លួនខ្ញុំទៀត នៅក្នុងពេលនោះ ខ្ញុំបាននិយាយសាចុះសាឡើងហើយ ក៏ខ្ញុំព្រួយបារម្ភដែរ ព្រួយបារម្ភៗ។ ហើយការនិយាយរបស់ខ្ញុំនេះ ជាមួយ ជាម នេះដូចខ្ញុំបានជម្រាបអ៊ីចឹង គឺខ្ញុំប្រយ័ត្នប្រយែងណាស់។ សួរ សួរនាំអីៗទៅ តែគេក្រឡេកឃើញមកថា ខ្ញុំអីទាក់ទងនឹង ជាម។ ប៉ង់ មកប្រើ ជាម ហើយ ស្រាប់តែខ្ញុំហ្នឹងមកសួរ ជាម សួរអី ស្និទ្ធស្នាលជាមួយ ជាម អីអ៊ីចឹងទៅ។ ខ្ញុំគិតណាស់ណា ខ្ញុំគិតមហាជនគេនៅជុំវិញខ្ញុំ គេគិតៗថា អានេះទាក់ទងនឹងជាមួយ អាប៉ង់ ដឹង? អានេះទាក់ទងជាមួយនឹង ជាម យកមនុស្សទៅមិនដឹង? ដូច្នេះខ្ញុំគិតណាស់ បញ្ហានេះខ្ញុំព្រួយ។ សូមជ្រាប។

[១០:០០:៣៧]

**ស៖** លោកក៏បានជម្រាបមកយើងខ្ញុំដែរថា ត្រឡប់ទៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ គឺប្រតិចារឹកត្រង់ទំព័រ៥១។ សូមអធ្យាស្រ័យ គឺនៅត្រង់ទំព័រទី៥៤ នៃប្រតិចារឹកទៅវិញទេ ដែលសរសេរថា ពេលវេលាគឺម៉ោង ១៤:៣៧:០៣ លោកបានប្រាប់មកយើងខ្ញុំថា “សូម្បីតែខ្លួនខ្ញុំក៏មានការព្រួយបារម្ភដែរ ហើយអ្នកដទៃទៀតក៏មានការភ័យខ្លាចដែរ”។ តើលោកនៅចាំថា លោកបាននិយាយយ៉ាងដូច្នេះទេ ហើយលោកនៅតែរក្សាចម្លើយនេះដដែលទេថា សូម្បីតែខ្លួនលោកក៏ព្រួយ ហើយអ្នកដទៃទៀត

ក៏ព្រួយដែរ?

[១០:០១:៤៤]

**ឆ៖** បាទ ខ្ញុំរក្សាចម្លើយនេះ។

**ស៖** តើលោកអាចពន្យល់ដែរឬទេ អ្នកដទៃនោះ មានការភ័យខ្លាចយ៉ាងម៉េចដែរ? លោកបានរៀបរាប់អំពីការភ័យខ្លាចរបស់លោករួចមកហើយ តើលោកមានហេតុផលអ្វីដែលជឿថា អ្នកផ្សេងនោះមានការភ័យខ្លាចដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់ៗក្បាលមីក្រូទេ។ ចាំមានភ្លើងក្រហម ឲ្យវាដំណើរការសឹមចាប់និយាយ។

**លោក សាឡូត បាន៖**

**ឆ៖** ខ្ញុំបានរៀបរាប់ជាបន្តបន្ទាប់ហើយ ការភ័យព្រួយនេះ។ ទីមួយ ខ្ញុំដើរទៅជនបទ គេនិយាយថា លំបាកអត់បាយអត់ទឹកអី មានការចាប់ចងនៅមូលដ្ឋានហ្នឹងទីមួយ។ ទីពីរ ក្នុងមន្ទីរក៏មានការច្របូកច្របល់។ នេះសភាពការណ៍នេះ គឺវៀតណាមជិតចូលមកកៀកហើយ ច្របូកច្របល់ខ្លាំងណាស់។ ដូច្នេះ ទាំងមូលដ្ឋាន ទាំងមន្ទីរ មន្ទីរផ្សេងៗទៀត ខ្ញុំមិនដឹងទេ តែខ្ញុំប៉ាន់ប្រមាណទៅប្រហែលដូចគ្នាទេ គឺច្របូលច្របល់ទាំងអស់គ្នា។ ឥឡូវ ខ្ញុំនិយាយបន្តទៅទៀតចុះ ឲ្យវាឆាប់ចប់ទៅ។ ដល់តែពេលដែលមាន៩ហ្នឹ ៩ជាន់ដែលថា ត្រូវយកមនុស្សទៅសម្លាប់ ឬមួយយកមនុស្សទៅឲ្យមានទោស៩ជាន់នោះ ពេលនោះយើងទាំងអស់គ្នាក៏បានរីករាយថា អ៊ូ! យើងបានៗសេចក្តីសុខហើយ ហើយមានច្បាប់មួយទៀតនោះគឺថា សហករណ៍មួយៗហ្នឹងឲ្យមានម្ហូបអាហារអីឲ្យឆ្អែត។ ពេលនោះ វៀតណាមចូលមកក៏ខ្ចាត់ខ្ចាយគ្នាទៅ។

[១០:០៤:១៧]

**ស៖** យើងនិយាយអំពីការភ័យខ្លាច នៅត្រង់ចំណុចមួយ ត្រង់ទំព័រ៦៤ នៃប្រតិចារឹកគឺត្រង់ម៉ោង ១៥:១៥:៤៦ មានសំណួរសួរអំពីការឆ្លើយដាក់។ តើពាក្យថា "ឆ្លើយដាក់នោះ" នៅក្នុងឯកសារមានន័យយ៉ាងម៉េច? តើលោកមានចាំថា លោកធ្លាប់បានជជែកពិភាក្សាអំពីបញ្ហានៃការឆ្លើយដាក់នៅសម័យនោះដែរឬទេ?

**ឆ៖** ខ្ញុំអត់បានជជែកអំពីបញ្ហាឆ្លើយដាក់ទេ។

**សៈ** ខ្ញុំសូមសួរអ៊ីចេះវិញ តើលោកមានការភ័យខ្លាចថាគេនឹងឆ្លើយដាក់លោកដែរឬទេ? លោកមានការភ័យខ្លាចថាអ្នកខាងក្រៅនឹងឆ្លើយដាក់លោកដែរឬទេ? ហើយដែលការឆ្លើយដាក់នោះ នាំឲ្យមានការចាប់ខ្លួនលោក។ តើលោកមានការភ័យខ្លាចអ៊ីចឹងដែរឬទេ?

**ផៈ** ក្នុងពេលនោះ ខ្ញុំភ័យខ្លាចយ៉ាងនេះដែរ។

**សៈ** លោកបានជម្រាបយើងខ្ញុំថា លោកមានប្រវត្តិរូបស្អាតស្អំ ហើយលោកក៏ជម្រាបយើងខ្ញុំដែរថា លោកមានការប្រយ័ត្នប្រយែងអនុវត្តតែតាមមុខនាទី តួនាទីរបស់លោកតែប៉ុណ្ណោះ។ យើងក៏បានដឹងដែរថា លោកមានសាច់ញាតិជាប់ជាមួយនឹង ប៉ុល ពត។ ដូច្នេះ ខ្ញុំចង់សួរថា ហេតុអ្វីបានជាមនុស្សដូចរូបលោកដែលមានទំនាក់ទំនង មានការធ្វើការងារដូច្នេះហើយ បែរជាភ័យខ្លាចអំពីការឆ្លើយដាក់ទៅវិញ?

[១០:០៦:២៨]

**ផៈ** ខ្ញុំសូមសរុបឲ្យខ្លី គឺខ្ញុំដឹងច្បាស់ណាស់ ប៉ុល ពត គ្មានមនោសញ្ចេតនាគ្រួសារនិយមទេ។ ដាច់ខាតគ្មានតែម្ដង។

**សៈ** ហេតុអ្វីបានជាលោកភ័យខ្លាចថាគេឆ្លើយដាក់លោក? ទោះបីជាលោក ប៉ុល ពត នោះគាត់មានអារម្មណ៍មួយ ដូចជាស្និទ្ធស្នាលជាមួយលោកដែរនៅពេលនោះ។

**ផៈ** សំណួរនេះខ្ញុំឆ្លើយដដែល។

**សៈ** ចុះកម្មាភិបាលផ្សេងទៀតនៅក្នុងក្រសួងរបស់លោកនោះ មានការភ័យខ្លាចដូចលោកថាគេនឹងឆ្លើយដាក់ពួកគេដែរឬទេ?

**ផៈ** បើខ្ញុំអ៊ីចឹងទៅហើយ អ្នកដទៃទៀត ខ្ញុំគិតថាវាហួស ភ័យហួសជាងខ្ញុំទៅទៀត។

**សៈ** លោកបានជម្រាបយើងខ្ញុំ រួមទាំងសហចៅក្រមស៊ើបអង្កេត ហើយក៏ឆ្លើយនៅមុខតុលាការនេះផងដែរថា លោក អៀង សារី ក៏មានការភ័យខ្លាចដូចអ៊ីចឹងដែរ។ តើការភ័យខ្លាចហ្នឹងលោក អៀង សារី ក៏មានអ៊ីចឹងដែរ តើមានមែនដែរឬទេ ផ្អែកតាមអ្វីដែលលោកធ្លាប់ឆ្លងកាត់ និងបទពិសោធន៍របស់លោកនៅពេលនោះ?

[១០:០៨:៤១]

**ផៈ** ខ្ញុំមិនបានឮពាក្យពោលរបស់លោកទេ ខ្ញុំមើលមុខរបស់លោក ស្រងូតស្រងាត់ គិតគូរដល់បុគ្គលិករបស់លោក ខ្លាចវាមានរឿងអ៊ីចឹង។

**ស៖** ប្រសិនបើយើងមើលឯកសារមួយ ឯកសារ E3/91។ យើងខ្ញុំសូមឲ្យខាងផ្នែកតុលាការជួយបង្ហាញឯកសារជាភាសាខ្មែរគឺ 00204097-98, បារាំង 00503936 ដល់ 37, ជាភាសាអង់គ្លេសគឺ 00223593 ហើយទំនងជានៅទំព័រចុងក្រោយ គ្រប់ឯកសារទាំងបីភាសា។

លោកទើបតែទទួលបានឯកសារមួយច្បាប់នៅ-- ផ្តល់ជូននៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារនេះចុះនៅថ្ងៃ១១ ខែកញ្ញា ឆ្នាំ២០០៧។ ខ្ញុំសូមអាន ត្រង់ចំណុចលោកឆ្លើយ "នៅពេលដែលបុគ្គលិកក្រសួងនោះបានបាត់ខ្លួន អៀង សារី មិននិយាយអ្វីទាល់តែសោះ។ គាត់ខ្លួនឯងមានការភ័យខ្លាចខ្ញុំក៏ភ័យដែរ"។ ហើយលោកបានលើកជាឧទាហរណ៍ ក៏ប៉ុន្តែខ្ញុំសូមអានផងដែរ ទោះបីជាវាក្រៅប្រធានបទនេះក៏ដោយ។ "ឧទាហរណ៍ បងស្រីរបស់ ខៀវ ធីរិទ្ធ ឈ្មោះ ខៀវ ធីរ៉ាត់ ដែលជាបញ្ញាជនមកពីប្រទេសបារាំង ពេលនោះត្រូវអង្គការឲ្យសម្រាកនៅតាខ្មៅ ហើយក្រោយមកក៏ត្រូវស្លាប់ដោយមានស្នាមច្របាច់ក ក្នុងរយៈពេលដែលគាត់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ប៉ង់ នៅតាខ្មៅ"។ តើលោកបានឃើញនូវចំណុចដែលខ្ញុំអាននេះដែរឬទេលោក?

**ឆ៖** បាទបានឃើញ។

[១០:១១:៤៥]

**ស៖** នៅពេលដែលខ្ញុំមើលចំណុចនេះ ខ្ញុំអត់មានឃើញពាក្យថា ស្រងូតស្រងាត់ទេ គ្រាន់តែនិយាយថា គាត់ភ័យខ្លាចខ្ញុំក៏ភ័យខ្លាចដែរ។ តើលោកនៅតែរក្សាសម្តីរបស់លោក ដូចអ្វីដែលសរសេរនេះដែរឬទេ?

**ឆ៖** បាទ រក្សា។ តែភ័យហើយស្រងូតស្រងាត់ហើយ។

**អ្នកបកប្រែ៖**

សូមអនុញ្ញាតឲ្យមេធាវី បើមីក្រូហ្វូន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** អ្នកណា បុគ្គលគ្រប់រូបអាចស្រងូតស្រងាត់ ក៏ប៉ុន្តែអត់មានការភ័យខ្លាចទេពេលខ្លះ។ តើលោកគិតថា ការស្រងូតស្រងាត់ហ្នឹងវាស្មើនឹងការភ័យខ្លាច ឬក៏មានលក្ខណៈខុសគ្នា?

**ឆ៖** ខ្ញុំមិនដឹងជាអ្នកចិត្តសាស្ត្រយ៉ាងម៉េចដែរ តែខ្ញុំភ័យហើយមុខខ្ញុំស្រងូតហើយបាទ។ តែភ័យអីមួយហើយ មិនចេះសើចទេបាទ។

[១០:១៣:០៨]

**ស៖** សូមអរគុណ។ តើលោកនៅតែរក្សាពាក្យសម្ដីដែលលោកឆ្លើយចំពោះចៅក្រមស៊ើបអង្កេតដែរឬទេ បាទ គឺឆ្លើយចំពោះមុខអ្នកស៊ើបអង្កេត។ តើលោកប្រកាន់សម្ដីដែលលោកឆ្លើយនៅមុខអ្នកស៊ើបអង្កេតដែរឬទេ ដែលពេលនោះលោកឆ្លើយថា "លោក អៀងសារី ខ្លួនឯងនុង ក៏មានការភ័យខ្លាចដែរ"?

**ប្រធានអង្គជំនុំ៖**

សំណួរច្រំដែល សួររួចហើយសំណួរនេះ។ មិនបាច់ឆ្លើយទេសាក្សី។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** សូមអរគុណ។ យើងមើលឧទាហរណ៍ដែលលោកឆ្លើយវិញម្ដង។ ហេតុអ្វីបានជាលោក អៀង សារី និង លោក ទំនងជាមានការភ័យខ្លាច។ លោកបានលើកឡើងថា លោកបានលើកឡើងអំពីឈ្មោះ ខៀវ ធីរ៉ាត់ តើលោកស្គាល់បុគ្គលនេះ ឬក៏លោកមិនស្គាល់ទេ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំស្គាល់បុគ្គលនេះ។

**ស៖** ខ្ញុំជឿថា លោកបានជម្រាបយើងខ្ញុំថា គាត់ហ្នឹងគឺជាបងថ្លៃលោក អៀង សារី តើត្រឹមត្រូវដែរទេ?

**ប្រធានអង្គជំនុំ៖**

លោករង់ចាំឆ្លើយម្ដងទៀត ចាំក្បាលមីក្រូដំណើរការសិន។

**លោក សាឡុត បាន៖**

**ឆ៖** បាទត្រឹមត្រូវ។

[១០:១៥:០០]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** តើប្រពន្ធរបស់ ប៉ុល ពត មានជាប់សាច់ឈាមជាមួយ ជាប់សាច់ញាតិជាមួយ ខៀវ ធីរ៉ាត់ ដែលឬទេ?

**ឆ៖** បាទ ជាប់សាច់ឈាម។

**ស៖** សូមឱ្យលោកជម្រាបថាជាប់សាច់ញាតិ សាច់ឈាមយ៉ាងម៉េចទៅ ដើម្បីឱ្យយើងកត់ត្រាចូលប្រតិចារឹក។ សូមអញ្ជើញ!

**ឆ៖** ជាបងប្អូនបង្កើត។

**ស៖** សូមអរគុណ។ ដូច្នេះអ្វីដែលយើងនិយាយអំពីឧទាហរណ៍ដែលលោកបានលើកឡើង សូមលោកកែខ្ញុំ ប្រសិនបើខ្ញុំនិយាយខុស។ ក្នុងនេះមានន័យថា បងប្អូនស្រីរបស់ ប៉ុល ពត នេះក៏មានការទំនាក់ទំនងជាមួយនឹងប្រពន្ធរបស់លោក អៀង សារី ដែរ។ ដូច្នេះហើយ គឺក៏មានការភ័យខ្លាច និងការចាប់ខ្លួនផងដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងដែរ ខ្ញុំនៅបែកគ្នាមិនដឹងគាត់ស្រងូតស្រងាត់ដែរ ឬមិនដឹងយ៉ាងណាទេបាទ នៅបែកគ្នា។

[១០:១៦:៤១]

**ស៖** លោកលើកឡើងនៅក្នុងនេះថា នៅពេលដែលគាត់ត្រូវបានគេច្របាច់កនោះ គឺគាត់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ប៉ង់ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ប៉ង់ នេះគឺជា ប៉ង់ តែមួយទេ គឺជា ប៉ង់ ដែលធ្វើការងារសន្តិសុខការពារទៅដល់ ប៉ុល ពត នៅពេលដែលនៅក្នុងព្រៃ ហើយក៏ជាមេផ្ទាល់របស់លោកផងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** ខៀវ ធីរ៉ាត់ ស្ថិតនៅក្រោមការគ្រប់គ្រងថែទាំរបស់ ប៉ង់ ហើយត្រូវបានគេច្របាច់ក។ តើការដែលច្របាច់កគាត់នោះ គឺជាការព្រួយបារម្ភសម្រាប់លោកផងដែរ ដែលឲ្យលោកលើកឧទាហរណ៍ករណីនេះឡើង ហើយបង្ហាញថាលោក អៀង សារី ក៏មានការភ័យខ្លាចអ៊ីចឹងដែរ។ តើមែនដែរឬទេ?

**ឆ៖** បាទ ចំពោះខ្ញុំ ពេលនោះខ្ញុំភ័យខ្លាច។ ឯបង អៀង សារី ពេលដែលលោកស្រី អៀង ធីរ៉ាត់ អ៎! អៀង ធីរ៉ាត់ នុំងស្លាប់នុំង លោកអត់មានបានឃើញនៅចំពោះមុខខ្ញុំទេ មិនដឹងជាគាត់ភ័យបារម្ភយ៉ាងម៉េចដែរ ខ្ញុំអត់ដឹងដែរ។

[១០:១៧:៥១]

**ស៖** សូមអរគុណច្រើន។ នៅពេលនេះយើងនិយាយអំពីហេតុការណ៍មួយទៀត ដែលនិយាយអំពី ឃួន ដាវីដ។ ខ្ញុំមិន ប្រហែលជាអានឈ្មោះមិនត្រូវនោះទេ។ លោកបានលើកឡើងថា ឃួន ដាវីដ នេះ ជាសាស្ត្រាចារ្យមួយរូបដែលលោកធ្លាប់ជួប។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ជួបតែមួយភ្លែត។ ប៉ុន្តែគេធ្លាប់ប្រាប់ខ្ញុំ ពួកបញ្ញាជនទាំងអស់នោះធ្លាប់ប្រាប់ខ្ញុំថា

ឃួន ដាវីដ នេះ ជាសាស្ត្រាចារ្យលើសាស្ត្រាចារ្យ។ ខ្ញុំក៏មិនយល់ដែរ សាស្ត្រាចារ្យលើសាស្ត្រាចារ្យហ្នឹង គឺថារៀនពូកែណាស់នៅឯប្រទេសបារាំង។ បាទ ខ្ញុំបានដឹងតែប៉ុណ្ណឹងទេ។

[១០:២០:០០]

**ស៖** សូមអរគុណ។ មុនពេលដែលយើងនិយាយលម្អិតអ្វីដែលលោកបាននិយាយអំពីករណីនេះ គឺនៅពេលដែល-- មុនពេលដែលយើងចូលនិយាយលម្អិតអំពីបុគ្គលដែលលោកធ្លាប់ឮឈ្មោះនេះ តើលោកនៅតែរក្សាសម្ដីដែលថា លោកសាស្ត្រាចារ្យរូបនោះក៏បាត់ខ្លួន ឬក៏ទទួលគ្រោះថ្នាក់ក្រោមការគ្រប់គ្រងរបស់ ប៉ង់ ផងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** វាអាចឱ្យយើងយល់ទាំងអស់គ្នា-- យល់ទាំងអស់ យើងអាចយល់ទាំងអស់គ្នាដែរ តាមអ្វីដែលលោកឆ្លើយ ឱ្យយើងយល់ម្ដងមួយៗ គឺត្រង់ទំព័រ៧២ នៃប្រតិចារឹកកាលពីថ្ងៃព្រហស្បតិ៍សប្ដាហ៍មុន។ គឺឯកសារជាភាសាខ្មែរ 00803206 ដល់ 07។ យើងអត់មានលេខERNជាភាសាបារាំងនិងអង់គ្លេសនោះទេ។ ប៉ុន្តែអង់គ្លេសគឺត្រង់ទំព័រ៧២។ ពេលវេលាគឺប្រហែលនៅម៉ោង-- នៅក្រោមម៉ោង ១៤:១២:២៣ ដើម្បីឱ្យលោកងាយស្រួលរកឯកសារ និងពិនិត្យមើល ខ្ញុំសូមលើកឡើងផ្នែកដែលពាក់ព័ន្ធនៅក្នុងប្រតិចារឹក ដើម្បីឱ្យលោកអាន និងយល់តាម និងអាចតាមទាន់។

អង់គ្លេសត្រង់ទំព័រ ៧២ រហូតទៅដល់ ៧៤ បន្ទាប់មកពី ៨៩ ទៅដល់ទំព័រ ៩០។

តើលោកសាក្សីមានកំណត់ត្រាប្រតិចារឹកនៅចំពោះមុខដែរឬទេលោក?

[១០:២២:០២]

**ឆ៖** បាទ មាន។

**ស៖** នៅពេលនេះយើងពិនិត្យមើលអ្វីដែលលោកបានឆ្លើយ ដើម្បីឱ្យយើងយល់ទាំងអស់គ្នា។ “អ្នកដែលចាំជាងគេឈ្មោះ ដាវីដ-- ឃួន ដាវីដ។ ខ្ញុំឮថាកាលនោះក្រសួងការបរទេស ខ្ញុំឮបញ្ញាជនដែលទៅលេង ទៅធ្វើការបរទេស និងប្រាប់ឈ្មោះ-- ប្រាប់ខ្ញុំថាមានម្នាក់ឈ្មោះ ឃួន ដាវីដ គាត់ហ្នឹងពូកែណាស់។ គាត់ទៅរៀនបរទេសហ្នឹង គឺថាគាត់ធ្វើសាស្ត្រាចារ្យ លើសាស្ត្រាចារ្យទៀត”។ ខ្ញុំអានឱ្យយឺតៗ ដើម្បីឱ្យអ្នកបកបារាំងបកទាន់។ “ខ្ញុំឮយ៉ាងដូច្នេះ។ ខ្ញុំទៅប្រាប់ឪពុកមាខ្ញុំឈ្មោះ ប៉ុល ពត។ ពីព្រោះពេលដែលខ្ញុំនាំស្អីៗទៅដូចមានត្រី ល្អៗអីអ៊ីចឹងទៅ គេអាចឱ្យខ្ញុំចូលបានទៅកន្លែងគេ ហៅថា ក-១ ហ្នឹង”។ ខ្ញុំសូមឈប់ត្រង់ចំណុចហ្នឹងសិន។

លោកសាក្សី ត្រង់ចំណុចនេះទំនងជាបង្ហាញឱ្យយើងឃើញថា លោកបានធ្លាប់ឮឈ្មោះបុគ្គលហ្នឹងពីអ្នកដទៃ ពីបញ្ញាជនផ្សេង ហើយលោកខ្លួនឯងបានទៅជួបឪពុកមារបស់លោកគឺ ប៉ុល ពត។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១០:២៣:៤៩]

**ស៖** ដូច្នេះនៅពេលនោះ គេឱ្យលោកចូលទៅជួបលោកពូរបស់លោកពូ ប៉ុល ពត ដោយសារតែលោកមានត្រីល្អៗ ហើយនិងមានរបស់របរនាំទៅជាមួយ។ ដូច្នេះហើយទើបគេឱ្យចូលទៅជួបឪពុកមារបស់លោកគឺ ប៉ុល ពត។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មែន។

**ស៖** ដូច្នេះយើងមើលតទៀត នូវអ្វីដែលលោកបានឆ្លើយ។ "នៅពេលដែលខ្ញុំជួបគាត់ គាត់ថាមានបញ្ញាជនណាពូកែៗទេ? ខ្ញុំប្រាប់ថា មានឈ្មោះបុគ្គលម្នាក់ឈ្មោះ ឃួន ដាវីដ"។ យើងឈប់ត្រង់ចំណុចនេះសិន។ ត្រង់ចំណុចនេះ តាមចម្លើយរបស់លោក គឺឪពុកមារបស់លោក ប៉ុល ពត បានសួរលោក ថាតើលោកមានធ្លាប់ឮឈ្មោះថាមានបញ្ញាជនណាពូកែដែរឬទេ? តើគាត់មានសួរលោកអ៊ីចឹងដែរឬទេ? ត្រឹមត្រូវដែរឬទេចំណុចហ្នឹង?

[១០:២៥:០១]

**ឆ៖** បាទ គាត់សួរអ៊ីចឹង។ មានអ្នកណាល្អទេ មើលទៅគេស្រឡាញ់ពេញចិត្តអីទេ អាហ្នឹងសួរច្រើន អានេះខ្ញុំឆ្លើយខ្លីៗទេ។ សួរថា របៀបរបបគាត់សួរថា មានមហាជនអីចូលចិត្តអីអ៊ីចឹងទៅណ៎ះ។ បាទខ្ញុំបាននិយាយអ៊ីចឹងមែន។

**ស៖** ខ្ញុំអត់មានឃើញថា មានមហាជនណាចូលចិត្តនៅក្នុងចម្លើយរបស់លោក។ ដូច្នេះ ទើបខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះ។ តើលោកនៅតែប្រកាន់សម្ដីដែលលោកឆ្លើយ ដោយលោកបានស្បថរួចមកហើយកាលពីសប្ដាហ៍មុនថា ឪពុកមារបស់លោក ប៉ុល ពត ហ្នឹងសួរថា តើលោកមានស្គាល់បញ្ញាជនពូកែៗដែរឬទេ? លោកនៅប្រកាន់សម្ដីដែលឆ្លើយកាលពីសប្ដាហ៍មុនដែរឬទេ?

**ឆ៖** បាទ។

**ស៖** ដើម្បីឱ្យយើងយល់ច្បាស់ទាំងអស់គ្នា។ តើមានតែពេលហ្នឹងតែម្ដងតែប៉ុណ្ណោះ ដែលឪពុកមារបស់លោក ប៉ុល ពត ហ្នឹងសួរលោកអំពីបញ្ញាជនពូកែៗ ឬក៏មានពេលណាទៀតដែលគាត់សួរលោក

អំពីបញ្ហាហ្នឹង? ឬក៏មានពេលណាមួយផ្សេងដែលលោកទៅជួបឪពុកមាររបស់លោក ប៉ុល ពត ហើយរាយការណ៍អំពីបញ្ហាជនពូកែៗទៅដល់គាត់?

**ឆ៖** បាទ មានតែម្តងនេះទេ។

**ស៖** សូមអរគុណ អ៊ីចឹងយើងបន្តទៅមុខទៀត។ "បន្ទាប់មកគាត់សួរខ្ញុំ ឲ្យខ្ញុំមើល ថាតើមនុស្សម្នាក់ដែលខ្ញុំលើកឡើងនោះ ពិតជាពូកែដែរឬទេ ដើម្បីគិតថាតើអាចធ្វើការជាមួយនឹងគាត់កើត ឬមិនកើត។ នេះហើយជាបុគ្គលម្នាក់ដែលខ្ញុំស្គាល់ច្បាស់ ខ្ញុំស្គាល់ច្បាស់"។ ដូច្នេះយើងឈប់ត្រង់ចំណុចហ្នឹងសិន។ ខ្ញុំចង់សួរលោកថា តើលោកដឹងច្បាស់ប្រាកដប៉ុនណាដែរ ដែលលោកគិតថាបុគ្គលម្នាក់នេះនោះពិតជាពូកែមែន?

[១០:២៧:៤១]

**ឆ៖** ខ្ញុំមិនប្រាកដទេ ប៉ុន្តែអ្នកដែលគេស្គាល់ ឃួន ដារីដ នេះក៏គេធ្វើការនៅក្រសួងការបរទេសដែរ គេប្រាប់ខ្ញុំអ៊ីចឹង។ ហើយអ្នកដែលនិយាយជាមួយខ្ញុំនេះ គឺជាជនមួយដែលខ្ញុំស្រឡាញ់រាប់អានដែរ។ ដូច្នេះ ខ្ញុំយកជាបានការហើយ។

**ស៖** សូមអរគុណ។ អធ្យាស្រ័យ ខ្ញុំព្យាយាមមើលចម្លើយរបស់លោកឲ្យបានឃ្លត់ចត់។ តាមចម្លើយរបស់លោកនោះ គឺថា ប៉ុល ពត ពិតជាចង់ដឹងថាបុគ្គលម្នាក់ហ្នឹងពូកែ ឬក៏មិនពូកែ ហើយប្រហែលជា ប៉ុល ពត ឬក៏អ្នកដទៃហ្នឹងអាចយកបុគ្គលហ្នឹងមកប្រើប្រាស់។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** អត់ៗ អត់ច្បាស់សំណួរ សូមសួរម្តងទៀត។ ចង់សួរថា ប៉ុល ពត ចង់បានមនុស្សហ្នឹង ឬមនុស្សដទៃទៀត ចង់បានឬយ៉ាងម៉េច? ខ្ញុំអត់យល់បាទ។

[១០:២៨:១៥]

**ស៖** ប៉ុល ពត ខ្ញុំនិយាយអំពី ប៉ុល ពត តាមចម្លើយរបស់លោក គឺលោកនិយាយថា ប៉ុល ពត ហ្នឹងចង់យកបុគ្គលម្នាក់ហ្នឹង យកមកប្រើប្រាស់។ ដូច្នេះហើយទើប ប៉ុល ពត ហ្នឹងមកសាកសួរលោកហ្នឹងថាតើបុគ្គលម្នាក់ហ្នឹងពិតជាពូកែមែន ឬក៏អត់?

**ឆ៖** គឺ ប៉ុល ពត តាមខ្ញុំមើល គាត់ចង់យកមនុស្សហ្នឹងមកប្រើប្រាស់។ អ្វីក៏មិនដឹងដែរបាទ។

**ស៖** ខ្ញុំសូមមើលទៅមុខទៀត តើលោកបាននិយាយអ្វីខ្លះបន្ថែមទៀត? ក្រៅពីហ្នឹង គឺក្រៅពីបុគ្គលហ្នឹង គឺថា ឃួន ដារីដ ហ្នឹងគឺខ្ញុំស្គាល់។ ហើយគេធ្លាប់និយាយអំពីគាត់។ ហើយបន្ទាប់មកគេសួរលោកបន្ត មានសំណួរសួរលោកបន្ត។ ខ្ញុំសូមបន្តទៅក្រោម៖

[១០:៣០:៣៦]

គេសួរមានសំណួរសួរមកលោកមួយសំណួរទៀត ហើយលោកឆ្លើយថា ប៉ុល ពត មានបំណង ដូច្នេះ ចង់យកបុគ្គលរូបហ្នឹងមកប្រើប្រាស់ដោយសារតែបុគ្គលនេះពូកែ ត្រង់ម៉ោង [១៤:១៥:៤៧]។ ដូច្នេះ នៅត្រង់ចំណុចហ្នឹង គឺលោកបានឆ្លើយថា បំណងគាត់គឺអ៊ីចឹងឯង។ ចង់បានអ៊ីចឹង! ដូច្នេះតាម ចម្លើយរបស់លោកនេះ គឺថា ប៉ុល ពត ចង់យក ឃួន ដាវីដ មកធ្វើការជាមួយនឹងគាត់ តើខ្ញុំនិយាយ អ៊ីចឹងត្រឹមត្រូវដែរឬទេ? ឬក៏ខ្ញុំនេះ បកស្រាយចម្លើយដែលលោកឆ្លើយហ្នឹងមិនត្រឹមត្រូវ?

**ឆ៖** បាទ នេះខ្ញុំនិយាយថា ប្រហែលអ៊ីចឹងមែនហើយបានជាគាត់សួរខ្ញុំអ៊ីចឹង។

[១០:៣១:៣៨]

**ស៖** បន្ទាប់មកលោកបន្តលើកឡើងទៀតថា "តាមការណែនាំរបស់គាត់ ខ្ញុំទៅជួប ប៉ង់ ហើយ ប្រាប់ ប៉ង់ ទៅតាមនុ៎ង។ ដោយសារតែខ្ញុំដឹងថា ប៉ង់ គឺជាអ្នកគ្រប់គ្រងបញ្ជាជន។ ខ្ញុំមិនដឹងថា តើ ប៉ង់ យកបញ្ជាជនមកពីណានោះទេ ក៏ប៉ុន្តែខ្ញុំគិតថា ប៉ង់ ប្រហែលជាស្គាល់បុគ្គលរូបនុ៎ង។ ដូច្នេះហើយខ្ញុំបាន ប្រាប់ ប៉ង់ អំពីបុគ្គលរូបហ្នឹងដើម្បីឲ្យ ប៉ង់ ផ្តោតការយកចិត្តទុកដាក់។ ក៏ប៉ុន្តែបំណងរបស់ ប៉ង់ នុ៎ងគឺ មិនបានច្បាស់លាស់នោះទេ"។ ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះ។ តើលោកចាំថាលោកបានឆ្លើយហ្នឹង ទាំងអស់ហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** សូមអរគុណ។ ឪពុកមារបស់លោក ប៉ុល ពត ប្រាប់លោកឲ្យទៅពិនិត្យមើលថា "តើ បុគ្គលរូបហ្នឹងពិតជាពូកែដែរឬទេ?" ហេតុអ្វីបានជាលោកទៅជួប ប៉ង់ វិញ មិនទៅជួបបុគ្គលរូបនោះ ផ្ទាល់? ហេតុអ្វីបានជាលោកមិនទៅមើលប្រវត្តិរូបរបស់បុគ្គលរូបហ្នឹងដោយផ្ទាល់ ហើយត្រឡប់ទៅ រាយការណ៍ជូន ប៉ុល ពត វិញ? ហេតុអ្វីបានជាលោកចាំបាច់ទៅតាមរយៈ ប៉ង់ ទៅជួប ប៉ង់ធ្វើអី?

[១០:៣៣:២៤]

**ឆ៖** នេះជារបៀបរបបធ្វើការ។ គឺខ្ញុំមិនអាចចូលទៅក្រសួងណាផ្សេងទៀតបានទេ នរណា ទទួលខុសត្រូវកន្លែងណា ដូចជា ប៉ង់ ទទួលខុសត្រូវខាងបឹងត្របែកអ៊ីចឹង គឺខ្ញុំត្រូវតែធ្វើតាមរយៈ ប៉ង់។ បើខ្ញុំទៅ គឺមានបញ្ហាហើយ ទៅតែឯង។ គឺច្បាប់អ៊ីចឹងតែម្តង ជំនាន់នុ៎ងបាទ។

**ស៖** ឃួន ដាវីដ នេះក្រោយមកបាត់ខ្លួន។ តាមអ្វីដែលលោកដឹងនោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើលោកមានរាយការណ៍បញ្ហាហ្នឹងជូនឪពុកមារបស់លោក ប៉ុល ពត ដែរឬទេ?

**ឆ៖** បាទ ដូចជាខ្ញុំមិនបានរាយការណ៍ទេ ពីព្រោះពេលនោះសភាពការណ៍ស្មុគស្មាញច្រើន គាត់បែបភ្លេចរឿងហ្នឹងហើយ។

[១០:៣៤:៥៧]

**ស៖** យើងនឹងចូលចំណុចហ្នឹងបន្តិចទៀតនេះ ក៏ប៉ុន្តែយើងអាចនិយាយថា ប៉ង់ ក៏បានដឹងផងដែរថា ប៉ុល ពត នោះចង់ឲ្យ ឃួន ដាវីដ នោះមានសុវត្ថិភាព ហើយអាចឲ្យ ប៉ុល ពត ហ្នឹងយកមកប្រើប្រាស់បាន អ៊ីចឹងដែរឬទេ?

**ឆ៖** នេះ គឺលោកសួរតាមខ្ញុំយល់ ឬមួយតាម ប៉ុល ពត យល់ ខ្ញុំអត់ទាន់ច្បាស់បាទ ស្តាប់អត់ច្បាស់បាទ។

**ស៖** បាទ ខ្ញុំអធ្យាស្រ័យត្រង់ចំណុចហ្នឹង។ ប៉ុល ពត បានប្រាប់លោកឲ្យទៅតាមមើលបុគ្គលហ្នឹង បន្ទាប់មកដោយសារតែលោកត្រូវតែធ្វើតាមខ្សែសង្វាក់បញ្ជា គឺលោកទៅតាម ទៅពិនិត្យ និងសួរតាមរយៈ ប៉ង់ ហើយទៅប្រាប់បញ្ហាហ្នឹង ប៉ង់ ដឹងផងដែរ។ ដូច្នេះចំណុចហ្នឹង តើត្រូវដែរឬទេ? លោកឯកភាពដែរឬទេ?

**ឆ៖** បាទ ខ្ញុំឯកភាព។

[១០:៣៦:១៩]

**ស៖** នៅពេលដែលលោកទៅនិយាយជាមួយ ប៉ង់ តើលោកមានបានឲ្យ ប៉ង់ ដឹងដែរឬទេថា គឺឪពុកមារបស់លោក ប៉ុល ពត ឲ្យលោកនេះទៅធ្វើការសាកសួរអំពីបុគ្គលហ្នឹង តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានប្រាប់។

**ស៖** សូមអរគុណ។ ដូច្នេះ ប៉ង់ នោះប្រាកដជាដឹងហើយ ថា ប៉ុល ពត មិនចង់ឲ្យមានអ្វីកើតឡើងចំពោះ ឃួន ដាវីដ ទេនៅពេលនោះ តើមែនដែរឬទេ?

**ឆ៖** តាមមើលទឹកចិត្តគាត់ គឺដូច្នេះ។

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនបើយើងអាចមើលបន្តទៀត ក៏ប៉ុន្តែយើងដល់ម៉ោងពេលសម្រាកហើយ ខ្ញុំសូមអធ្យាស្រ័យពីរបីនាទីទៀត។ ប្រសិនមើលឯកសារ E3/459។ ឯកសារជាភាសាខ្មែរ លេខ ERN គឺ00204100 ទៅដល់ 01, បារាំង 00524354, អង់គ្លេសលេខ ERN គឺ00223596 គឺនៅត្រង់ទំព័រ៣ នៃភាសា

អង់គ្លេស។ ប្រសិនបើខ្ញុំទទួលបានការអនុញ្ញាត គឺខ្ញុំសូមអនុញ្ញាត គឺខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះយកឯកសារនេះបញ្ជូនលោកសាក្សី ហើយសូមឲ្យបញ្ចាំងនៅលើអេក្រង់ផងដែរ ដោយសារតែវាអាចជាសារៈប្រយោជន៍ និងប្រយោជន៍សម្រាប់យើងទាំងអស់គ្នា។ សូមអរគុណ។

[១០:៣៨:៣៦]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ប្រសិនបើលោកមើលទំព័រដែលខ្ញុំបញ្ជាក់អម្បាញ់មិញឲ្យបានប្រុងប្រយ័ត្ន និងហ្មត់ចត់នោះ ខ្ញុំមិនដឹងត្រង់ទំព័រណាទេជាភាសាខ្មែរ ក៏ប៉ុន្តែមានចំណុចគូសអក្សរពណ៌ឲ្យលោកមើលហើយ។ “ឧទាហរណ៍ មានពេលមួយនោះ ប្រហែលចុងឆ្នាំ១៩៧៨ ខ្ញុំបានតាមលោក អៀង សារី ទៅកន្លែងបឹងត្របែក បានជួបជាមួយសាស្ត្រាចារ្យម្នាក់ ជាអ្នកចេះដឹង។ គាត់ជាខ្មែរមកពីប្រទេសបារាំង”។ ចំណុចនេះ គឺលោកបានលើកឡើងថា លោកទៅជួបបុគ្គលនោះដោយផ្ទាល់តែម្ដងនៅបឹងត្របែក។ ដូច្នេះវាខុសនឹងចំណុចមុនបន្តិច។

[១០:៣៩:២៤]

“ក្រោយពីបានជួប ខ្ញុំបានរាយការណ៍ជូនទៅឪពុកមារបស់ខ្ញុំ ប្រាប់គាត់ថា មនុស្សនេះជាអ្នកចេះដឹង និងស្លូតបូត។” ដូច្នេះត្រង់ចំណុចនេះ គឺលោករាយការណ៍ជូនឪពុកមារបស់លោក ជាជាងគាត់សួរលោក។ បន្ទាប់មកលោកនិយាយទៀតថា “ប៉ុន្តែខ្ញុំត្រឡប់មករកគាត់នៅកន្លែងនោះម្ដងទៀត ស្រាប់តែមនុស្សនោះបាត់ខ្លួន មិនដឹងទៅកន្លែងណា។ ឈ្មោះ ហ៊ីង អ៊ុន ដែលជាអ្នកគ្រប់គ្រងនៅទីនោះបានបញ្ជាក់ថា ជននោះត្រូវបានក្រុម ប៉ង់ យកទៅបាត់ហើយ។ ពេលខ្ញុំបានប្រាប់ឪពុកមាខ្ញុំវិញថា មនុស្សនោះបាត់ហើយ ស្រាប់តែគាត់នៅស្ងៀមធ្មឹងតែម្ដង”។ លោក សាក្សីតើលោកឃើញចំណុចដែលខ្ញុំអានអម្បាញ់មិញដែរឬទេ?

**ឆ៖** បាទ ឃើញ។

**ស៖** ដូច្នេះ ចំណុចនេះ គឺយើងឃើញថា លោកបានប្រាប់ចៅក្រមស៊ើបអង្កេតថា លោកបានត្រឡប់ទៅប្រាប់ឪពុកមារបស់លោក អំពីការបាត់ខ្លួនរបស់បុគ្គលរូបនេះ ដែលជាសាស្ត្រាចារ្យ។ ដូច្នេះចំណុចនេះ គឺលោកបានទៅធ្វើអ៊ីចឹង ហើយប្រហែលជាលោកអាចរៀបរាប់ចំណុចនេះ បានត្រឹមត្រូវជាងអ្វីដែលលោករៀបរាប់នៅក្នុងថ្ងៃនេះ ឬក៏យ៉ាងម៉េច? ថាដែលលោកបាននិយាយថា ថាលោកមិនដែលទៅប្រាប់ឪពុកមារបស់លោក ប៉ុល ពត វិញទេ តែចំណុចនេះ លោកបានទៅប្រាប់?

[១០:៤១:២០]

**ឆ៖** ខ្ញុំបានគិតពិចារណាម្តងទៀត ខ្ញុំឃើញថា ពេលដែលប្រថុចញ៉ុចនៅពេលដែលវៀតណាមចូលនុំង ខ្ញុំហាក់ដូចជាគិតថា មិនបានជម្រាបគាត់អំពីរឿង ដាវីដ នោះបាត់ទេ។ ពាក្យសម្តីនេះប្រហែលជាខ្ញុំ វៀតណាមចូលហើយៗ គាត់មានសួរខ្ញុំ ដាវីដ អីរឿងរ៉ាវ ដាវីដ អីពេលឆ្នាំដែលគាត់សួររកសួរអីហ្នឹង ខ្ញុំអាចនិយាយពេលដែលវៀតណាមចូលហើយទេ។ នេះខ្ញុំច្រឡំហើយ ខ្ញុំច្រឡំដែលគេហៅថា-- ប៉ុន្តែខ្ញុំបាននិយាយ ប៉ុន្តែនិយាយពេលណាហ្នឹង ខ្ញុំវាៗភ្លេចអ៊ីចេះវាយូរហើយណាស់លោក។ ពាក្យហ្នឹងខ្ញុំបាននិយាយមែន ខ្ញុំអាចនិយាយអាពាក្យក្រោយនេះ ខ្ញុំអាចនិយាយពេលវៀតណាមចូលហើយ។ បាទសូមលោកជ្រាបបាទ។

**ស៖** សំណួរចុងក្រោយ មុនពេលដែលលោកប្រធានប្រកាសសម្រាកសម្រាប់វគ្គព្រឹកនេះ។ តើពូរបស់លោក ប៉ុល ពត បានដឹងដែររទេថា ប៉ង់ នេះទទួលខុសត្រូវ ឬក៏ជាអ្នកធ្វើឲ្យមានការបាត់ខ្លួនលើរូប ឃួន ដាវីដ? តើអ៊ីចឹងដែរឬទេ?

[១០:៤២:៥៥]

**ឆ៖** ខ្ញុំមិនដឹងគាត់យល់យ៉ាងណាដែរ។ ខ្ញុំមិនបានសួរគាត់ពីរឿងហ្នឹងទេ។

**ស៖** ខ្ញុំមិនសួរអំពី ប៉ុល ពត គិត ឬក៏យល់យ៉ាងម៉េចនោះទេ។ តើ ប៉ុល ពត ដឹងថា លោកបានជម្រាប ប៉ង់ ថា ឃួន ដាវីដ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ប៉ង់ នេះបានបាត់ខ្លួនហើយ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

បាទ ខ្ញុំយល់អំពីខ្សែគំនិតរបស់លោក កាណាវាស ក៏ប៉ុន្តែមានសំណួរមួយដែលត្រូវចោទឡើងពីព្រោះថា ខ្ញុំ-- សាក្សីហាក់ដូចជា ច្របូកច្របល់ទាក់ទងកាលបរិច្ឆេទ គឺថាពុំមានកាលបរិច្ឆេទច្បាស់លាស់នៅពេលដែលទស្សនកិច្ចនៅបឹងត្របែកនោះ ហើយពេលដែលមានធ្វើរបាយការណ៍អីនោះ ហើយក៏គ្មាន ហើយនៅពេលដែល ឃួន ដាវីដ នោះដកចេញ នាំចេញពីបឹងត្របែកនោះ ក៏ពុំមានកាលបរិច្ឆេទដែរ ហើយខ្ញុំអង្កាល់នោះ នៅ ប៉ង់ ជាប្រធាននោះ។ អ៊ីចឹង ដើម្បីបំភ្លឺនោះ សូមឲ្យសាក្សីឆ្លើយឲ្យច្បាស់លាស់ជាងនេះ ប្រហែលជាយើងអាចបំភ្លឺអំពីរយៈកាល ដែលព្រឹត្តិការណ៍ទាំងអស់នោះបានកើតឡើង មុននឹង ដើម្បីដំណើរការទៅបានល្អ។ សូមអរគុណ។

[១០:៤៤:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

សូមអញ្ជើញលោក កាណាវាស! សូមរៀបចំនូវសំណួរឲ្យបានជាក់ច្បាស់ ពីព្រោះការឈ្លោចសួរដេញដោលនេះមានច្រើន ឡប់ចុះឡប់ឡើងអ៊ីចឹង គឺថាវាអាចមានបញ្ហាហើយសូមឲ្យការគិតគូរដល់កាលបរិច្ឆេទនៃបញ្ហានីមួយៗដែលកើតមានឡើងពាក់ព័ន្ធនឹងសំណួរនេះជាការល្អ ដើម្បីងាយនៅក្នុងការឲ្យសាក្សីហ្នឹង អាចតាមដាន តាមទាន់ ហើយនិងអាចឆ្លើយតបបាន ពីព្រោះម្យ៉ាងទៀត អង្គហេតុនេះកើតឡើង៤០ឆ្នាំមកហើយ បើប្រៀបធៀបជាមួយនឹងពេលបច្ចុប្បន្ននេះវាក្បែរៗនឹង៤០ឆ្នាំហើយ មនុស្សតិចតួចណាស់ដែលមានការ បញ្ញាស្មារតី ដែលអាចចងចាំនូវហេតុការណ៍លម្អិតនៅក្នុងស្ថានភាពនៃគម្លាតពេលវេលារហូតដល់៣០ ទៅ ៤០ឆ្នាំនោះ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមថ្លែងអំណរគុណចំពោះការសង្កេត និងយោបល់របស់សហព្រះរាជអាជ្ញា។ ខ្ញុំហៀបនឹងសួរបញ្ជាក់អំពីកាលបរិច្ឆេទរួចទៅហើយ។ ខ្ញុំគិតថានៅ ខ្ញុំត្រូវការរយៈពេលប្រហែលជាប៉ុន្មាននាទីទៀត ក៏ប៉ុន្តែយើងគួរតែឈប់សម្រាកសិនទៅ បើសិនជាឲ្យខ្ញុំបន្តអាចត្រូវប្រាំនាទីទៀតឯណោះ។

សូមអរគុណ។

[១០:៤៦:០២]

**ប្រធានអង្គជំនុំ៖**

បាទឥឡូវហ្នឹងពេលវេលាសមល្មមសម្រាកហើយ អង្គជំនុំជម្រះសម្រាក២០នាទី ចាប់ពេលនេះតទៅរហូតដល់ម៉ោងដប់មួយប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម! លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ សម្រាប់រយៈពេលសេសសល់ពេញមួយថ្ងៃនេះតែម្តង ប៉ុន្តែសូមចូលរួមដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ សំណើនេះធ្វើឡើងដោយសារបញ្ហាសុខភាពដែលលោកមិនអាចអង្គុយបាននៅទីនេះ។ អាស្រ័យហេតុនេះ សូមលោកសម្រេចតាម

សំណើ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ សូមអង្គុយចុះ!

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ ដោយមានបញ្ហាសុខភាព មិនអាចអង្គុយតាមដានផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះបាន។

[១០:៤៧:២០]

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ទៅបន្តតាមដានកិច្ចដំណើរការសវនាការ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ចាប់ពីពេលនេះតទៅរហូតដល់ចប់នៅរសៀលនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី អៀង សារី ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការ ដែលធ្វើឡើងដោយលោក អៀង សារី គឺចុះហត្ថលេខា ឬផ្តិតម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៩ នាទី ដល់ម៉ោង ១១:០៥ នាទី)*

[១១:០៥:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម។ អរុណសួស្តីដល់អស់លោក លោកស្រី ក៏ដូចជាសាធារណជនទាំងអស់។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី មុនដែលយើងឈប់សម្រាក គឺយើងនិយាយពីឯកសារ E3/459 ត្រង់ទំព័រដែលយើងកំពុងតែនិយាយគ្នាមុននោះ។ ហើយខ្ញុំសូមឲ្យលោកជួយបញ្ជាក់ពីរបីចំណុច។ ទីមួយថា តើលោកសាស្ត្រាចារ្យដែលលោកលើកឈ្មោះឡើងនោះ ឃួន ដារីដ នោះ ឬលោកនិយាយអំពី ឃួន ដារីដ ឬក៏លោកនិយាយសាស្ត្រាចារ្យណាផ្សេងទៅវិញ?

[១១:០៧:១៨]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំនិយាយពី ឃួន ដារីដ នេះឯង។

**ស៖** តាមការដែលលោកចងចាំបានល្អប្រសើរបំផុតនោះ ថាតើនៅពេលណាដែលលោកបានទៅជួប ប៉ង់ ដើម្បីប្រាប់គាត់ថាពូ ប៉ុល ពត នេះបានប្រាប់លោកអំពីឈ្មោះ ឃួន ដារីដ នេះ តើនៅពេលណា?

**ឆ៖** ពេលដែលខ្ញុំបាននិយាយពីរឿងសាស្ត្រាចារ្យ ឃួន ដារីដ នេះប្រាប់ពូរបស់ខ្ញុំ ប្រហែលជាជួប ប៉ង់ ហើយ ដោយចៃដន្យទេ ខ្ញុំក៏និយាយប្រាប់ ប៉ង់ ទៅ។ ប្រហែលជាមួយអាទិត្យ ពីរអាទិត្យអី ប៉ុណ្ណឹងទេ តាមមើលបាទ។

**ស៖** តើលោកនៅចាំបានទេ ប្រហែលជាក្នុងខែណា? ខ្ញុំដឹងហើយថាវាជាង៣០ឆ្នាំមកហើយ ប៉ុន្តែលោកអាចនៅចាំខែបានទេ ក្នុងខែណាដែរ?

**ឆ៖** ខ្ញុំមិនចាំខែទេ។ ខ្ញុំអាចចាំបានថា ប្រហែលជាកន្លះខែមុន ប៉ង់ បាត់ខ្លួន។

**ស៖** តាមការដែលលោកចាំបានល្អបំផុតនោះ តើលោកដឹងទេថានៅពេលណាដែល ប៉ង់ បាត់ខ្លួន?

**ឆ៖** ខ្ញុំមិនចាំពេលវេលានោះច្បាស់ទេ។ ខ្ញុំចាំថាវៀតណាមចូលមកជិតក្រុងភ្នំពេញមែនទែនហើយ។

[១១:០៩:៥០]

**ស៖** នៅពេល ប៉ង់ បាត់ខ្លួន តើលោកបានទទួលព័ត៌មានទេ? មានគេប្រាប់លោកអំពីការបាត់ខ្លួនរបស់ ប៉ង់ នេះដែរទេ?

**ឆ៖** ខ្ញុំអត់បានព័ត៌មានអីពី ប៉ង់ បាត់ខ្លួនទេ។ ពេលនោះ ស្មុគស្មាញណាស់ មន្ទីរក្រសួងរបស់ខ្ញុំគិតតែគិតគូរតែរៀបចំ អំពីការត្រៀមរៀបចំជម្លៀស។

**ស៖** តើនេះជាការប្រកាសផ្លូវការឬយ៉ាងណា ដែលការបាត់ខ្លួនរបស់ ប៉ង់ ហ្នឹងគឺថាមានការប្រកាសជាផ្លូវការ ឬយ៉ាងណា?

**ឆ៖** មិនមានការប្រកាសជាផ្លូវការទេ។

**ស៖** អ៊ីចឹងម៉េចបានជាលោកដឹងថា គាត់បាត់ខ្លួន?

**ឆ៖** បាត់ខ្លួនគឺអត់ឃើញមានការទាក់ទងមកមន្ទីរអីផ្សេងៗ ឃើញរាល់ថ្ងៃដែល ប៉ង់ នៅ ប៉ង់ ជិះម៉ូតូ ចួនកាលក៏ជិះឡានទៅ ដើរទៅនេះទៅនោះអី។ ឯមន្ទីរខ្ញុំអត់ឃើញទាល់តែសោះ អត់ឃើញ ប៉ង់ មកសោះ។

[១១:១១:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក! លោកៗ កាណាវាស អាចផ្អាកបន្តិចសិន។

សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសោកស្ដាយណាស់ដែលបានកាត់ផ្ដាច់លោក កាណាវាស ក៏ប៉ុន្តែខ្ញុំចង់ទាក់ទាញអារម្មណ៍ភាគីទាំងអស់លើការដែលនៅថ្ងៃទី២៤ មេសា កន្លងមកនេះ សហព្រះរាជអាជ្ញាបានដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ ដែលលេខឯកសារគឺ IS5.14 ជាឯកសារ១នេះ

ជាចម្លើយសារភាពរបស់ ប៉ង់ ហើយទាក់ទងនឹងកាលបរិច្ឆេទដែលមានចង្អុលបង្ហាញនោះ គឺថាមានកាលបរិច្ឆេទទីមួយនៅក្នុងរបាយការណ៍ចម្លើយរបស់ ប៉ង់ នោះគឺថ្ងៃទី២០ ឧសភា ឆ្នាំ១៩៧៨។ ហើយកាលបរិច្ឆេទចុងក្រោយដែលមាននៅក្នុងឯកសារដែលយើងមានការបកប្រែជាភាសាបារាំង ហើយបកភាសាអង់គ្លេសហើយ គឺថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៨។ បាទ នេះសំខាន់ណាស់ចំពោះយើង ពីព្រោះថាបាននិយាយជាច្រើនដងថា ការចាប់ខ្លួនរបស់ ប៉ង់ នោះប្រហែលជាកើតមានឡើងនៅពេលវៀតណាមជិតមកដល់ គឺថានៅចុងឆ្នាំ១៩៧៨។ ដូច្នេះខ្ញុំគិតថា ប្រហែលជាមានភាពចម្រូងចម្រាស ពីព្រោះថាយើងមានភស្តុតាងដែលយើងអាចយកជាមូលដ្ឋានបាន។

[១១:១៣:៣៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ សូមអញ្ជើញបន្តលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណចំពោះការកត់សម្គាល់របស់អង្គជំនុំជម្រះ។ គឺថាខ្ញុំមិនអាចបង្ហាញឯកសារនេះបានដោយសារតែខ្ញុំចង់សួរនាំមុខសាក្សី ដោយប្រើប្រាស់ឯកសារនេះទេ។ តាមការពិត គឺថានៅក្នុងយុត្តាធិការនេះ គឺថាខ្ញុំអាចប្រើប្រាស់ឯកសារណាមួយក៏បានដែរ ដែលមាននៅក្នុងសំណុំរឿង ដើម្បីឲ្យសាក្សីគាត់ពិនិត្យមើលចំពោះចម្លើយរបស់គាត់នោះ។ ខ្ញុំស្នាក់ស្ទើរចំពោះការបង្ហាញឯកសារនោះ ប៉ុន្តែដោយសារមានការបង្ហាញពីលោកចៅក្រម គឺថាពេលនេះគឺថា ពេលនេះខ្ញុំនឹងអាចមានលទ្ធភាព មានផ្លូវមួយដើម្បីបង្ហាញឯកសារនេះបានហើយ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី យើងមានឯកសារជាចម្លើយសារភាព គឺចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨។ ឥឡូវយើងត្រឡប់ទៅមើលចម្លើយសារភាពនេះ ដែលមានរយៈពេលជាង៣០ឆ្នាំមកហើយ។ គឺខ្ញុំចង់និយាយនៅពេល ប៉ង់ គាត់ឈប់មកចូលកន្លែងលោកក្នុងប្រហែលជាខែឧសភា ឆ្នាំ១៩៧៨។

ខ្ញុំសូមសួរសំណួរទៅសាក្សីម្តងទៀត យើងខ្ញុំទើបតែបានដឹងថាមានចម្លើយសារភាពមួយ ជាចម្លើយសារភាពរបស់ ប៉ង់ ក្រោយពេលគេចាប់ខ្លួនគាត់ ហើយកាលបរិច្ឆេទនៃចម្លើយសារភាពនេះ គឺចម្លើយសារភាពលើកទីមួយនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨។ ចម្លើយសារភាពដែលយើងបានដឹងនេះ គឺថាជាចម្លើយសារភាពដែលគេសួរចម្លើយ ប៉ង់ នៅពេលដែលគាត់ត្រូវបានគ្រប់គ្រង និងទុកនៅមន្ទីរ

ស-២១ ក្រោមការគ្រប់គ្រងរបស់ ឌុច។ ដូច្នេះតាមរយៈចម្លើយសារភាពនេះ គឺថា ប៉ង់ យ៉ាងហោចណាស់ក៏ក្នុងថ្ងៃទី២៨ ខែឧសភា ៧៨ គឺថាគាត់លេងមានឃើញការដើរហើរតាមដងផ្លូវនៅទីក្រុងភ្នំពេញទៀតហើយ។ ដូច្នេះ ខ្ញុំចង់ឲ្យលោកគិតទៅដល់ពេលនោះ ហើយប្រាប់មកខ្ញុំវិញថាតើចំណុចនេះវាស៊ីចង្វាក់គ្នាទៅនឹងការចងចាំរបស់លោកដែរឬទេ? ដោយសារថា លោកមិនអាចចាំថ្ងៃ ចាំខែបានដោយសារវាមានរយៈពេលយូរមកហើយ?

[១១:១៧:៤០]

**ធ៖** ខ្ញុំបានចងចាំថា ពេលដែលវៀតណាមចូលមក គឺខ្ញុំអត់បានឃើញ ប៉ង់ តែប៉ុណ្ណោះបាទ។ អីៗដែលគេសួរចម្លើយ សួរអីឯណា ចងចាំអី ខ្ញុំអត់ទេ ខ្ញុំអត់បានដឹងទេបាទ។ ខ្ញុំបានដឹងរួមៗអ៊ីចឹងតែម្តង។ គឺថា ប៉ង់ ដែលធ្លាប់គ្រប់គ្រងខ្ញុំហ្នឹង គឺថាអត់បានឃើញនៅពេលដែលវៀតណាមជិតចូលភ្នំពេញហើយ។ បាទ តែប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែល ប៉ង់ ឈប់ចេញចូលកន្លែងលោកនោះ ថាតើមានអ្នកណាម្នាក់មកពីមន្ទីរសន្តិសុខហ្នឹង មកបង្ហាញណែនាំលោកថា គាត់ហ្នឹងគឺជាអ្នកជំនួសមុខតំណែង ប៉ង់ នេះដែរឬទេ?

**ធ៖** អត់មានទេ។ មន្ទីរណា ដូចថាមន្ទីរខ្ញុំនេះ គេប្រាប់ថាម្ចាស់ការខ្លួនឯងទៅ។ រៀបរយបងប្អូនយ៉ាងម៉េច ទៅណាទៅជាមួយគ្នាទាំងអស់។ គេប្រាប់តែបុណ្ណឹងឯង គឺតាមរយៈបង អៀង សារី តែប៉ុណ្ណោះ។

[១១:១៩:១៧]

**ស៖** ប៉ុន្មានថ្ងៃក្នុងសប្តាហ៍មុននោះ គឺថាលោកនិយាយថា ប៉ង់ ចេញចូលកន្លែងលោក។ ប៉ង់ យកមនុស្សមកទុកនៅក្រសួងការបរទេស ហើយ ប៉ង់ ក៏យកមនុស្សចេញពីក្រសួងការបរទេស។ ដូច្នេះ សំណួររបស់ខ្ញុំគឺ ក្រោយពេល ប៉ង់ បាត់ខ្លួនទៅ ថាតើមានមនុស្សណាម្នាក់មកជំនួសមុខតំណែង ប៉ង់ ដើម្បីយកមនុស្សមកផ្ញើនៅក្រសួងការបរទេស ហើយនិងយកមនុស្សចេញទៅពីក្រសួងការបរទេសវិញដែរឬទេ?

**ធ៖** ខ្ញុំបានជម្រាបរួចហើយ គឺអត់ទេ។

[១១:២០:០០]

**ស៖** លោកពិតជាបានបញ្ជាក់ថា មានពេលមួយនោះ គឺបឹងត្របែក និងកន្លែងផ្សេងទៀត មានច្រាំងចំរេះ ខ្ញុំសូមអធ្យាស្រ័យក្រែងខ្ញុំអានឈ្មោះនេះមិនបានចំច្បាស់ ខ្ញុំខំព្យាយាមអានដែរ។ គឺនៅពេល

ដែលច្រាំងចំរេះបានផ្ទេរមកឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសនោះ។ តើមានពេលផ្ទេរអ៊ីចឹងមែនទេ?

**ឆ៖** បាទ មានពេលផ្ទេរ។

[១១:២០:៥៦]

**ស៖** តាមដែលខ្ញុំយល់សក្ខីកម្មរបស់លោក មុននឹងច្រាំងចំរេះត្រូវផ្ទេរមកឲ្យនៅស្ថិតនៅក្រោមក្រសួងការបរទេស គឺកន្លែងនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ប៉ង់ មុននោះ។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅពេលដែលកន្លែងនោះផ្ទេរមកឲ្យស្ថិតនៅក្រោមក្រសួងការបរទេស លោកអាចគិតទៅដល់ពេលនោះបានទេ លោកអាចចាំទេ ថាតើ ប៉ង់ មានជិះម៉ូតូ ឬក៏ប្រើប្រាស់មធ្យោបាយណាមួយនៅជុំវិញភ្នំពេញទេនៅពេលនោះ?

**ឆ៖** បាទ មាន។

**ស៖** ក្នុងចម្លើយនៅចំពោះមុខលោក គឺឯកសារ E3/459 គឺនៅត្រង់ទំព័រដែលខ្ញុំបានបង្ហាញលោកពីមុននោះ គឺលោកបញ្ជាក់ថា "គឺមួយខែមុននឹងវៀតណាមចូលមកគ្រប់គ្រងទីក្រុងភ្នំពេញ គឺមន្ទីរបឹងត្របែកត្រូវបានដាក់ឲ្យស្ថិតនៅក្រោមក្រសួងការបរទេស។ ប៉ុន្តែពេល ប៉ង់ គ្រប់គ្រងមន្ទីរបឹងត្របែកនោះគឺថា មានបញ្ហាចម្រូងចម្រាសច្រើនជាងពេលនេះ"។ លោកឃើញត្រង់ទំព័រនេះទេ?

[១១:២២:៥៣]

**ឆ៖** បាទ ខ្ញុំឃើញ។ ប៉ុន្តែមុនក្រសួងការបរទេសទៅកាន់កាប់បឹងត្របែកនោះ ខ្ញុំមើលទៅប្រហែលជាមិនដល់មួយខែទេ ខ្ញុំថាពីរអាទិត្យអីហ្នឹង។ ប្រហែលពីរអាទិត្យ មិនដល់មួយខែទេបាទ វាប្រថុចញ៉ុចណាស់ពេលនុ៎ង បាទ។

**ស៖** តើលោកអាចពន្យល់បានទេ ថានៅពេល ប៉ង់ ធ្វើការគ្រប់គ្រងកន្លែងទាំងពីរនេះ គឺបឹងត្របែក និងច្រាំងចំរេះ ថាតើការគ្រប់គ្រងរបស់គាត់នៅកន្លែងទាំងពីរនេះ នៅអង្គភាពទាំងពីរនេះបន្ថែមទៅលើតួនាទីគាត់ជាប្រធានមន្ទីរ៨៧០ រួមទាំងមុខងារទទួលបន្ទុកខាងផ្នែកសន្តិសុខផង។ ថាតើលោកអាចពន្យល់បានទេ តើ ប៉ង់ អាចចាត់ចែង និងគ្រប់គ្រងកន្លែងទាំងនេះបានដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំនិយាយសរុបទៅ គឺតាមចិត្តគាត់។

**ស៖** ដោយយោងទៅលើគោលការណ៍ថា មិនត្រូវដឹងរឿងអ្នកដទៃ គិតតែពីរឿងខ្លួនឯងនោះ ដើម្បីឱ្យយល់ឱ្យបានច្បាស់ ថាតើអំណាច និងការទទួលខុសត្រូវរបស់គាត់ចំពោះកន្លែងទាំងពីរដោយរបៀបណានោះ?

[១១:២៥:០៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរចុងក្រោយនេះសាជាថ្មីម្តងទៀត ពីព្រោះទំនងជាសាក្សីស្តាប់អត់យល់ទេ។ ដោយសារមិនដឹងថា សួរគាត់រឿងអីទេ ជាសំណួរ ឬក៏គ្រាន់តែនិយាយប្រាប់គាត់។ ជាភាសាខ្មែរពិតជាពិបាកក្នុងការយល់ថា តើជាសំណួរឬក៏គ្រាន់តែនិយាយប្រាប់គាត់ទេ?

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ថាតើលោកធ្លាប់មានការនិយាយគ្នា សន្ទនាគ្នាជាមួយ ប៉ង់ ដើម្បីសួរគាត់អំពីការទទួលខុសត្រូវពិតប្រាកដរបស់គាត់-- របស់ ប៉ង់ ទៅលើកន្លែងទាំងពីរនេះដែរឬទេ? គឺនៅមុនហ្នឹង កន្លែងទាំងពីរនេះ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស លោកមានការសន្ទនាជាមួយ ប៉ង់ ដែរឬទេ?

[១១:២៦:០៨]

**លោក សាឡុត បាន៖**

**ឆ៖** តាមខ្ញុំចាំ បង អៀង សារី ថា "បឹងត្របែក ឬក៏ជាច្រាំងចំរេះ ប៉ង់ គេថា ឲ្យ ហុង ឯងហ្នឹងទទួលខុសត្រូវហើយ"។ តែប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមឱ្យលោកស្តាប់សំណួររបស់ខ្ញុំ ហើយឆ្លើយមកសំណួរខ្ញុំ។ ខ្ញុំសួរថា តើលោកធ្លាប់មានដែលបាននិយាយគ្នាជាមួយនឹងអតីតមេរបស់លោក ថ្នាក់លើរបស់លោក គឺ ប៉ង់ ដើម្បីសួរ ប៉ង់ ថាតើ ប៉ង់ ហ្នឹងមានការទទួលខុសត្រូវពិតប្រាកដហ្នឹងយ៉ាងណាដែរទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** នៅពេលដែលអង្គភាពទាំងពីរនេះ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមក្រសួងការបរទេស តើលោកមានបានទទួលឯកសារអ្វីពី ប៉ង់ ដែរឬទេ? ដើម្បីមើលឱ្យបានច្បាស់ថា តើប៉ង់ ធ្វើអ្វីខ្លះ?

ចាត់ចែងកន្លែងទាំងពីរដោយរបៀបណាខ្លះ នៅពេលដែល ប៉ង់ មានសិទ្ធិអំណាចគ្រប់គ្រងកន្លែងទាំងពីរនេះ?

[១១:២៧:៤៥]

**ផ៖** ខ្ញុំមិនបានមានទទួលឯកសារអីដែល ប៉ង់ មកគ្រប់គ្រងកន្លែងទាំងពីរនេះទេបាទ។

**ស៖** ខ្ញុំសូមប្តូរប្រធានបទហើយ ប្រហែលជានេះជាប្រធានបទចុងក្រោយរបស់ខ្ញុំហើយ។ ខ្ញុំសូមនិយាយអំពីឈ្មោះ កុយ ធួន វិញម្តង។ គឺចម្លើយ-- និងចម្លើយសារភាពរបស់គាត់។ លោកស្គាល់ កុយ ធួន ដែរទេ?

**ផ៖** បាទ ស្គាល់។

**ស៖** លោកស្គាល់គាត់តាំងពីមុនថ្ងៃ១៧ មេសា ៧៥ ដែរឬទេ?

**ផ៖** ១៧ មេសា បាទ ស្គាល់មុន។

**ស៖** តើលោកបានជួប កុយ ធួន ដោយរបៀបណា? លោកជួបក្នុងមុខងារ ឬក៏សមត្ថកិច្ចរបស់លោកដោយរបៀបណាដែរ?

[១១:២៩:១៥]

**ផ៖** ខ្ញុំបែក-- ខ្ញុំធ្វើការងារបែកនៅភ្នំពេញដោយគេចាប់ខ្ញុំដាក់គុកពីរឿងធ្វើបាតុកម្មប្រឆាំងនឹងចក្រពត្តិអាមេរិក ដោយបាចខិត្តប័ណ្ណ។ ខ្ញុំបានជួប កុយ ធួន នៅក្រចេះ។

**ស៖** ក្នុងឆ្នាំណាដែរ?

**ផ៖** ក្នុងឆ្នាំ១៩៦៧ ឬ៦៨ បាទ។

**ស៖** ហើយចន្លោះពីឆ្នាំ៧៧ និងឆ្នាំ៧៨ តើលោកមានឱកាសបានទៅជួប កុយ ធួន ក្រៅពីពេលជួបនៅក្រចេះនោះដែរទេ?

**ផ៖** ខ្ញុំលែងបានជួបហើយ។

**ស៖** តើលោកមានដែលបានជួបគាត់នៅក្នុងព្រៃទេ នៅពេលដែលលោកនៅ នៅឯទីនោះ?

**ផ៖** ខ្ញុំធ្លាប់បានជួបនៅព្រៃម្តង នៅឯរតនគិរី។

[១១:៣០:៤៨]

**ស៖** នៅពេលនោះ គិតរហូតមកដល់ខែមេសា ឆ្នាំ៧៥ លោកដឹងថា តើ កុយ ធួន មានតួនាទីមានឋានៈជាអ្វីទេ?

**ផ៖** ខ្ញុំដឹង តួនាទីគាត់ថា ភូមិភាគ ប្រធានភូមិភាគ បាទ។

**ស៖** ភូមិភាគណាដែរ?

**ផ៖** ភូមិភាគនែ៎! មានកំពង់ធំ កំពង់ចាម មិនដឹងភូមិភាគអីទេ ភ្លេចហើយបាទ មិនដឹងគេហៅភូមិភាគីអីទេ បាទ។ កំពង់ធំ កំពង់ចាម សៀមរាប បាទ កាលនុ៎ង មានបីហ្នឹង។ ភូមិភាគឧត្តរអីចឹងបាទ គេហៅជំនាន់ហ្នឹងបាទមើលទៅ។

**ស៖** តើតួនាទីនេះជាតួនាទីមួយដ៏សំខាន់របស់គាត់ដែរឬយ៉ាងក្នុងឋានៈគាត់ជាមេភូមិភាគហ្នឹង?

**ផ៖** បាទ ខ្ញុំដឹងថាគាត់សំខាន់នៅក្នុងភូមិភាគហ្នឹងបាទ។

**ស៖** ដូច្នេះ តើពូ ប៉ុល ពត ស្គាល់ និងដឹងអំពី កុយ ធួន នេះដែរឬទេក្នុងអំឡុងពេលហ្នឹង?

**ផ៖** ខ្ញុំអត់បានដឹងថា ស្គាល់របៀបម៉េច របៀបម៉េចទេបាទ អត់ដឹងទេបាទ។

[១១:៣២:៤៦]

**ស៖** ក្រោយភ្នំពេញបែកនៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ តើលោកដឹងថា កុយ ធួន នោះធ្វើអ្វីដែរ? តួនាទីអ្វីដែរ?

**ផ៖** ខ្ញុំដឹងតែនៅតែប្រធានភូមិភាគដដែល។

**ស៖** ថាតើលោកដឹងដែរឬទេថា ក្នុងពេលណាមួយនោះមុនពេលចាប់ខ្លួនគាត់ តើគាត់ហ្នឹងមានកាន់នាទីអ្វីក្រៅពីប្រធានភូមិភាគដែរឬទេ?

**ផ៖** ខ្ញុំអត់ដឹងដែរ។

[១១:៣៣:៣៧]

**ស៖** តើលោកដឹងថា លោកនុ៎ង គាត់មានជាប់ពាក់ព័ន្ធជាមួយនឹងក្រសួងដែរឬទេ?

**ផ៖** តើក្រសួងណា៎?

**ស៖** ខ្ញុំសួរលោក តើលោកដឹងដែរឬទេ ចន្លោះឆ្នាំ៧៥ រហូតដល់ពេលចាប់ខ្លួនគាត់នោះ តើគាត់ហ្នឹងមានកាន់ការងារ ឬក៏ពាក់ព័ន្ធជាមួយនឹងក្រសួងណាមួយក្នុងទីក្រុងភ្នំពេញដែរឬទេ?

**ផ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** តើលោកដឹងថា គាត់ជាសមាជិកនៅក្នុងមន្ទីរមជ្ឈិមដែរទេ?

**ផ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** តើលោកដឹងថាគាត់ហ្នឹងជាប់ទាក់ទងជាមួយនឹងអ្វីដែលយើងហៅថា ថ្នាក់លើដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

[១១:៣៥:០០]

**ស៖** តើលោកដឹងថាគាត់មានពាក់ព័ន្ធការងារ ឬក៏ជាសមាជិកនូវគំនិតដែលយើងហៅថា អង្គការនោះដែរឬទេ?

**ឆ៖** ប្រហែលជានៅក្នុងនុំងដែរ ជាក្នុងអង្គការដែរ។

**ស៖** ដូច្នេះ នៅពេលដែលលោកនិយាយឆ្លើយអម្បាញ់មិញនេះ តើលោកនិយាយស្មាន ឬក៏និយាយអ្វីដែលលោកដឹងដោយផ្ទាល់?

**ឆ៖** បាទ ខ្ញុំនិយាយស្មាន ពីព្រោះគេអត់មានប្រាប់ថា អ្នកនេះជាស្អីៗទេ។ ប៉ុន្តែបើដឹងថា ភូមិភាគគេប្រាប់ខ្ញុំ នែ៎ ឋានៈឋានុក្រមអីផ្សេងៗឲ្យគេសរសេរប្រាប់ ខ្ញុំថា អ្នកនេះឈ្មោះនេះៗ ខ្ញុំអត់មានទេ។ ដូច្នេះ ភូមិភាគខ្ញុំដឹង ថាអ្នកហ្នឹងទទួលខុសត្រូវភូមិភាគប៉ុណ្ណេះៗ ខ្ញុំដឹង។ ដូច្នេះ ខ្ញុំដឹងថា ជាក្នុងអង្គការ ធ្វើការក្នុងអង្គការដែរបាទ។

[១១:៣៦:២០]

**ស៖** សូមអរគុណ។ នៅពេលដែលគេចាប់ខ្លួនគាត់ ក្រោយមកលោកបានធ្លាប់ឮចម្លើយសារភាពរបស់គាត់ តើគេចាត់ទុកគាត់នៅពេលនោះ ជាបុគ្គលសំខាន់ដែរឬទេ?

**ឆ៖** ខ្ញុំបាន-- ខ្ញុំអត់បានវិភាគអីទាំងអស់។ ខ្ញុំត្រូវតែនៅស្ងៀម រឿងគេ គេដឹង រឿងឯង ឯងដឹង។

**ស៖** ខ្ញុំសូមសួរសំណួរម្តងទៀត។ នៅពេលដែលលោកលេចឮការចាប់ខ្លួនគាត់ ហើយលោកឮអំពីចម្លើយសារភាពរបស់គាត់ ដែលចម្លើយសារភាពនោះ គឺក៏បានឲ្យលោកដឹងផងដែរ។ តាមអ្វីដែលលោកដឹង តើ កុយ ធួន នេះជាកម្មាភិបាលសំខាន់មួយរូបដែរឬទេ?

**ឆ៖** ពេលដែលអានឯកសារ កុយ ធួន អារម្មណ៍ខ្ញុំគិតឃើញថា ទេ កាលដែលគាត់ធ្វើការជាមួយខ្ញុំដូចមិនអីចឹង។ ស្រាប់ដល់គេសរសេរចោទមកប្រកាន់ វាខុសពីដែលគាត់ធ្វើការជាមួយខ្ញុំធ្លាប់ជួបគ្នានុំង នៅព្រៃនៅអីហ្នឹងបាទ។ ដូច្នេះ ខ្ញុំមិនសន្និដ្ឋានថា នរណាថាត្រូវ ថាខុសយ៉ាងម៉េច ខ្ញុំក៏អត់បានសន្និដ្ឋានដែរបាទ។

[១១:៣៨:១៤]

**ស៖** សូមអរគុណ។ លោកបានចង្អុលបញ្ជាក់ថា ឯកសារ ឬក៏ចម្លើយសារភាពនេះគឺ គេអាន

ឲ្យលោកស្តាប់ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ? លោកមិនដែលឃើញចម្លើយសារភាពនេះដោយផ្ទាល់ទេ ក៏ប៉ុន្តែលោកបានដឹងខ្លឹមសារ នៃចម្លើយសារភាពនោះ ដោយសារមានបុគ្គលណាម្នាក់គេអានឲ្យលោកស្តាប់ តើត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ក្រោយពីលោកបានស្តាប់នូវខ្លឹមសារ ចម្លើយសារភាពនោះ តើលោកមានអារម្មណ៍អ្វីជាក់លាក់ដែរឬទេនៅពេលនោះ? ក្រោយពីលោកគិតឃើញថា នរណាគេជា កុយ ធួន និងចម្លើយសារភាពនោះ?

**ឆ៖** *(មីក្រូហ្វូនមិនដំណើរការ)* បាទ ខ្ញុំមិនអាចឆ្លើយម្តងទៀតបានទេ ចម្លើយជាលាក់លាក់ដូចខ្ញុំបានថាប៉ុណ្ណឹងគឺ ខ្ញុំថា ជាក់លាក់ហើយ។

[១១:៣៩:៣៧]

**ស៖** នៅពេលដែលលោកនិយាយថា លោកឆ្លើយជាក់លាក់នោះ តើលោកមានន័យយ៉ាងម៉េច? លោកសប្បាយចិត្ត លោកមានអារម្មណ៍ក្រៀមក្រំ ភ្ញាក់ផ្អើល ឬក៏មានអារម្មណ៍យ៉ាងម៉េចដែរ នៅពេលដែលដឹងអំពីព័ត៌មានហ្នឹងនោះ?

**ឆ៖** មានអារម្មណ៍ច្របូកច្របល់ មិនដឹងរឿងហ្នឹងជារឿងអ្វី គិតមិនយល់ គិតមិនលេច។ ហេតុផលនេះមកពីណាមកពីណឹស្មុគស្មាញក្នុងខ្លួន។

**ស៖** ហេតុអ្វីបានជាលោកច្របូកច្របល់?

[១១:៤០:២៨]

**ឆ៖** បានជាខ្ញុំច្របូកច្របល់ ធ្វើការជាមួយខ្ញុំវាល្អ ឃើញថាល្អត្រឹមត្រូវ តែដល់គេចម្លើយមកគេថាមិនល្អ វាផ្ទុយនឹងគំនិតខ្ញុំដែលឃើញគាត់ផ្ទាល់នោះ។ ដូច្នេះ ខ្ញុំច្របូកច្របល់ហើយពេលហ្នឹង។

**ស៖** សូមអរគុណ។ នៅថ្ងៃ២៤ ខែមេសា ឆ្នាំ២០១២ លោកបានបញ្ជាក់ត្រង់ទំព័រ៥១នៃប្រតិចារឹកជាភាសាអង់គ្លេស ត្រង់ម៉ោង [១៤:២៦:១៦], លោកបានឆ្លើយថា “ក្រោយពីអានចម្លើយសារភាពលោក អៀង សារី និងខ្ញុំ រួមទាំងអ្នកផ្សេងផងដែរមានការភ័យខ្លាច”។ តើលោកចាំថាលោកបាន ឆ្លើយចម្លើយដូច្នេះនៅចំពោះមុខតុលាការ ហើយលោកបានស្បថដែរឬទេ?

[១១:៤១:៥២]

**ឆ៖** ខ្ញុំបានឆ្លើយ ប៉ុន្តែខ្ញុំមិនបានស្បថទេ។

**ស៖** សូមអរគុណ។ តើលោកនៅតែរក្សាសម្ដីហ្នឹងដដែលដែរឬទេ? ប្រកាន់សម្ដីហ្នឹងដែរឬទេ ដែលថាលោក និង អៀង សារី រួមទាំងលោកផងដែរ មានការភ័យខ្លាច?

**ឆ៖** បាទ។

**ស៖** ហេតុអ្វីបានជាលោកខ្លួនឯងក្លាយជាមានការភ័យខ្លាចដូច្នេះក្រោយពីបានស្ដាប់ដូចខ្លឹមសារចម្លើយសារភាពរបស់លោក កុយ ធួន នោះ?

**ឆ៖** ខ្ញុំឆ្លើយម្ដងរួចទៅហើយ ខ្ញុំអត់ឆ្លើយតទៀតទេ។

**ស៖** នៅពេលនោះ តើលោកបានដឹងដែរឬទេ ចម្លើយសារភាពរបស់គេនោះ គេទាញដោយរបៀបណាដែរ ទាញយកដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំមិនដឹងក្បួនខ្នាតគេទាញអីៗទេ។ ខ្ញុំមិនបានវិភាគដល់ការទាញចម្លើយហ្នឹងយ៉ាងម៉េចៗទេ ខ្ញុំគិតអត់ដល់បាទ។

[១១:៤៣:៣៦]

**ប្រធានអង្គជំនុំ៖**

មេធាវីសូមចាប់អារម្មណ៍ពីការផ្អែកលើមូលដ្ឋាននៃចម្លើយសារភាព យកមកសួរដេញដោលសាក្សី! អង្គជំនុំជម្រះកត់សម្គាល់ឃើញសំណួរចុងក្រោយប៉ុន្មានសំណួរនេះ គឺផ្អែកលើចម្លើយសារភាពយកមកសួរដេញដោល គោលបំណងបង្ហាញចម្លើយសារភាពគឺគ្រាន់តែកំណត់អំពីកាលបរិច្ឆេទនៃការចាប់ខ្លួនអ្នកដែលត្រូវមានពាក់ព័ន្ធទៅនឹងកំណត់ហេតុប៉ុណ្ណោះ។ មិនអាចយកខ្លឹមសារនៃកំណត់ហេតុចម្លើយសារភាពដែលបានមកពីទារុណកម្មយកមកដេញដោលសាក្សីនោះទេ។

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសួរលោកសាក្សីថាតើគេទាញយកចម្លើយសារភាពដោយរបៀបណានោះតែប៉ុណ្ណោះ។ ក៏ប៉ុន្តែខ្ញុំនឹងព្យាយាមចូលទៅដល់ចំណុចហ្នឹងតែម្ដង។

[១១:៤៤:៤៥]

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** ចម្លើយរបស់លោក លោកបានបញ្ជាក់ថាលោកបានដឹងថា សុន សេន ទទួលបន្ទុកខាងផ្នែកសន្តិសុខ។ ចំណុចចម្លើយនេះ គឺសរសេរនៅក្នុងឯកសារលេខ E3/415 តើលោកនឹកឃើញថាបានឆ្លើយអ៊ីចឹងដែរឬទេ? ដែលលោកឆ្លើយថាលោក សុន សេន នោះទទួលបន្ទុកខាងផ្នែកសន្តិសុខ?

**ឆ៖** បាទ ខ្ញុំឆ្លើយអ៊ីចឹងបាទ។

**ស៖** តើលោកអាចនឹកឃើញឡើងវិញដែរឬទេ តាំងពីពេលនោះមក ថាតើ សុន សេន មានជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួន ឬក៏ការទាញយកចម្លើយសារភាពរបស់ កុយ ធួន ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេបាទ។

**ស៖** នៅក្នុងឯកសារដដែលអម្បាញ់មិញនេះ ខ្ញុំយោងឯកសារត្រង់ទំព័រ 0035751 បារាំងគឺ 00405457 អង់គ្លេសគឺ 00361014 ត្រង់ទំព័រ៧ នៃភាសាអង់គ្លេស នៃឯកសារភាសាអង់គ្លេស។ នៅត្រង់ឯកសារនេះ លោកបានលើកឡើងថា "ពាក់ព័ន្ធទៅនឹង កុយ ធួន ខ្ញុំដឹងថាមានបុគ្គលម្នាក់បានបញ្ជូនឯកសារមួយចំនួនទៅក្រសួងការបរទេស ដែល សួង សុគន្ធ ជាអ្នកកាន់កាប់ ក៏ប៉ុន្តែឯកសារនោះបានបាត់អស់ហើយ។ តាមអ្វីដែលខ្ញុំដឹង ឯកសារ-- ខ្លឹមសារនៅក្នុងឯកសារនោះគឺប្រឌិតតែប៉ុណ្ណោះ។ ខ្ញុំមិនបានឯកសារ-- ដឹង-- មិនបានឯកសារ កុយ ធួន និង ហ៊ូ នឹម ទេ គឺមានបុគ្គលម្នាក់អានឲ្យខ្ញុំស្តាប់។ ខ្ញុំយល់ឃើញថា ចម្លើយសារភាពនេះ ខ្ញុំមិនជឿថាអ្នកទាំងនោះធ្វើអ៊ីចឹងទេ"។ តើលោកឃើញចំណុចដែលខ្ញុំអាននេះដែរឬទេលោក?

[១១:៤៧:១៣]

**ឆ៖** បាទ ឃើញ។

**ស៖** លោកបានលើកឡើងឈ្មោះ ហ៊ូ នឹម តើលោកស្គាល់គាត់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់បានស្គាល់។

**ស៖** តើលោកដឹងនាទីរបស់គាត់នៅពេលនោះធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថាគាត់នៅក្នុងរណសិរ្ស។

**ស៖** តើលោក នៅពេលដែលលោកនិយាយអំពីរណសិរ្ស តើលោកសំដៅលើរយៈកាលមុនឆ្នាំ៧៥ ឬក៏ចន្លោះ៧៥ ដល់៧៩។ តើរយៈកាលណាមួយដែរ?

**ឆ៖** តាំងពី៧៥ ដល់៧៩ ខ្ញុំគិតថាគាត់ធ្វើការរណសិរ្សបាទ។

**ស៖** សូមអរគុណ។ តើលោកដឹងការងាររបស់លោក ហ៊ូ នឹម ហ្នឹង ធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** ខ្ញុំសូមសួរលោក ក្នុងរយៈកាលនុ៎ង តើលោកមានការធ្វើទំនាក់ទំនងជាមួយនឹងលោក ហ៊ូ នឹម ដែរឬទេ?

[១១:៤៩:១២]

**ឆ៖** អត់មានទាល់តែសោះ។

**ស៖** នៅពេលនេះ លោកនិយាយអំពី ហ៊ូ នឹម រួមជាមួយនឹង កុយ ធួន ខ្ញុំចង់សួរលោកថា តើលោកដឹងដែរឬទេ ថាចម្លើយសារភាពរបស់ ហ៊ូ នឹម ក៏បានអានឲ្យលោកស្តាប់ផងដែរ នៅពេលនោះ?

**ឆ៖** គាត់ចង់សួរយ៉ាងណា?

**ស៖** ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ លោកបាននិយាយថាចម្លើយសារភាពរបស់ កុយ ធួន គឺគេបានអានឲ្យលោកស្តាប់។ ដូច្នេះ តើចម្លើយសារភាពរបស់កម្មាភិបាលផ្សេង អ្នកផ្សេងនោះ បានអានឲ្យលោកស្តាប់ដែរឬទេ? ឬក៏មានតែចម្លើយសារភាពរបស់ កុយ ធួន តែប៉ុណ្ណោះដែលគេអានឲ្យលោកស្តាប់?

[១១:៥០:២១]

**ឆ៖** តាមខ្ញុំចាំ ដូចជាមានចម្លើយតែ កុយ ធួន មួយ។

**ស៖** តើលោកនឹកឃើញដែរឬទេថា មានអ្វីសរសេរខ្លះ? មានការចោទប្រកាន់យ៉ាងម៉េចខ្លះដែលគេចោទប្រកាន់អំពីការប្រព្រឹត្តិបទល្មើសនៅក្នុងចម្លើយសារភាពនោះនោះ?

**ឆ៖** បាទ ខ្ញុំភ្លេចអស់ហើយ។

**ស៖** តើលោកដឹងដែរឬទេ មានសេចក្តីណែនាំណាមួយ បានបញ្ជូនជាដំណឹងអំពីការចាប់ខ្លួន កុយ ធួន រួមទាំងការចោទប្រកាន់លើ កុយ ធួន ឲ្យគេឯងដឹងផងដែរនោះ?

**ឆ៖** បាទអត់បានដឹងទេ។

[១១:៥១:៣៤]

**ស៖** តើចម្លើយសារភាពរបស់ កុយ ធួន និងបទល្មើសដែលគេចោទប្រកាន់ទៅលើរូបគាត់នោះមានការផ្សព្វផ្សាយឲ្យគេដឹងជាទូទៅដែរឬទេនៅពេលនោះតាមអ្វីដែលលោកចាំនោះ?

**ឆ៖** *(និយាយមិនបើកមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ចាំឆ្លើយនៅពេលដែលក្បាលមីក្រូដំណើរការ។

**លោក សាឡុត បាន៖**

**ឆ៖** បាទ អត់បានដឹងទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ក៏ប៉ុន្តែតាមការដែលលោកចាំល្អបំផុតនោះ យ៉ាងហោចណាស់នៅក្នុងការងារក្រសួងការបរទេសនោះ គឺយើងឃើញថា មានការពិភាក្សាអំពីខ្លឹមសារដែលមាននៅចម្លើយសារភាពរបស់លោក កុយ ធួន នោះ។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ ខ្លឹមសារបានស្តាប់បាន ដូចខ្ញុំជម្រាបអំមិញអ៊ីចឹង។ ឥឡូវហ្នឹងវាភ្លេចអស់ហើយ។

[១១:៥៣:០២]

**ស៖** ការពិភាក្សានៅពេលនោះ ពិភាក្សាលើអ្វីដែរ ហើយតើមានបានពិភាក្សាថាតើចម្លើយសារភាពរបស់ កុយ ធួន នោះគាត់ឆ្លើយអ្វីខ្លះ?

**ឆ៖** ពេលនោះពិភាក្សាគ្នាហ្នឹងគឺថា ដូចថា ខ្ញុំចាំព្រាលៗទេ ហ្នឹងខ្ញុំខំឆ្លើយទៅទេនេះ។ ដូចថាអានហើយទៅ សួរជារួមថា បងប្អូនណាមានពាក់ព័ន្ធអីទេ? ជាមួយនឹងបង កុយ ធួន ទេ? អាហ្នឹងឆ្លើយទៅ។ យើងអធ្យាស្រ័យ បើឆ្លើយ កុំឲ្យបង្កប់អ្វីដែលជាការខូចខិល ដែលយើងឃើញហើយ យើងអានមើលឃើញ កុយ ធួន ខូចខិលអ៊ីចេះអ៊ីចុះអីសីលធម៌។ ខ្ញុំឃើញតែពាក្យសីលធម៌ហ្នឹងហើយច្បាស់ជាងគេ ឯអីៗទៀតអីណា ទាក់ទងអីណាអីណីអីខ្ញុំមិនដឹងទេ។ តើមានខូចខិលសីលធម៌អីអ៊ីចឹងៗទេ? មានពាក់ព័ន្ធទៅ មិនមានទោស មិនមានពៃរ៍អីទេ។ ពីព្រោះកាលហ្នឹងវាមានអាប្រាំបួនជាន់ហើយ។ ដូច្នេះវាធូរដែរ។ សូមជម្រាបប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែលគេលើកឡើងអំពីការខូចខិលសីលធម៌ តើលោកនឹកឃើញដែរឬទេ ថាតើ កុយ ធួន បាននិយាយសារភាពអំពីការខូចខិលសីលធម៌ដែរឬទេ?

[១១:៥៥:១២]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៥:៣៦]

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ ព្រោះសំណួរនេះ គឺពាក់ព័ន្ធយក ដកស្រង់នូវខ្លឹមសារនៃចម្លើយសារភាពមកដេញដោលសាក្សី ដែលច្បាប់ហាមឃាត់។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើលោកដឹងថាមានពាក្យរហិចរហៀង ពាក្យចចាមអារ៉ាម អំពីការខុសសីលធម៌របស់លោក កុយ ធួន មុនពេលដែលគាត់ឆ្លើយសារភាព ឬក៏មុនពេលគេចាប់ខ្លួនគាត់ដែរឬទេ គឺក្នុងពេលដែលគាត់ជាប្រធានភូមិភាគឧត្តរនៅពេលនោះ?

**លោក សាឡុត បាន៖**

**ឆ៖** អត់មានទេ។

[១១:៥៦:២៧]

**ស៖** លោកបានជម្រាបយើងខ្ញុំថា នៅពេល-- ក្រោយពេលដែលលោកស្ដាប់ខ្លឹមសារចម្លើយសារភាពហើយនោះ តាមអ្វីដែលខ្ញុំយល់ពីចម្លើយរបស់គាត់នោះ គឺលោកពិបាកនឹងជឿណាស់។ តើលោកអាចពន្យល់ទេ ហេតុអ្វីបានជាលោកមានការភ្ញាក់ផ្អើល ហើយមិនជឿរឿងរ៉ាវទាំងអស់នោះ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយនឹងសំណួរហ្នឹងទេ សំណួរច្រំដែល ហើយសំណួរដកស្រង់នូវខ្លឹមសារពាក់ព័ន្ធជាមួយនឹងចម្លើយសារភាពដែលបានមកពីទារុណកម្ម។

ទំនងជាមេធាវីអស់សំណួរហើយ ដែលជាសំណួរច្រំដែល ហើយសំណួរដកស្រង់ចេញពីខ្លឹមសារនៃចម្លើយសារភាពដូចជាដដែលៗ ច្រើនលើកច្រើនសាហើយ។ បើអស់ប្រាប់អស់សំណួរទៅមិនគប្បីប្រឹងប្រែងសួរឯណា នូវសំណួរណាដែលវាខុសឆ្គងជាមួយនឹងនីតិវិធីដូច្នេះទេ។

[១១:៥៧:៤០]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកនិយាយប្រាប់យើងខ្ញុំអំពីការភ័យខ្លាចគេឆ្លើយដាក់លោក ក្រោយពីលោកបានឃើញដឹងហេតុការណ៍នេះ បានន័យថា នៅពេលដែលគេយកខ្លឹមសារចម្លើយសារភាពរបស់ កុយ ធួន មកមកជជែកពិភាក្សានោះ។ តើករណីនេះធ្វើឲ្យលោកកាន់តែមានការភ័យព្រួយបារម្ភថា គេអាចឆ្លើយដាក់លោក ឬក៏មាននរណាម្នាក់អាចឆ្លើយដាក់លោកបាន តើអ៊ីចឹងដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំអាចនិយាយអ៊ីចេះ ពីមុនដែល ប៉ង់ ចាប់មនុស្សអាហ្នឹងខ្ញុំភ័យ។ ដល់យកចម្លើយ កុយ ធួន មកនិយាយ ហើយមានប្រាំបួន-- អំ ប្រាំពីរជាន់ប្រាំពីរអ៊ីរួចហើយ ឲ្យខ្ញុំមកនិយាយ ខ្ញុំអត់ភ័យទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកសាក្សី សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំអស់សំណួរហើយ ខ្ញុំមិនមានអ្វីសួរទៀតទេ។ លោកសាក្សីសូមអរគុណលោកច្រើន សូមថ្លែងអំណរគុណលោកដែលបានឆ្លៀតឱកាសមកផ្តល់សក្ខីកម្មនៅទីនេះ ហើយសូមជូនពរលោកឲ្យធ្វើដំណើរទៅវិញដោយសុវត្ថិភាព។ សូមអរគុណ។

[១១:៥៩:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលត្រូវសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសូមសម្រួលកន្លែងសម្រាកសម្រាប់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកពិសាថ្ងៃត្រង់ផង ហើយឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ ទាំងមេធាវីប្រឹក្សាផងនៅវេលាម៉ោងសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី ផេសមិន!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ នៅក្នុងដៃរបស់ខ្ញុំ គឺលិខិតជាលាយលក្ខណ៍អក្សរបោះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់កូនក្តីរបស់ខ្ញុំ។ កូនក្តីរបស់ខ្ញុំចង់សូមអនុញ្ញាតទៅបន្តតាមដានសវនាការនៅក្នុងបន្ទប់ខាងក្រោម។ សូមអរគុណ។

[១២:០០:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ សូមអនុញ្ញាតអង្គុយចុះ!

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍។ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយក្រុមមេធាវីការពារក្តីសន្យាថាខ្លួននឹងប្រគល់មកឲ្យអង្គជំនុំជម្រះ នូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការ។

[១២:០១:១៥]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដែលមានចុះហត្ថលេខាឬស្នាម-- ផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមបន្ទប់សវនាការនេះក្នុងរយៈពេលកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃ-- សម្រាប់រសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម ដោយទុកឲ្យ នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍។ ដោយឡែកបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះមុនម៉ោងដប់បី និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

កិច្ចដំណើរការសវនាការនៅរសៀលនេះ តាមរបៀបវារៈដែលបានគ្រោងទុក គឺដល់ពេលវេលាក្រុមមេធាវីការពារក្តី លោក នួន ជា ដែលនឹងមានឱកាសក្នុងការដេញដោល ចំពោះសាក្សី សាឡុត បាន។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ សូមគោរពជម្រាបសួរលោកសាក្សី។ ខ្ញុំមេធាវីរបស់លោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួន តិចទេ ប្រហែលជាបួនដប់សំណួរទេជូនទៅលោកសាក្សីដូចតទៅនេះ។

[១៣:៣២:៣៥]

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកសាក្សីបានចូលតស៊ូ ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាតាំងពីក្មេងមក ហើយតាំងពីឈប់រៀនមករហូត ជាពិសេសនៅពេលដែលលោកទៅនៅនិរតីក្នុងខេត្តរតនគិរី ជាមួយនឹងថ្នាក់ដឹកនាំធំៗ ដូចជាលោក ប៉ុល ពត ដែលត្រូវជាពូរបស់លោកសាក្សីបង្កើត។ ខ្ញុំចង់សួរថា ពេលដែលលោកទៅនៅជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាហ្នឹង លោកឃើញច្បាប់របស់បក្សហ្នឹងតឹងរ៉ឹងយ៉ាងណា? តើលោកអាចអត្ថាធិប្បាយជូនជម្រាបតុលាការបានទេ បើតាមប្រជាពលរដ្ឋដែលរស់នៅរហូតសព្វថ្ងៃ។ មានច្រើន ភាគច្រើនណាស់បាននិយាយថា កាលពីសម័យនុ៎ង មានការតឹងរ៉ឹង ច្បាប់ទម្លាប់តឹងរ៉ឹង ហើយនិងធ្វើឲ្យពិបាករស់នៅស្ទើសព្វបែបសព្វយ៉ាងអ៊ីចឹង។ តើរឿងហ្នឹងជារឿងពិត ឬយ៉ាងណា? សូមលោកជូនយោបល់តុលាការ។

[១៣:៣៤:០៤]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំបាទបានជួបលោក នួន ជា ម្តងម្កាលដែរនៅរតនគិរី មិនមែនភូមិភាគនិរតីទេ គឺភូមិភាគឦសានលោក បាទ ភូមិភាគឦសាន។ ការដែលខ្ញុំចូលបដិវត្តន៍នេះ មិនមែនខ្ញុំចូលដោយសម្ពាធរបស់លោកពូខ្ញុំ ប៉ុល ពត ឬមួយលោក នួន ជា ទេ។ សម្ពាធនេះ ជាសម្ពាធទីពីរទេ ឯសម្ពាធទីមួយនោះ គឺសម្ពាធដែលខ្ញុំយល់មកនោះ គឺថាលោកពូខ្ញុំ គាត់និយាយថា មុនទៅរៀនស្រុកបារាំង គ្រួសារមានដីឧទាហរណ៍ ១០ហិកតា ដល់មកពីស្រុកបារាំងវិញ ឃើញគ្រួសារអ្នកជិតខាងអស់ដីរលីង នៅសល់មិនដល់កន្លះហិកតាផង។ ពាក្យនេះហើយដែលខ្ញុំគិតថា អូ៎! ឲ្យខ្ញុំគិត។ ដល់មកដល់បានជួបលោកទាំងពីរ

ពិសេសនៅព្រៃ លោកពន្យល់ពីរឿងអីមុនគេ ដូចខ្ញុំបានជម្រាបអ៊ីចឹង លោកទាញសៀវភៅមក។ លោកឲ្យកាលនុ៎ងមិនមែនលោកឲ្យផ្ទាល់ទេ។ លោកឲ្យលោក ប៉ង់ ហ្នឹងហុចមកឲ្យខ្ញុំ គឺសៀវភៅ "សាមគ្គីជនជាតិក្រោមទង់បដិវត្ត"។ ពេលនោះបដិវត្តពេលនោះ គឺធ្វើអី? គឺដូចខ្ញុំបានជម្រាប អ៊ីចឹង ការពារទឹកដី គាំទ្រសម្ដេចតា រក្សាអព្យាក្រឹត្យភាព កុំឲ្យមានមូលដ្ឋានសឹកអាមេរិកាំងនៅស្រុកខ្មែរ។ ឯឯកសារជនជាតិនេះ គឺសាមគ្គីជនជាតិ ពីដើមឡើយខ្មែរច្រើនតែធ្វើបាបបងប្អូនជនជាតិ។ ដូច្នេះយើងរៀនឲ្យមានចេះសាមគ្គីគ្នា ជនជាតិអីក៏ដោយ។

[១៣:៣៦:៤៣]

តាមខ្ញុំយល់ជនជាតិទាំងនោះមាន២១ជនជាតិ ឬជាងនេះទៅទៀត។ ត្រូវតែសាមគ្គីគ្នា បើមិនចេះសាមគ្គីគ្នាទេ យើងកសាងខ្លួនក៏មិនល្អ ក្រុមយើងក៏មិនល្អ ភូមិយើងក៏មិនល្អ ស្រុកយើងក៏មិនល្អ ខេត្តយើងក៏មិនល្អ ជាតិយើងទាំងមូលក៏មិនល្អដែរ។ ដូច្នេះ ខ្ញុំសរុបទៅគឺថា មិនពិតទេដែលថា តឹងតែងនោះ។

**ស៖** សូមអរគុណលោកសាក្សី។ លោកបាននៅក្នុងជួរបដិវត្តន៍យូរ លោកបានស្គាល់លោក នួន ជា ច្បាស់លាស់ទេ ហើយលោកបានជួបច្រើនដងទេ?

**ឆ៖** ខ្ញុំបានជួបលោក ដូចជាច្បាស់លាស់ដែរ ច្បាស់លាស់បាទ ជួបលោកច្បាស់លាស់ ហើយច្រើនដង។ ប៉ុន្តែការជួបនេះ មិនមែនជួបធ្វើការងារអី ជាមួយខ្ញុំបន្តិចបន្តួចទេ អត់ទេ។

**ស៖** សូមអរគុណ។ លោកស្គាល់-- លោកអំមិញមានបាននិយាយថា លោកស្គាល់ច្បាស់លាស់ លោកបានជួបញឹកញាប់។ លោកស្គាល់អំពីចរិតកិរិយារបស់លោក នួន ជា ថាតើគាត់ជាមនុស្សកាចសាហាវ ឃោរឃៅ ក្នុងឋានៈគាត់ជាអ្នកដឹកនាំ ឬក៏គាត់ជាមនុស្សស្លូតបូត និយាយស្ដីចេះមានសីលធម៌មានចរិត ដូចថា អប់រំអីអ៊ីចឹង ឬក៏យ៉ាងម៉េច? សូមលោកនិយាយតាមដែលលោកចាំ ហើយលោកស្គាល់មក។

[១៣:៣៩:២០]

**ឆ៖** គឺលោកមានចរិតសាមគ្គីនឹងខ្ញុំល្អ។ បាទ អានេះ ខ្ញុំនិយាយតែខ្ញុំទេ។ លោកមិនមានធ្វើអី ឲ្យខ្ញុំអាក់អន់ស្រពន់ចិត្តដល់ខ្ញុំទេ គឺលោកមានតែពន្យល់ឲ្យចេះស្រលាញ់គ្នាក្នុងក្រុម បើមិនបានស្រឡាញ់មិនចេះស្រលាញ់គ្នាទេ អាដែងកិច្ចការពារបដិវត្តន៍មិនបានទេ ក្នុងន័យថាលោកអប់រំ លោកអប់រំឲ្យយល់អ្វីចំណេញដល់ការតស៊ូ ការធ្វើបដិវត្តន៍តែប៉ុណ្ណោះ។

**សះ** ចុះចំពោះអ្នកដទៃក្រៅពីខ្លួនលោកផ្ទាល់ លោកបានឃើញ ឬក៏លោកបានឮថាគាត់ហ្នឹងជាមានចរិតប្លែកពីលោក ដូចអ្នកដទៃទេ ឬក៏យ៉ាងម៉េច? អំចំពោះអ្នកដទៃ តើមានចរិតប្លែកទេ? កាចសាហាវ ឬក៏ថាឮគាត់ធ្លាប់ដល់ពេលដែលមានបញ្ហាផ្ទៃក្នុងកាន់តែខ្លាំងឡើង ឮថាគាត់អាចបញ្ជូនមនុស្សទៅឃុំឃាំង ឬទៅដាក់គុកដាក់អីអីចឹង មានដែលឮអីចឹងផងទេ?

**ផះ** បាទ ខ្ញុំមិនដែលឮទេ។

**សះ** សូមអរគុណ។ លោកតាំងពីលោកចាប់ផ្តើមចូលបដិវត្តន៍មក រហូតមក លោកដែលឮបក្សកុម្មុយនីស្តឥណ្ឌូចិនទេ?

[១៣:៤១:៥៥]

**ផះ** បាទ ខ្ញុំបានឮ។

**សះ** លោកអាចបរិយាយបន្តិចខ្លីទេ កុំវែងតិចតួចពីរឿងបក្សកុម្មុយនីស្តឥណ្ឌូចិនហ្នឹងជូនតុលាការស្តាប់បានទេ? តើបក្សហ្នឹងគេមានរចនាសម្ព័ន្ធគេយ៉ាងម៉េច? ឬក៏ថាការការងាររបស់បក្សកុម្មុនីយស្តឥណ្ឌូចិនមានអ្នកណាត្រួតត្រា ឬក៏ថាក្រុមគេហ្នឹងគឺយ៉ាងម៉េច? អាហ្នឹងលោកអាចមានប្រសាសន៍បានប៉ុន្មាន? សូមអញ្ជើញ។

**ផះ** មួយ ខ្ញុំបានអានសៀវភៅខ្លះដែរ សៀវភៅក្រៅពីសៀវភៅក្នុងអង្គការរបស់ខ្ញុំ គឺបក្សកុម្មុយនីស្តកម្ពុជាហ្នឹង។ ខ្ញុំអានសៀវភៅតាម-- ទិញតាមបណ្ណាគារអីខ្លះ។ ខ្ញុំឮបក្សកុម្មុយនីស្តឥណ្ឌូចិន។ ដល់ខ្ញុំពិចារណាទៅ ខ្ញុំឃើញថាបក្សនេះគឺមានទ្រឹស្តីដែលឈ្មោះ ហូ ជីមិញ ដែលមេបក្ស។ ដូច្នេះបក្សឥណ្ឌូចិននេះគឺមានបក្សវៀតណាមនេះ គឺជា១បងលើបក្សកម្ពុជា ហើយនិងបក្សឡាវ។

[១៣:៤៣:៥៣]

**សះ** លោកមិនអាចជម្រាបតុលាការពីរឿង អី១រចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តឥណ្ឌូចិនហ្នឹងបានទេ?

**ផះ** បាទ ខ្ញុំមិនអាចពន្យល់បានទេ។

**សះ** បាទ អរគុណណាស់។ លោកដែលឮពាក្យថា “មិត្តភាពរាប់ម៉ឺនឆ្នាំរវាងបក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាម” ទេ?

**ផះ** បាទ ខ្ញុំឮ។

**សះ** បើឮថា ពាក្យនេះមានន័យថាយ៉ាងម៉េច? អាចមានប្រសាសន៍ពន្យល់បានខ្លះៗទេ?

**ឆ៖** ក្នុងន័យនេះ ខ្ញុំមិនអាចពន្យល់បានទេ ដូចខ្ញុំបាននិយាយអំមិញហ្នឹង គឺថាបងគេហ្នង គឺថា ធ្វើបងគេម៉ាម៉ឺនឆ្នាំ មួយពាន់ឆ្នាំ អ៊ីចឹងបាទ មានន័យអ៊ីចឹងបាទ។

**ស៖** ខ្ញុំបង្វែរមកសួរសំណួរផ្សេងទៀត នៅថ្ងៃ១៥ ខែកញ្ញា ឆ្នាំ១៩៧៧ ពេលដែលលោក សុន សេន ទៅបំពេញបេសកកម្មនៅបូព៌ា មានន័យថា ទៅនៅ-- ទៅអ្នកលឿង។ តើលោកបានដឹងទេថា នៅពេលដែល សុន សេន ទៅបំពេញបេសកកម្មនោះមាននរណាជំនួសលោក សុន សេន? សូមទោស ខ្ញុំសូមបន្ថែម។ ពេលដែល សុន សេន ទៅបំពេញបេសកកម្មនៅបូព៌ាមាននរណាជាអ្នកជំនួសលោក សុន សេន ចំពោះក្រសួងទាំងមូលគឺក្រសួងការពារជាតិ ក្រសួងការពារជាតិ និងមន្ទីរសន្តិសុខទាំងឡាយ រួមទាំងមន្ទីរស-២១ ផងដែរនោះ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** លោកស្គាល់មន្ទីរស-២១ ទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ស្គាល់ទេ។

[១៣:៤៦:៥៦]

**ស៖** លោកបានស្គាល់ ឌុច ទេ? កាំង ហ្កេកអ៊ាវ ហៅ ឌុច?

**ឆ៖** បាទ ខ្ញុំស្គាល់ ពេលដែលយួនចូលស្រុកខ្មែរហើយ។

**ស៖** លោកមានដឹងថា លោក ឌុច គាត់ធ្វើអីទេ ពេលដែលបីឆ្នាំប្រាំបីខែហ្នឹង?

**ឆ៖** ខ្ញុំមិនបានសួរ ឌុច ទេ ប៉ុន្តែគេលួចខ្សឹបប្រាប់ខ្ញុំថា ហ្នឹងហើយប្រធានស-២១។

**ស៖** បើអ៊ីចឹងលោកអត់បានច្បាស់លាស់ជាមួយនឹងប្រវត្តិរបស់ ឌុច ទេណ៎?

**ឆ៖** បាទ។

**ស៖** មុខតំណែងរបស់លោកៗ សាក្សីជាអគ្គលេខាធិការក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ តើលោកបានដឹងរាល់រឿងដែលគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមប្រជុំ ឬការងារអ្វីធំៗដែលគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមបានធ្វើៗរួចមកហើយទេ លោកមានដែលបានទទួលជាឯកសារ ឬក៏គេប្រាប់ថាគេជំនុំរឿងអី គណៈអចិន្ត្រៃយ៍ក្តី គណៈមជ្ឈិមក្តី?

[១៣:៤៨:៣២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សំណួរនេះត្រូវបានសួរជាច្រើនលើកច្រើនសាទៅកាន់សាក្សីរូបនេះ រួចទៅហើយ ខ្ញុំគិតថានេះគឺជាសំណួរច្រំដែលលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សាក្សីមិនបាច់ឆ្លើយនូវសំណួរនេះទេ ដោយសារជាសំណួរច្រំដែល។ ហើយមេធាវីអាចតាំងសំណួរផ្សេងទៀត។

**លោក សុន អរុណ៖**

ខ្ញុំអំមិញសួរសំណួរនេះក្នុងន័យមួយដែលខ្ញុំចង់មានសំណួរបន្តភ្ជាប់ន័យខាងលើ។ អ៊ីចឹង ខ្ញុំយកសំណួរនេះពីដើមមក រួចពីហ្នឹងខ្ញុំសួរសំណួរហ្នឹង វាពាក់ព័ន្ធគ្នាសំណួរខ្ញុំខាងលើហ្នឹង។ តើលោកប្រធានអាចអនុញ្ញាតឲ្យខ្ញុំសួរបន្តសំណួរអំមិញទេ។

**ប្រធានអង្គជំនុំ៖**

សំណួរអំមិញសាក្សីមិនបាច់ឆ្លើយទេ ព្រោះសំណួរច្រំដែល។ លោកតាំងសំណួរណាក៏បានសំណួរផ្សេងទៀត។

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកសាក្សី កាលពីថ្ងៃទី២៥ ខែ០៤ ឆ្នាំ២០១២ លោកឆ្លើយប្រាប់ទៅខាងព្រះរាជអាជ្ញាថា ពេលលោកជូនអ្នកកាសែត ឬជនបរទេសទៅមូលដ្ឋាន ប្រជាជនតែងតែត្អូញថា ខ្វះបាយ ម្ហូបហូបមិនគ្រប់គ្រាន់ តើប្រជាជនរដ្ឋបានប្រាប់លោក-- ប្រជាជន ប្រជាពលរដ្ឋបានប្រាប់លោកសាក្សីថាមកពីហេតុអ្វីបានជាមិនមានបាយម្ហូបមិនគ្រប់គ្រាន់នោះទេ? ដែលមានប្រាប់ទេ? គ្រាន់តែប្រាប់ថាអ្អឺះ! ហូបមិនគ្រប់គ្រាន់ទេ ប៉ុន្តែហេតុយ៉ាងម៉េចបានជាមិនគ្រប់គ្រាន់ អត់ដែលមានបាន ដែលនិយាយប្រាប់លោកទេ?

[១៣:៥០:៤៣]

**លោក សាឡុត បាន៖**

**ឆ៖** មានរឿងជាច្រើន កន្លែងខ្លះទៅឮថា ខាងលើៗបញ្ជូនកំណាត់ទៅទាំងឡាន១ ស្រាប់តែកំណាត់នោះទឹកអាស៊ីតឆេះអស់ ធ្វើឲ្យ-- ធ្វើឲ្យកំណាត់នុំងឆេះអស់។ ខាងលើប្រាប់ថា ឲ្យមានអង្ករឲ្យ

មានរបបបបរមួយអាទិត្យយ៉ាងតិចក៏ម្ដង ក៏អត់បាន។ អ្នកខ្លះប្រាប់ខ្ញុំថា ស្រូវធ្វើបានច្រើនណាស់ មិនដឹងគេដឹកយកទៅណា។ ខ្លះប្រាប់ថា គេដឹកយកទៅត្បូង។ ខ្លះគេប្រាប់ថា គេដឹកយកទៅកើត។ ខ្លះគេប្រាប់ថា គេដុតស្រូវចោល។ ត្រង់នេះហើយ ដែលខ្ញុំបានដឹងតាមប្រជាជន ដូចថា យើងថាមាត់សេកមាត់ចាបអីទៅចុះ។ ជាក់ស្ដែងខ្ញុំមើលទៅឃើញអ៊ីចឹងមែន គ្នាអត់មែន។ ជាក់ស្ដែងទៅទៀត ឪពុកម្ដាយខ្ញុំ ក៏អត់បានអ្វីដែលហៅថា អង្ករពីលើមកថាឲ្យម្ហូបអីចេះបបរបាយអី ឬបង្អែម ឬអីអត់បានទេ អត់មានទេ។ ហ្នឹងហើយ ឪពុកមា ឪពុកធំរបស់ខ្ញុំដែលធ្លាប់ធ្វើការនៅក្នុងរោង ទៅជាបោសច្រាសអីអ៊ីចឹងទៅ គាត់អត់ទេ គាត់ថា គាត់អត់ៗ អន់ចិត្ត អន់ថ្លើមអីទេ រឿងបោសច្រាស បោសអី។ ក៏ប៉ុន្តែអង្ករមានហើយ ស្រូវមានហើយ អត់ឲ្យហូបគ្រប់គ្រាន់។ ត្រង់ហ្នឹងហើយដែលខ្ញុំឃើញនឹងភ្នែក និងឮគេថាដូច្នេះដែរ។

[១៣:៥៣:០៤]

**ស៖** ខ្ញុំសូមលោកសាក្សីបញ្ជាក់ខាងចុងអំមិញ ខ្ញុំឆ្លើយមកវិញ ខ្ញុំដូចជាមិនយល់ថា ឮគេប្រាប់ ឬក៏លោកដឹង សូមបញ្ជាក់អាហ្នឹងឲ្យច្បាស់បន្តិចមើល៍។ ហេតុអីបានជាយើងអត់មានម្ហូប អត់បាយ អត់មានម្ហូប អត់មានបាយ អត់មានអីគ្រប់គ្រាន់? លោកអាច តាមការលោកដឹងមក តាមការលោកជួបប្រទះមកផ្ទាល់ខ្លួនក្ដី ឬបងប្អូនក្ដីហ្នឹង មកពីហេតុអី?

**ឆ៖** រឿងនេះ ខ្ញុំដឹងហៅថា វាដឹងចុងកន្ទុយហើយទេ។ យើងៗជម្រាបពីសភាពការណ៍បានដឹងហេតុ ដឹងចុងកន្ទុយហើយទេ។ ខ្ញុំសួរមូលហេតុគេម៉េចអ៊ីចឹង? ខ្ញុំសួរដែរ ខ្ញុំឆ្ងល់ដែរ។ ខ្ញុំមិនជាប់នៅនឹងទេ ខ្ញុំមិនដឹង ខ្ញុំសួរ សួរបងប្អូន។ បងប្អូនគេឆ្លើយថា ឆ្លើយថាខ្លីមកប្រាប់ខ្ញុំថា យី! វាធ្វើនេះ វាធ្វើឲ្យខ្លោចហើយនេះ វាធ្វើឲ្យអង្ករយើងខ្លោច ឲ្យឆៅហើយ។ គេៗប្រាប់តែប៉ុណ្ណឹងឲ្យខ្ញុំបាទ។ គេអត់ប៉ានថាអីទៀតទេ។

[១៣:៥៤:៣៥]

**ស៖** ប៉ុន្តែលោកយល់ថា ជាក់ស្ដែងយ៉ាងម៉េចទេ ដែលគេថាដុតឲ្យខ្លោច?

**ឆ៖** ឥឡូវខ្ញុំមកវិភាគឥឡូវនេះ ដូចខ្ញុំបានជម្រាបអ៊ីចឹង។ អាហ្នឹងវាគេហៅថា ធ្វើឲ្យខូចហើយ ពួកដែលស្អប់ ពួកដែលមានគំនុំ គំនុំនឹងបដិវត្តន៍ ដែលរបបមួយៗដែលធ្វើយក្សណ៌ា វាបាក់ស្បាតណ៌ា តើវាខឹងយ៉ាងម៉េច? ឯមួយផ្នែកទៀត គេថាគេនេះ គេនឹងរំដោះឲ្យបានមុនខ្មែរក្រហមនេះ ដល់រំដោះទៅ វាក្រោយខ្មែរក្រហម តើគេរៀនយ៉ាងម៉េច? ដូច្នេះហើយរឿងហ្នឹងតាមមើលខ្ញុំមិននិយាយតទៅទៀតទេ។

**ស៖** លោកអាចបញ្ជាក់បាន ថាគេហ្នឹង អ្នកណាគេ? បញ្ជាក់ត្រង់ហ្នឹងបានទេ?

**ឆ៖** បាទ ខ្ញុំបញ្ជាក់អត់បានទេ។

[១៣:៥៦:១៣]

**ស៖** ខ្ញុំសូមបន្តទៅសំណួរបន្ទាប់ទៀត។ តើលោកសាក្សីដឹងអំពីនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង? តើក្នុងគោលបំណងយ៉ាងម៉េច? ពេលនោះគេមាននយោបាយ ឬការគិតគូរទុកជាមុនរួចស្រេចហើយទេ មុននឹងជម្លៀសប្រជាជនចេញពីទីក្រុង? ពីព្រោះអីលោកបាននៅជិតដិតជាមួយនឹងមេដឹកនាំជាន់ខ្ពស់បំផុត គឺលោកពូ ប៉ុល ពត។

**ឆ៖** បាទ ខ្ញុំសូមទោស ខ្ញុំបានឆ្លើយម្តងរួចហើយបាទ ខ្ញុំឆ្លើយពីរដងទៀតវិលវល់ហើយបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីត្រូវឆ្លើយនឹងសំណួររបស់មេធាវីនេះ ព្រោះគាត់ចង់បញ្ជាក់ឲ្យបានច្បាស់លាស់លើចំណុចនេះ វាជាចំណុចសំខាន់។

**លោក សាឡុត បាន៖**

**ឆ៖** ការដែលឲ្យប្រជាជនចេញពីភ្នំពេញ ខ្ញុំឮសូរបងប្អូនកងទ័ពនិយាយថា មានចារកម្មចក្រពត្តិអាមេរិកាំងច្រើនម៉ឺនណាស់ ជាប្រុសជាស្រ្តី បើកងទ័ពនេះចូលមកមិនយល់អំពីកិច្ចការរបស់ចារកម្មទេ វានឹងចូលអន្ទាក់របស់ចារកម្មហើយ។ ទីពីរទៀត ខ្ញុំឮកងទ័ពថា អាមេរិកមានផែនការចាញ់គេហៅថាមាន "ផែនការចាញ់" ខ្ញុំក៏មិនសូវដែរ គេហៅថា "ផែនការចាញ់"។ ទើបខ្ញុំមកនឹងយល់ក្រោយៗមកទៀតទេ ពេលដែលគេថាផែនការចាញ់ហ្នឹងខ្ញុំមិនទាន់យល់ទេ។ ផែនការចាញ់ គឺថាគេត្រៀមទម្លាក់គ្រប់បែកនៅក្រុងភ្នំពេញ។ ដូច្នេះនយោបាយត្រូវតែជម្លៀសចេញបាទ។ ខ្ញុំដឹងប៉ុណ្ណឹងបាទ។

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមអរគុណ។ ចុះចំពោះជនជាតិភាគតិចដូចជា ខ្មែរអ៊ីស្លាម ជនជាតិចិន ជនជាតិវៀតណាម។ល។ តើបក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយចំពោះជនទាំងនោះយ៉ាងម៉េច ដែលពេលបក្សកំពុងតែកាន់អំណាចនៅក្នុងទឹកដីខ្មែរយើង? លោកអាចដឹង អាចជម្រាបតុលាការបានទេ?

[១៣:៥៩:៥១]

**ឆ៖** ខ្ញុំដឹងជារួមថា ឯកសារដែលរៀន ជនជាតិក្រោមទង់បដិវត្តនេះ អ្វីៗក៏ដោយជាចាម ជាថ្លៃ ជាកួយ ជារ៉ដែ ជាកាចក់ អីក៏ដោយគឺត្រូវតែសាមគ្គីគ្នា ដើម្បីកសាងប្រទេសវៃចក្រពត្តិអាមេរិក។ នេះ

នយោបាយនេះ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ហើយការជាក់ស្តែង គឺអ៊ីចឹងនៅមុខខ្ញុំអត់មានឃើញធ្វើបាបអីបងប្អូនចាម អីទេ។ ព្រោះខ្ញុំមិនមានជាអ្នកធ្វើកងទ័ពនៅសមរភូមិមុខ។

**ស៖** សូមអរគុណ។ លោកសាក្សីលោកបានជម្រាបទៅតុលាការច្រើនប្រើពាក្យ "ស្មាន"។ ពាក្យ "ស្មាន"នេះ ថាលោកដឹងមិនច្បាស់ទេ។ នេះជាចម្លើយដែលលោកឆ្លើយទៅនឹងចៅក្រមព្រឹកថ្ងៃទី ២៦ ខែ០៤ ២០១២។ ខ្ញុំសួរថា ការងារលោកដែលលោកបានដឹង និងបានធ្វើ គឺត្រឹមតែថ្នាក់របស់លោក តែប៉ុណ្ណោះ តែដូច្នេះទេ។ លោក-- សូមទោស! លោកបាន លោក ដែលលោកបានដឹង និងបានធ្វើ គឺត្រឹមតែឋានៈរបស់លោកប៉ុននុ៎ងទេ លោកអត់អាចធ្វើការងារណាដែលខ្ពស់ជាងឋានៈរបស់លោកទេ។ អ៊ីចឹង ឬមិនមែនទេ?

[១៤:០១:៤៤]

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** អរគុណ។ ចុះអ្នក ក្រសួងដទៃៗទៀត ស្ថាប័នដទៃៗទៀត ក្រៅពីកន្លែងលោក ការបរទេស ហ្នឹង គេមានឋានៈប្រហែលលោកដែរ គេអាចធ្វើលើសពីថ្នាក់របស់គេទេ ឬក៏ថាគឺត្រឹមតែថ្នាក់របស់គេ ហ្នឹងតែប៉ុណ្ណឹងទេ? លោកយល់សំណួរខ្ញុំហ្នឹងទេ?

**ឆ៖** *(និយាយមិនបើកមីក្រូហ្វូន)*។

**ស៖** បាទ សូមអរគុណ។

**ឆ៖** ខ្ញុំមិនដឹងទេ។ រឿងថ្នាក់គេដទៃទៀត គេឲ្យសិទ្ធិយ៉ាងម៉េច ខ្ញុំអត់ដឹងទេ។ ប៉ុន្តែការអប់រំពិសេសរបស់បង អៀង សារី គាត់អប់រំខ្ញុំតែត្រឹមកម្រិតខ្ញុំហ្នឹងថា "ឯងនៅក្របខ័ណ្ឌណា ធ្វើតាមតែក្របខ័ណ្ឌប៉ុណ្ណឹងទៅ កុំទៅគិតគេ"។ តែប៉ុណ្ណឹងបាទ។

[១៤:០២:៥៧]

**ស៖** ចាប់ពីពេលដែលលោកបានចូលធ្វើតស៊ូជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាមក លោកដែលឃើញទ័ពជនបរទេសមករួមធ្វើសហការជាមួយបក្សកុម្មុយនីស្តកម្ពុជាទេ?

**ឆ៖** ខ្ញុំមិនដែលបានធ្វើ-- ខ្ញុំមិនដែលបានឃើញទេ ប៉ុន្តែខ្ញុំបានឃើញខាងលើរៀបចំឲ្យបងប្អូននេះខ្ញុំអត់បាននេះទេ ខាងលើរៀបចំឲ្យបងប្អូនតាមរយៈ ប៉ង់ ហ្នឹងរៀបចំថា "ន៎ែ! ម៉ូតូអីៗត្រៀមអីៗទៅជូន អ៊ំនួន ទៅធ្វើការនៅបក្សផ្សេងៗទៀត" បាទតែប៉ុណ្ណឹង។

**ស៖** បក្សផ្សេងទៀតហ្នឹងមានន័យថា ជនបរទេសអ្វីអ៊ីចឹង អ្វីយ៉ាងម៉េច? មើលសូមបញ្ជាក់

រឿងបក្សផ្សេងទៀតហ្នឹងបាទ?

**ឆ៖** បាទ សូមទោស! គឺជនបរទេសហ្នឹងហើយបាទ។

**ស៖** សូមអរគុណណាស់។

**ឆ៖** បាទ។

**ស៖** តាំងពីឆ្នាំ១៩៧០ ដល់១៩៧៥ លោកដឹងយ៉ាងម៉េចដែរទេ ស្ថានភាពកាលសម័យហ្នឹង ពេលដែលទម្លាក់សម្តេច សីហនុ មករហូតដល់ឆ្នាំ១៩៧៥ ស្ថានភាពប្រទេសយើងហ្នឹងវាយ៉ាងម៉េច? លោកអាចរៀបរាប់បានតាមការចាំរបស់លោកបានទេ?

[១៤:០៥:០៩]

**ឆ៖** ខ្ញុំអាចរៀបរាប់តាម-- ខ្ញុំអាចរៀបរាប់តាមការចាំរបស់ខ្ញុំបានខ្លះ បាទ។

**ស៖** សូមកុំវែងពេក បាទខ្លី! ពីព្រោះអីពេលវេលាតិច។

**ឆ៖** បាទៗ ទីមួយ ប្រទេសអត់ទាន់មានសុខសន្តិភាពទេបាទ ៧០ ដល់៧៥ហ្នឹងបាទ។ រឿង ម៉ៃយ៉ាហ្គេ រឿងអីៗ អ្ហូ! ខ្ញុំបានចាំតិចតួចទេ រឿងកោះវៃ រឿងកោះតាង រឿងវៃគ្នាជាមួយវៀតណាម និងកងទ័ពយើងនៅព្រំដែន រឿងផ្លូវរហូតដីមិញ រឿងទាក់ទងជាមួយនឹងវៀតណាម។ អត់មានអ្វីដែល ឯកភាពគ្នាទាល់តែសោះបាទ។ នេះ ខ្ញុំសូមឧទាហរណ៍ខ្លីៗប៉ុណ្ណឹងបាទ។

**ស៖** អរគុណណាស់។ ចុះបន្ទាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ លោក វាខុសគ្នាយ៉ាងម៉េច ពី៧០ មកដល់៧៥ ហើយពីខែ៤ ៧៥ មកដល់មករា ៧៩?

**ឆ៖** បាទ សុំទោសអំមិញ ដូចថាលោកសួរមុនដំបូង ៧០, ៧៥?

**ស៖** បាទ!

**ឆ៖** ឥឡូវ៧៥ ដល់៧៩ អ្ហ៎?

**ស៖** បាទ។

**ឆ៖** ខ្ញុំនិយាយមុនហ្នឹង គឺច្រឡំ៧០-- បាទ៧៥ ដល់៧៩ទេ មុននេះ។ បើតាមខ្ញុំចាំអំមិញ ខ្ញុំ និយាយអំមិញបែបខុសអ៊ីចឹងបាទ។ ឥឡូវខ្ញុំនិយាយសាដើមឡើងវិញបាទ។

[១៤:០៦:៥៦]

៧០ ដល់៧៥ គឺលំបាកណាស់ៗ គឺបាតដៃទទេៗ ហើយដល់៧៥ឈ្នះ។ បាតទទេហ្នឹងគឺបាន ន័យថា ប្រើប្រាស់ញើសឈាមខ្លួនឯងម្តងបាទ។ អត់មានស្អីៗ អីណាទាក់ទងគ្នាទេ ជិះសេះរត់សំបុត្រ

អត់មានទូរស័ព្ទទេបាទ ជិះកង់រត់សំបុត្រ។ បើអ្នកគ្រាន់បើបន្តិចទៅ បានម៉ូតូរត់សំបុត្របាទ។ ដូច្នេះ បានខ្ញុំនិយាយពាក្យពីមុននោះ ពីប៉ុន្មានថ្ងៃមុននោះ ថាបដិវត្តន៍នេះឈ្នះដោយសារទ្រឹស្តី អាចម៍ទៅវ៉ៃយក្ស នោះ។ តើប៉ុណ្ណេះលោកស្តាប់បានឬទេ? ក៏សូមអធ្យាស្រ័យលោកបាទ។

**ស៖** សូមអរគុណណាស់ ខ្ញុំស្តាប់បាន។ ប៉ុន្តែខ្ញុំសួរបន្តភ្ជាប់នឹងសំណួរអំមិញខ្ញុំដដែលហ្នឹង ខ្ញុំសួរថាមួយរយៈពេលឆ្នាំ៧០ មក៧៥ហ្នឹង នៅកម្ពុជាប្រជាធិបតេយ្យហ្នឹងវ៉ៃខ្លាំងដោយដៃទទេ អំមិញដូចមានប្រសាសន៍អំមិញអ៊ីចឹង ជិះសេះរត់សំបុត្រ ឬម៉ូតូអ៊ីចឹងទៅ ប៉ុន្តែរយៈពេលហ្នឹងមានជនបរទេសណាមកជួយទេ? អាហ្នឹងទីមួយ។ ទីពីរ មានសហការជាមួយនឹងរដ្ឋាភិបាលហ្គ្រុង វណសិរ្សហ្គុង ហើយនិងហ្គ្រុងទេ?

[១៤:០៩:០២]

**ឆ៖** បាទ ខ្ញុំមិនយល់ហ្គ្រុងហ្នឹងដែរ ប៉ុន្តែបើតាមខ្ញុំ គឺថាខាងសម្តេចតាមមើល៍បាទ។ អ៊ីចឹងមែនទេលោក?

**ស៖** ត្រឹមត្រូវហើយ!

**ឆ៖** បាទៗ! ជាផ្លូវចិត្តទេ បានជាផ្លូវចិត្តទេបាទ រំជួល ឲ្យរំជួល ឲ្យបងប្អូនមកចូលរួមបាទ។ បើថាជាសម្ភារៈអីៗហ្នឹង គឺអត់មានទាល់តែសោះ។

**ស៖** ចុះមានទ័ពវៀតណាមមកសហការជាមួយទេ? ពេលហ្នឹងវ៉ៃ លន់ នល់ ហើយ ទាំងអស់គ្នា?

**ឆ៖** បញ្ហានេះ ខ្ញុំមិនបានឃើញផ្ទាល់ទេ ប៉ុន្តែខ្ញុំឮ។ ខ្ញុំឮកងទ័ពគេថាមានវៀតណាម ប៉ុន្តែខ្ញុំបានឮសួរ ប៉ង់ និយាយថា “អត់ឲ្យទេ អត់ឲ្យចូលមក” ដូចថា វៀតណាមវ៉ៃខាងណា ខាងហ្នឹងទៅ ខ្មែរវ៉ៃខាងណាខាងហ្នឹងទៅ អត់បានឲ្យចូលចម្រុះគ្នាទេបាទ។

**ស៖** សូមអរគុណ។ ក្រោយខែមករា ឆ្នាំ១៩៧៩ ពេលនោះទ័ព ហេង សំរិន និងទ័ពវៀតណាមវាយយកក្រុងភ្នំពេញ ពេលនោះកម្ពុជាប្រជាធិបតេយ្យ រត់ទៅទិសខាងលិច មានន័យថាទៅព្រំប្រទល់ដែនថៃ ពេលនោះលោកទៅជាមួយលោក ប៉ុល ពត ដែរឬទេ?

[១៤:១០:៥៧]

**ឆ៖** ខ្ញុំនៅក្រសួងការបរទេស ភារកិច្ចខ្ញុំគឺ ធ្វើម៉េចរក្សាបងប្អូនបញ្ញាជន កូនក្មេងដែលត្រៀមរៀនសូត្រ ជិតមួយពាន់នាក់ឯនោះ គឺថាត្រូវធ្វើម៉េចជម្លៀសចេញឲ្យផុត ក្រែងលោមានគ្រោះថ្នាក់ គឺថា

ទៅហ្នឹងគឺថា ទៅប្រហែលមួយអាទិត្យពីរអាទិត្យទេ គេនិយាយអ៊ីចឹង អាចត្រឡប់មកវិញហើយ។ ដូច្នេះ ក៏ទៅរហូតមក។

**ស៖** ពេលដែលលោកនាំកូនក្មេងរត់ទៅទិសខាងលិចៗ ពេលនុ៎ង ពេលដែលទៅហ្នឹងពេលយូរក៏ដោយ ខ្លីក៏ដោយ លោកបានជួបពូរបស់លោក គឺលោក ប៉ុល ពត ហ្នឹងទេ?

**ឆ៖** ឆ្នាំណាទេប្រហែលជា រត់ទៅជិតៗជាមួយឆ្នាំហើយបានជួបបាទ។

**ស៖** អរគុណណាស់។ ពេលដែលលោកបានជួបលោក ប៉ុល ពត នៅកន្លែងតស៊ូទល់ដែននុ៎ង លោកបានធ្វើការជិតដិតជាមួយគាត់តទៅទៀត ឬក៏នៅផ្សេងពីគ្នា?

**ឆ៖** បាទ ខ្ញុំនៅផ្សេងពីគ្នា កន្លែងដែលខ្ញុំនៅជាប្រចាំគឺគេហៅថា ១០២ នេះ ម៉ាខ្សែនេះឯងបាទ។

**ស៖** ដល់ពេលលោក ប៉ុល ពត គាត់ឈឺៗយូរ បើតាមខ្ញុំដឹង ហើយមុនពេលគាត់ស្លាប់ ថាតើលោកដឹងទេ? ដល់ហើយដល់ថ្ងៃគាត់ស្លាប់ទៀតដឹងទេ?

[១៤:១៣:១៣]

**ឆ៖** មុនលោកស្លាប់ លោកប្រាប់ថា សភាពការណ៍នៅខាងលើ ពេលនុ៎ងគាត់នៅលើៗភ្នំ គេហៅខាងលើ សភាពការណ៍នៅលើភ្នំអត់ស្រួលទេ ឯងនៅខាងក្រោមពេលនុ៎ងខ្ញុំៗមិននៅជាមួយលោកទេ ប៉ុន្តែពេលមួយនោះ លោកៗហៅគ្នីគ្នាមកប្រជុំទៅ លោកប្រាប់ខ្ញុំថា អត់ៗស្រួលទេឯង។ ឯងបើថាខ្ញុំហៅ សឹមឯងមក បើខ្ញុំមិនហៅទេ ឯងកុំមកឲ្យសោះ ឯងទៅណាទៅៗ។

**ស៖** រួចពីហ្នឹងមកទៀត លោកអត់ដែលបានជួបលោក ប៉ុល ពត ទេ?

ឆ៖ *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ចាំៗ ក្បាលមីក្រូដំណើរការសិន សឹមឆ្លើយ។

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំឈប់បានជួបរូបលោកហើយ ខ្ញុំជួបតែផ្នូរលោកទេ។

**សួរដោយលោក សុន អរុណ៖**

**ស៖** បើដូច្នេះ លោកមិនបានដឹងមានស្ថានភាព ស្ថានការណ៍អី អ្វីប្លែកមុនថ្ងៃដែលគាត់ស្លាប់ ឬថ្ងៃដែលគាត់ស្លាប់? ថ្ងៃដែលគាត់ស្លាប់ មានន័យថា មុននឹងគាត់ស្លាប់ទេ មិនបានដឹងទេណា?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ខ្ញុំនៅឯក្រោម នៅទល់មុខជិតផ្លូវលេខ ផ្លូវមកឧត្តរមានជ័យឯណោះ។

[១៤:១៦:០០]

**ស៖** សូមអរគុណ។ ខ្ញុំឈប់សួរពីរឿង ហ្នឹងខ្ញុំដូរសំណួរផ្សេងទៀត។ នៅក្នុងឯកសារលេខ D233/2 លោកបានឆ្លើយថា ខ្ញុំដឹងពីព្រោះ ប៉ុល ពត គាត់ទទួលនយោបាយ គាត់ទទួលបន្ទុកខាងនយោបាយ ហើយបង នួន ទទួល-- បង នួន ជា ទទួលខាងចាត់តាំង។ អានេះជាសម្ដីរបស់លោក។ ខ្ញុំសួរថា ចម្លើយនេះតើលោកដឹងអំពីរចនាសម្ព័ន្ធ ស្ដីអំពីមុខងារនេះពីណាមក?

**ឆ៖** គឺតាមលោក ប៉ង់។

**ស៖** បើ នួន ជា ទទួលចាត់តាំង តើនៅរបបកម្ពុជាប្រជាធិបតេយ្យ មុខងារចាត់តាំងនេះមានន័យថាយ៉ាងម៉េច? ហើយមុខងារធ្វើអ្វីខ្លះ?

**ឆ៖** ខ្ញុំមិនយល់ដែរកិច្ចការផ្ទៃក្នុងរបស់លោកទាំងពីរ មួយនយោបាយ មួយចាត់តាំងនេះ។ គ្រាន់តែដឹងពាក្យថា ប៉ង់ ប្រាប់ថា ប៉ុល ពត នយោបាយ, នួន ជា ចាត់តាំង។

[១៤:១៧:០៧]

**លោក សុន អរុណ៖**

សូមអរគុណណាស់លោកសាក្សី។

ខ្ញុំអស់មានសំណួរលោកប្រធាន ហើយសហភាគីនឹងសួរបន្តទៅទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើន។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** សួស្ដីលោកសាក្សី។ ខ្ញុំក៏ជាមេធាវីតំណាងលោក នួន ជា ផងដែរ។ ខ្ញុំមានសំណួរមួយចំនួនចង់សួរលោក។ ជាបឋម ខ្ញុំសូមសួរលោកសាជាថ្មី អំពីរឿងក្ដី ០០១។ មេធាវី កាណាវាស មេធាវីការពារក្ដីលោក អៀង សារី បានសួរលោកថា តើអ្នកណាគួរតែជាជនជាប់ចោទនៅក្នុងរឿងក្ដី ០០០? ខ្ញុំដូចជាមិនចាំថា លោកថាជនជាប់ចោទនោះគឺ នរណានោះទេ? តើលោកមានឆ្លើយដែរឬទេចំណុចហ្នឹង? សូមអរគុណ។

[១៤:១៨:១៨]

**លោក សាឡុត បាន៖**

**ឆ៖** សូមជម្រាបលោក ថ្ងៃមុនខ្ញុំមិនចាំម៉ោង ចាំពេលទេ។ ខ្ញុំបានថាខ្ញុំសមា-- សមាធិទៅ លោកតាដំបងដែកប្រាប់ខ្ញុំថា "សម្ដីជាឯកណាចៅ លេខជាទោ អក្សរជាត្រី។ ០០០ ជាអ្វី ម៉េចក៏មិនគិតផង?" នេះខ្ញុំបាននិយាយដូច្នេះ។ ដូច្នេះខ្ញុំគិតថា ខ្ញុំសួរខ្លួនឯងថា មុននឹងលេខ០០១ មានអីពីមុនហ្នឹងទៀត? ខ្ញុំថាមុន០០១ គឺលេខ០០០ នេះឯង។ បានន័យថា ០០០ នេះគឺជាមេបង្ក។ ០១ សូន្យទីមួយគេហៅថា "សូន្យកង", សូន្យទីពីរគេហៅថា "សូន្យកាក់", សូន្យទីបី គេហៅថា "សូន្យក"។ ហើយនេះ សូន្យ កាក់ ក។ អាណាបង្កើតរឿងហ្នឹង? ចង់និយាយអ៊ីចេះបាទ។ នរណាបង្កើតរឿងហ្នឹង? នរណានាំអាទិ៍មានរឿងហ្នឹង? ហើយខ្ញុំក៏ចង់បញ្ជាក់ទៀតថា ខ្មែរក្រហមដូចខ្ញុំនេះ មិនចង់រស់នៅក្នុងព្រៃទេ មិនចង់លំបាកទេ។ វាលំបាកណាស់ការតស៊ូ ការប្រឆាំង ការធ្វើសង្គ្រាម។ គេតើគេបង្កសង្គ្រាមឲ្យខ្ញុំធ្វើខ្មែរក្រហម ហើយខ្មែរក្រហមនេះខ្ញុំមិនដាក់ឈ្មោះខ្លួនឯងផង មិនដឹងនរណាដាក់ផង។ ខ្ញុំជាជនតស៊ូតើ ខ្ញុំជាយុទ្ធជន ដើម្បីរំដោះជាតិតើ។ ន័យ ០០ នេះ គឺអារម្មណ៍របស់ខ្ញុំយល់យ៉ាងដូច្នេះលោក។

[១៤:២០:៥៤]

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលដែលលោកថា អ្នកណាជាមេបង្កើតរឿងហ្នឹងៗ តើលោកសំដៅទៅនរណា វៀតណាម ឬក៏អ្នកណា? សូមលោកបញ្ជាក់ឲ្យបានជាក់លាក់បន្តិចមក? វៀតណាម ឬក៏អាមេរិក សូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់។

**ឆ៖** ដល់ខ្ញុំឆ្លើយអ៊ីចឹងទៅ ខ្ញុំមានចម្លើយមួយថា ច្បាប់ព្រហ្មទណ្ឌ នេះតាមខ្ញុំចាំបាន។ ខ្ញុំអត់ចោទទេណា។ ខ្ញុំអត់ចោទវៀតណាម និងអាមេរិកអីទេ ខ្ញុំអត់ចោទទេ។ ខ្ញុំឆ្លើយថា ច្បាប់ព្រហ្មទណ្ឌមានន័យយ៉ាងម៉េច? បើទស្សនៈខ្ញុំ ច្បាប់ព្រហ្មទណ្ឌគឺថា បើធ្វើអ្វីខុសពីច្បាប់ព្រហ្មហើយ ដំបូន្មានព្រហ្មហើយ គឺអ្នកឯងត្រូវមានទណ្ឌកម្ម។ ចុះច្បាប់ព្រហ្មទណ្ឌមានអីជាក្រឹត្យក្រម? ព្រហ្មតាមខ្ញុំយល់ជាពុទ្ធិ។ ព្រហ្មគឺបង្កើតមនុស្ស មនុស្សកើតមកពីទឹក ដី ខ្យល់ ភ្លើង នរណាដែលបំផ្លាញទឹក ដី ខ្យល់ ភ្លើង ហ្នឹងហើយ អ្នកបង្ករឿង។ បាទ សូមមានយោបល់ប៉ុណ្ណឹង។ ខ្ញុំអត់ប៉ះទៅអាមេរិក ខ្ញុំអត់ប៉ះពាល់ទៅបងប្អូនវៀតណាមទេ។

[១៤:២៣:០៨]

**ប្រធានអង្គជំនុំ៖**

មេធាវីសូមតាំងសំណួរឲ្យជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់។ សំណួរ

អម្បាញ់មិញនេះហើយនិងចម្លើយ មិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់ ហើយកំពុងតែត្រូវបានយកមកធ្វើសវនាការទេ។

**លោក ម៉ែខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ចាំងឯកសារមួយ។ ឯកសារមួយច្បាប់ជាលាយលក្ខណ៍អក្សរ បានបញ្ជូនទៅមន្ត្រីតុលាការហើយ ឯកសារ D56/doc.101 វាជាសេចក្តីប្រកាសព័ត៌មានក្រោយពីទស្សនកិច្ចរបស់សម្តេចនរោត្តម សីហនុ ទៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៧២។ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះធ្វើការបញ្ចាំងនូវឯកសារនេះ។ សូមអរគុណ។

[១៤:២៤:២០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការបង្ហាញ ឯកសារនៅលើអេក្រង់កុំព្យូទ័រតាមសំណើសុំរបស់មេធាវីការពារក្តី នួន ជា។ សូមលោកមេធាវីផ្តល់អត្តសញ្ញាណឯកសារសាជាថ្មី ដោយសារអ្នកមន្ត្រីច្បាប់ស្តាប់មិនបានច្បាស់អំពីអត្តសញ្ញាណឯកសារ ដែលលោកមានការប៉ុនប៉ងស្នើសុំឲ្យដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រ។

**លោក ម៉ែខល ផេសមិន៖**

គឺ D56-Doc.101-- 010 សូមអធ្យាស្រ័យបាទ មន្ត្រីតុលាការគាត់មានឯកសារនេះនៅជាឯកសារក្រដាសហើយ ដូច្នេះហើយយើងខ្ញុំសូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់គឺ D56/Doc.010។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ខ្ញុំទុកពេលប៉ុន្មានវិនាទីឲ្យលោកសាក្សីពិនិត្យមើលឯកសារនេះសិន។ លោកសាក្សី សំណួររបស់ខ្ញុំហ្នឹង គឺចង់សួរថា លោកបានឮអំពីទស្សនកិច្ចដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៧២ ក្នុងខែតុលា គឺសម្តេចព្រះ នរោត្តម សីហនុ ប្រធានប្រមុខរដ្ឋ និងប្រធានរណសិរ្សរួបរួមជាតិ បានធ្វើ យាងធ្វើទស្សនកិច្ចទៅប្រទេសវៀតណាម ដោយក្នុងនោះ មានរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាលយាងដំណើរទៅជាមួយព្រះអង្គនៅពេលនោះ ធ្វើដំណើរទៅជាមួយព្រះអង្គនៅពេលនោះ។ តើលោកមានស្គាល់ ដឹងអំពីទស្សនកិច្ចនេះដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទាល់តែសោះបាទ។

E1/70.1

[១៤:២៦:១២]

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំមិនសួរលោកបញ្ហាផ្សេងទៀតអំពីឯកសារនេះទេ។ ប៉ុន្តែក្នុងនោះ មានមនុស្សម្នាក់ ដែលធ្វើដំណើរទៅជាមួយព្រះអង្គ ទៅវៀតណាមមាន គាត ឈន់ លោកបានលើកឡើងឈ្មោះនេះប៉ុន្មានដងដែរ ប៉ុន្មានថ្ងៃមុន។ តើលោកដឹងទេ តួនាទីរបស់គាត់ហ្នឹង នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជានៅពេលនោះ គឺអ្វីដែរ? មានតួនាទីអ្វីដែរ?

**ឆ៖** ខ្ញុំមិនដឹងតួនាទីរបស់លោកទេ។ ខ្ញុំស្គាល់លោកតែក្នុងក្រសួងការបរទេស ហើយគាត់នៅផ្នែកខាងបញ្ញាជន។ ឯខ្ញុំនៅផ្នែកខាងកសិករបាទ។

**ស៖** យោងតាមឯកសារដែលខ្ញុំបង្ហាញលោកនោះ គឺគាត់ជារដ្ឋមន្ត្រីតំណាងខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៅក្នុងឆ្នាំ១៩៧២។ តើខ្ញុំយល់ច្បាស់ពីចម្លើយរបស់លោក ថាលោកមិនអាចបញ្ជាក់អំពីតួនាទីរបស់គាត់នាពេលនោះបានទេ អ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ។

[១៤:២៧:៣៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី គួរតែត្រូវបានបញ្ជាក់អំពីអត្តសញ្ញាណឯកសារនេះ ដែលលោកមានការប៉ុនប៉ងដាក់សួរដេញដោលសាក្សី អម្បាញ់មិញ សាក្សីអត់ដឹងព្រឹត្តិហេតុនោះទេ។ ទីពីរ សំណួរកន្លងមកលោកតែងតែជំទាស់ភាគីដទៃទៀត ថាឲ្យបង្ហាញអត្តសញ្ញាណសាក្សី ឯកសារនេះ ថាតើឯកសារនេះសាក្សីធ្លាប់បានឃើញពីមុនមកដែរឬទេ?

ដើម្បីយើងសម្រេចថាតើឲ្យដាក់នៅមុខហ្នឹង ឬក៏ដកចេញ ដោយទុកលទ្ធភាពឲ្យភាគីដែលមានបំណងដេញដោលទៅលើបញ្ហាពាក់ព័ន្ធនឹងឯកសារនេះ ដោយមិនមានឯកសារនៅនឹងមុខសាក្សី ហើយក៏ដូចគ្នាមិនមាននៅលើកញ្ចក់អេក្រង់ទូរទស្សន៍។ លោកអាចធ្វើដូច្នេះបានទេ? ពីព្រោះនេះជាការណែនាំរួមស្ដីពីការដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដែលយើងបានធ្វើរួចមកហើយ បន្ទាប់ពីមានការតវ៉ាជំទាស់គ្នាជាច្រើនលើកច្រើនសា។

[១៤:២៨:៤០]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់ការសួរសំណួរត្រង់ឯកសារនេះហើយ។ ដូច្នេះ ខ្ញុំគិតថា

អាចដកឯកសារនេះចេញហើយ មិនជាបញ្ហាអ្វីទេ។ ខ្ញុំចង់សួរបន្តទៅសំណួរបន្ទាប់ទៀត ដែលខ្ញុំសូមសួរនៅពេលនេះតែម្តងលោកសាក្សី។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** កាលពីសប្តាហ៍មុន លោកបានបញ្ជាក់ទៅលើចម្លើយដែលលោកឆ្លើយជូនសហព្រះរាជអាជ្ញាថា គាត ឈន់ ធ្លាប់បានគេឆ្លើយដាក់នៅក្នុងឯកសារជាច្រើន-- ធ្លាប់បានឆ្លើយដាក់-- គេឆ្លើយដាក់នៅក្នុងឯកសារជាច្រើន តើលោកចាំទេ?

**លោក សាឡុត បាន៖**

**ឆ៖** ដូចជាខ្ញុំមិនបាននិយាយថា ធ្លាប់មានឯកសារឆ្លើយដាក់ទេ។ គ្រាន់តែថា ខ្ញុំដឹងថា លោក គាត ឈន់ ខ្ញុំដឹងថាមានគេចោទ។ ដូច្នេះ ខ្ញុំតាមខ្ញុំចាំ ដែលថា បងសារី គាត់-- បង អៀង សារី គាត់ថា បើដកលោក គាត ឈន់ ទៅគឺក្រសួងការបរទេសហ្នឹង គឺត្រូវតែអត់ដំណើរការទេ។ ខ្ញុំនិយាយអ៊ីចឹងបាទ ខ្ញុំមិនបានថា ខ្ញុំឃើញគេចោទអីៗច្រើនទេបាទ។

**ស៖** សូមអរគុណលោកសាក្សី។ នេះជាចំណុចដែលលោកឆ្លើយ ដែលខ្ញុំយោងទៅរកហ្នឹង។ សំណួរបន្តរបស់ខ្ញុំ គឺចង់សួរថា ហេតុអ្វីបានជាក្រសួងការបរទេសនោះនឹងមិនដំណើរការប្រសិនបើដកលោក គាត ឈន់ ចេញនោះ?

**ឆ៖** ខ្ញុំមិនដឹងហេតុផលរបស់បង អៀង សារី យ៉ាងម៉េចទេបាទ។ ខ្ញុំអត់ដឹងហេតុទេបាទ។

[១៤:៣១:១៨]

**ស៖** លោកមិនអាចពន្យល់ ថាតើគាត់ហ្នឹងមានសារសំខាន់ប៉ុនណាទេ ដែលធ្វើឲ្យលោក អៀង សារី ហ្នឹងអន្តរាគមន៍ផងដែរនោះ?

**ឆ៖** បាទ។

**ស៖** នៅក្នុងថ្ងៃ៣១ ធ្នូ ឆ្នាំ៧៧ មានសេចក្តីថ្លែងការណ៍ជាផ្លូវការមួយរបស់ក្រសួងការបរទេស ដែលក្នុងនោះនិយាយអំពីការផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងប្រទេសវៀតណាម។ តើលោកចាំសេចក្តីប្រកាសជាផ្លូវនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** តើលោកចាំអ្នកណាគេដែលជាអ្នកសរសេរសេចក្តីថ្លែងការណ៍ជាផ្លូវការនោះ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

[១៤:៣២:៣៥]

**ស៖** ចៅក្រមស៊ើបអង្កេតបានសួរលោកលើសំណួរមួយនេះ។ គឺអ្នកស៊ើបអង្កេតទេ ដែលសួរលោកលើសំណួរនេះ គាត់ធ្វើការឲ្យចៅក្រមស៊ើបអង្កេត។ "បុគ្គលដែលអាចទំនងសរសេរសេចក្ដីប្រកាសជាផ្លូវការនោះ ទំនងជាលោក គាត ឈន់" ដែលចម្លើយនេះលោកបានឆ្លើយនៅថ្ងៃ២២ ខែកក្កដា ឆ្នាំ២០០៩។ តើលោកចាំទេ?

**ឆ៖** បាទ ខ្ញុំចាំថា លោក គាត ឈន់ គាត់សរសេរសុន្ទរកថាអីផ្សេងៗ តែពីរឿងប្រកាសផ្ដាច់ទូតពីវៀតណាមនេះ គឺខ្ញុំអត់ដឹងទេ។

**លោក ម៉ែខល ផេសមិន៖**

លោកប្រធាន ខ្ញុំចង់បង្ហាញឯកសារមួយទៀតមុនពេលឈប់សម្រាក។ ខ្ញុំនឹងសួរសំណួរសមរម្យបន្ទាប់ពីឯកសារនេះទៅ គឺឯកសារលេខ D366/7.1.473។ ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើអេក្រង់។--

[១៤:៣៤:១០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីការពារក្ដីយកទៅបង្ហាញ!

សូមលោកមេធាវីបង្ហាញអំពីឯកសារនេះ តើជាឯកសារនៅក្នុងសំណុំរឿង ឬក៏ឯកសារថ្មី?

**លោក ម៉ែខល ផេសមិន៖**

គឺឯកសារនៅក្នុងសំណុំរឿង ហើយលេខដែលខ្ញុំជម្រាបហ្នឹងគឺលេខសំណុំរឿងផ្លូវការ។ ហើយខ្ញុំជឿថា ឯកសារនេះ នាពេលបញ្ចាំងលើអេក្រង់រួចហើយ យើងអាចមើលលេខសម្គាល់ផងដែរ។ ក្នុងខណៈសាក្សីកំពុងតែពិនិត្យមើលឯកសារ វាជាឯកសារសរសេរដោយដៃ កំណត់សម្គាល់សរសេរដោយដៃស្ដីអំពីទស្សនកិច្ចរបស់សម្ដេច សីហនុ នៅទីក្រុងញូវយ៉ក នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៧៥។ ខ្ញុំសូមសួរសាក្សី តើលោកសាក្សីធ្លាប់បានឃើញឯកសារនេះពីមុនដែរឬទេ ឬក៏ឯកសារនេះថ្មីសន្លាងចំពោះលោកតែម្ដង? សូមលោកជួយឆ្លើយ។

**ឆ៖** បាទ ឯកសារនេះថ្មីសន្លាងចំពោះខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដកហូតឯកសារនេះពីសាក្សី ហើយនិងដកចេញពីអេក្រង់កំព្យូទ័រ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៧:០២]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីឯកសារ D67/7.1.473 ហ្នឹង តើជាប្រភេទឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ?

**លោក ម៉ៃខល ផេសមិន៖**

ដូចជាអត់ទេ តាមអ្វីដែលខ្ញុំដឹង។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៨:២៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកសួរដេញដោលចំពោះឯកសារណាដែលលោកមិនបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះដូច្នេះទេ។ ចំពោះឯកសារថ្មីដែលដាក់ដេញដោលនោះ ប្រសិនបើលោកមានបំណង ហើយយល់ថាជាការចាំបាច់នោះត្រូវដាក់ស្នើសុំមកអង្គជំនុំជម្រះជាមុន ដើម្បីអង្គជំនុំជម្រះសម្រេចទៅលើការថា សម្រេចឲ្យដេញដោល ដាក់ឯកសារហ្នឹងដេញដោលនៅចំពោះមុខអង្គជំនុំជម្រះឬយ៉ាងណា ចំពោះឯកសារដែលមិនទាន់លើកមកដាក់ចំពោះមុខអង្គជំនុំជម្រះ ដើម្បីឈានដល់ការដេញដោលទៅ ប្រព្រឹត្តទៅតាមនីតិវិធីជាធរមាន។

[១៤:៣៩:១០]

**លោក ម៉ៃខល ផេសមិន៖**

ឯកសារនេះ ដាក់ចូលក្នុង *អ៊ីនធីហ្វេស* រួចជាមុនមកហើយ ហើយយើងប្រកាន់ជំហរថា យើងមិនចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះទេ យើងគ្រាន់តែចង់សួរផ្ចុចសាក្សីនេះតែប៉ុណ្ណោះ។ យើងគ្រាន់តែចង់ប្រើឯកសារនេះជាការដេញដោលផ្តុចទៅលើសាក្សីតែប៉ុណ្ណោះ ហើយវាបានដាក់នៅក្នុង*អ៊ីនធីហ្វេស* រួចទៅហើយ។ ដូច្នេះហើយ ខ្ញុំហាក់ដូចជាច្រឡំបន្តិចដែរទៅលើឯកសារនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤០:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាប លោកមេធាវីការពារក្តី នួន ជា ថា ឯកសារប្រភេទនេះដែលលោកបានដឹងច្បាស់ថា មិនមានបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ គប្បីត្រូវតែធ្វើសំណើសុំតាមនីតិវិធីចំពោះមុខអង្គជំនុំជម្រះ ដើម្បីសម្រេចថា លើកយកមកដេញដោលនៅចំពោះមុខនាពេលនេះ ឬយ៉ាងណា? បញ្ហាទីពីរគឺ តើឯកសារនេះ មានការបកប្រែត្រឹមត្រូវជាបីភាសា ឬយ៉ាងហោចណាស់ជាពីរភាសាហើយឬនៅ? បញ្ហាទីបី ខ្ញុំដូចជាមានបញ្ហាឆ្ងល់ដែរ ដោយសារលោកមេធាវីបានលើកឡើងថា ខ្លួនគ្មានបំណងយកឯកសារនេះ មកដាក់ចំពោះមុខអង្គជំនុំជម្រះទេ មានបំណងគឺថា គ្រាន់តែយកឯកសារនេះមកសួរផ្ទៀងផ្ទាត់សាក្សី ភាសានេះ បើកម្រិតជាភាសាជាតិខ្មែរហ្នឹង ដូចជាមិនអាចទទួលយកបានទេ។ ការដេញដោលទាំងអស់ គឺត្រូវធ្វើនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីឱ្យអង្គជំនុំជម្រះស្តាប់បាននូវព័ត៌មាននូវហេតុការណ៍ នូវព្រឹត្តិហេតុផ្សេងៗ ដែលកើតឡើងមាននៅក្នុងអំឡុងពេលដេញដោល។ បែរជាមានបំណងថា លើកឯកសារនេះមកគឺមិនចង់ឱ្យអង្គជំនុំជម្រះដឹងទេ គឺសួរទៅផ្ទៀងផ្ទាត់ទៅសាក្សីទៅវិញ។

[១៤:៤២:២៨]

ឥឡូវនេះ លោកពិនិត្យឡើងវិញលើបញ្ហាឯកសារនេះ តើលោកចាំបាច់ក្នុងការត្រូវដេញដោលដែរទេ? បើត្រូវដេញដោល លោកត្រូវតែធ្វើនីតិវិធីនៃការស្នើសុំដើម្បីឱ្យអង្គជំនុំជម្រះសម្រេចជាមុនមុននឹងដាក់ដេញដោលចំពោះសាក្សីរូបនេះ។ អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យលោកប្រើប្រាស់នូវវិធីនៃការពង្វាងចេញផុតពីអង្គជំនុំជម្រះ ហើយយកទៅផ្ទៀងផ្ទាត់សាក្សី ហើយឱ្យសាក្សីឆ្លើយបញ្ហានោះមកអង្គជំនុំជម្រះដូច្នេះបានទេ។

ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ ហើយនិងមេធាវីប្រឹក្សារបស់គាត់ក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា អង្គជំនុំជម្រះសូមជម្រាបថា ឯកសារអម្បាញ់មិញនេះ ដែលលោកមេធាវីការពារក្តី នួន ជា មានបំណងដាក់ពិភាក្សាដេញដោលតទល់ចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសម្រេចថា មិនអនុញ្ញាតឲ្យដាក់ឯកសារនេះប្រើប្រាស់ ក្នុងការពិភាក្សាដេញដោលចំពោះសាក្សីនេះទេ ដោយហេតុថា ទោះបីឯកសារនេះមាននៅក្នុងសំណុំរឿងក៏ដោយ តែនៅក្នុងបញ្ជីឯកសារនានាដែលបានស្នើសុំដោយភាគី មិនមាននៅក្នុងបញ្ជីឯកសារទេ ចំពោះឯកសារនេះ។

ទីពីរទោះបីមាននៅក្នុង នៅអ៊ីនធឺហ្វេស ក៏ដោយក៏ភាគីមិនអាចលើកយកឯកសារបែបនេះមកពិភាក្សាដេញដោល ដោយមិនស្នើសុំចំពោះមុខអង្គជំនុំជម្រះ ឲ្យអង្គជំនុំជម្រះពិនិត្យសម្រេចជាមុនចំពោះឯកសារប្រភេទនេះឡើយ។

[១៥:០៤:៣៩]

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រហែលជាមានបញ្ហាខាងការបកប្រែ។ អ្វីដែលសំខាន់នោះគឺថា ឯកសារនេះមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់ធ្វើការដេញដោលនោះទេក្នុងដំណាក់កាលនេះ។ ដូច្នេះនៅពេលដែលអង្គជំនុំជម្រះចង់ពិនិត្យផ្ទៀងផ្ទាត់នោះ គឺថាតើឯកសារនេះមាននៅក្នុងបញ្ជីឯកសារ ដែលភាគីបានស្នើដើម្បីដាក់ចូលទៅក្នុងសំណុំរឿងហើយឬនៅ? ហើយក្នុងដំណាក់ការនេះ ឯកសារនេះមិនទាន់មានការស្នើនៅឡើយទេ។ ប្រសិនមេធាវីការពារក្តី នួន ជា ចង់ប្រើប្រាស់ឯកសារនេះសម្រាប់ដេញដោលសាក្សីរូបនេះ មេធាវីត្រូវតែធ្វើសំណើសុំ គឺក្នុងឋានៈជាឯកសារថ្មីដែលនឹងដាក់ជជែកដេញដោល។ គឺនេះ--

ទង្វើនេះគឺយោងទៅតាមវិធាន៨៧(៤) ប្រហែលជាអ៊ីចឹងហើយ ខ្ញុំជឿថាអ៊ីចឹង។ ហើយត្រូវតែពន្យល់ឲ្យបានច្បាស់ថាតើហេតុអីបានជាឯកសារនេះ មិនមាននៅក្នុងបញ្ជីដំបូងរបស់ខ្លួន ដែលភាគីចង់ដាក់នោះ?

[១៥:០៦:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ម៉ែខល ផេសមិន៖**

សូមអរគុណ។ ការពន្យល់គឺច្បាស់លាស់អស់ទៅហើយចំពោះខ្ញុំ។ ដូចអ្វីដែលលោកចៅក្រម ឡាវែន៍ បានពន្យល់ គឺខ្ញុំយល់ស្រប ហើយនេះគឺជាការវិត្តន៍ថ្មីមួយទៅលើយុត្តាធិការរបស់យើង។ ខ្ញុំត្រូវបានគេស្នើឲ្យធ្វើបញ្ជីនៅក្នុងខែតុលា ឆ្នាំ២០១១។ ឯកសារនៅមាននៅពេលនោះ ប៉ុន្តែយើងមិនបានដាក់ចូលទៅក្នុងបញ្ជីទេ ដោយសារតែយើងមិនចង់ធ្វើដូច្នេះ។ គឺយើងមិនមែនព្យាយាមបង្ហាញនូវភស្តុតាងថ្មីនោះទេ គឺយើងៗគ្រាន់តែប្រើព័ត៌មាននេះដើម្បីផ្ទៀងផ្ទាត់ទៅលើសាក្សីតែប៉ុណ្ណោះ។ ហើយប្រហែលជាមានការច្របល់-- យល់ច្រឡំចំពោះការប្រើប្រាស់ពាក្យថា *"អ៊ឹមភីជ"* នៅក្នុងភាសាខ្មែរ។ ការពិតពាក្យថា *"អ៊ឹមភីជ"* ដែលបកប្រែថាផ្ទៀងផ្ទាត់នេះ គឺខ្ញុំមានគោលដៅគ្រាន់តែថាធ្វើការសាកល្បងទៅលើ ធ្វើការពិនិត្យសាកល្បងទៅលើសាក្សីតែប៉ុណ្ណោះ។ មិនមែន គឺៗខ្ញុំគ្រាន់តែចង់ពិនិត្យទៅលើភាពអាចជឿទុកចិត្តបានរបស់សាក្សី។ ខ្ញុំនឹងដាក់នូវញត្តិមួយទាក់ទងទៅនឹងបញ្ហានៃឯកសារ ដែលត្រូវដាក់ជូនទៅសាក្សី ហើយយើងអាចនឹងធ្វើ ហើយយើងអាចនឹងដាក់ឯកសារនេះដែលសហការជាមួយនឹងភាគីដទៃទៀត ដើម្បីឲ្យមាន-- ដើម្បីស្នើឲ្យមានសវនាការ ដើម្បីពិភាក្សាទៅលើបញ្ហាមួយនេះ។ យើងនិងនិយាយទៅលើបញ្ហានេះនៅពេលក្រោយ។ ឥឡូវនេះខ្ញុំសូមបន្តសំណួររបស់ខ្ញុំបន្តទៅទៀត។

[១៥:០៧:៥០]

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ហើយចំពោះលោកសាក្សី ខ្ញុំសូមបន្តសំណួររបស់ខ្ញុំជាបន្តទៅទៀត។ តើលោកមានចាំឯកសារសរសេរដៃដែលខ្ញុំបានបង្ហាញលោកពីមុនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:០៨:២៦]

**លោក វ៉ាងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំចង់ឲ្យមានការសម្រេចទៅលើឯកសារ ហើយឥឡូវនេះមេធាវី នួន ជា គាត់បានសួរអំពីអក្សរនេះទៀតហើយ។ ដូច្នេះ វិធានគឺអនុវត្តចំពោះយើងទាំងអស់គ្នា។ ដូច្នេះមិនគួរណាសួរសំណួរពាក់ព័ន្ធនឹងអក្សរសរសេរដៃនៃឯកសារនេះទៀតទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយ មិនអនុញ្ញាតឲ្យលោកយកឯកសារនេះមកប្រើប្រាស់ដេញដោលសាក្សីរូបនេះទេ ដោយហេតុលោកមិនបានបំពេញកិច្ចដំណើរការតាមនីតិវិធី។ លោកបានសន្យាហើយអំមិញ ថានៅពេលបន្ទាប់ទៀត លោកនឹងដាក់ញត្តិពាក់ព័ន្ធនឹងបញ្ហាឯកសារនេះ។ ឥឡូវនេះលោកមិនទាន់ដាក់ទេ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។ ហើយសួរសំណួរមួយទៀតថាតើលោកត្រូវពេលវេលាត្រូវការពេលពេលវេលាប៉ុន្មានទៀតក្នុងការសួរដេញដោលសាក្សីរូបនេះ ដើម្បីអង្គជំនុំជម្រះលៃលកពេលវេលាសម្រាប់ភាគីពាក់ព័ន្ធដទៃទៀតដែលនៅសល់?

[១៥:០៩:២៩]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសង្ឃឹមថាខ្ញុំអាចបញ្ចប់នៅថ្ងៃនេះ។ ហើយវាអាស្រ័យទៅលើថាតើមានការរំខានតិច ឬក៏ច្រើនប៉ុណ្ណោះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មានការរំខានមកពីលោក ឬក៏រំខានមកពីអ្នកដទៃ?

ឥឡូវលោកបន្តនូវតាំងសំណួរផ្សេងទៀត ប្រសិនបើលោកមានសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ចំណែកឯកសារបញ្ហាពាក់ព័ន្ធនឹងឯកសារអម្បាញ់មិញនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកលើកយកមកដេញដោលចំពោះសាក្សីរូបនេះទេ។ អង្គជំនុំជម្រះបានសម្រេចរួចហើយ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកដឹងដែរឬទេថា លោក គាត ឈន់ បានអមព្រះរាជដំណើរសម្តេចព្រះនរោត្តម សីហនុ ទៅទីក្រុងញូវយ៉ក នៅក្នុងឆ្នាំ៧៥? តើលោកដឹងដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ អង្គហេតុនេះមានការមិនមានការពាក់ព័ន្ធទៅនឹងការ

ចោទប្រកាន់ទេ។ នៅក្នុងសេចក្តីសន្និដ្ឋានចោទប្រកាន់មិនមានបង្ហាញពីអង្គហេតុនេះទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាបញ្ជាក់ឲ្យបានលម្អិត ថាតើហេតុអ្វីក៏សំណួររបស់ខ្ញុំមិនពាក់ព័ន្ធ ព្រោះថានេះគឺថាដំណើរទស្សនកិច្ចដ៏សំខាន់ទៅអង្គការសហប្រជាជាតិនៅក្នុងរបបខ្មែរក្រហម។ ហើយខ្ញុំគិតថា វាពាក់ព័ន្ធព្រោះថាវានិយាយអំពីតួនាទីរបស់លោក គាត ឈន់ នៅមន្ទីរប-១។ ដូច្នេះទោះបីថាខ្ញុំមិនអាចប្រើប្រាស់ឯកសារនោះបាន ប៉ុន្តែខ្ញុំព្យាយាមដើម្បីចោទសួរទៅលើបញ្ហានេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១១:៣០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយថា សំណួរដែលលោកហ្នឹងមិនពាក់ព័ន្ធទេ។ អ៊ីចឹងសាក្សីមិនបាច់ឆ្លើយទេ។ ប្រសិនបើលោកអស់សំណួរ យើងនឹងប្រគល់ពេលវេលាហ្នឹងទៅជូនទៅក្រុមមេធាវីផ្សេងទៀត។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំមានសំណួរបន្តទៅទៀត ហើយខ្ញុំសូមបន្ត។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី ថាតើ គាត ឈន់ គាត់មានតួនាទី ដើម្បីធ្វើការកត់ត្រានៅក្នុងព្រឹត្តិការណ៍សំខាន់ៗដែរឬទេ?

[១៥:១២:១៤]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំបានឆ្លើយជាបន្តបន្ទាប់ហើយ គាត់មានតួនាទីកត់ត្រា ប៉ុន្តែសំខាន់ ឬមិនសំខាន់ ខ្ញុំមិនដឹងទេ។

**ស៖** លោកសាក្សី ខ្ញុំចង់បង្ហាញនូវឯកសារថ្មីមួយទៀត គឺឯកសារៗ D91/15 ហើយខ្ញុំស្នើអង្គជំនុំជម្រះដើម្បីដាក់បង្ហាញទៅសាក្សីនូវឯកសារមួយនេះ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ លោកបង្ហាញឯកសារនេះសិន តើចរិតលក្ខណៈនៃឯកសារនេះ លោកបានដាក់នៅ

ចំពោះមុខអង្គជំនុំជម្រះរួចហើយឬនៅ? ឬក៏មិនទាន់ដាក់ទេ? លោកបានយល់ហើយ អម្បាញ់មិញ អំពីអង្គជំនុំជម្រះសម្រេចលើឯកសារមួយដែលមិនឲ្យលោកដេញដោលចំពោះសាក្សីរូបនេះ ដោយសារមូលហេតុលោកលើកយកឯកសារនោះមកដេញដោល វាមិនត្រឹមត្រូវតាមនីតិវិធីដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក។ ហើយលោកបានបង្ហាញហើយអំមិញថា លោកយល់ច្បាស់អំពីការពន្យល់របស់ចៅក្រមហ្សង់ម៉ាក ឡាវែន៍ ដែលជាចៅក្រមប្រឹក្សានៃអង្គជំនុំជម្រះ។

ឥឡូវសូមលោកបង្ហាញជាមុនសិន មុននឹងដាក់ អនុញ្ញាតឲ្យ អង្គជំនុំជម្រះសម្រេចថាអនុញ្ញាតឬមិនអនុញ្ញាតឲ្យដាក់បញ្ចាំងនៅលើអេក្រង់ទូរទស្សន៍ ក៏ដូចជាដាក់បង្ហាញសាក្សី។

[១៥:១៤:០០]

**លោក ម៉ៃខល ផេសមិន៖**

គឺថាវាហាក់ដូចថា ឯកសារ វាជាការមិនត្រឹមត្រូវដែលថាឯកសារនេះមិនបានដាក់នៅក្នុងសំណុំរឿង ព្រោះថាឯកសារនេះត្រូវបានប្រើប្រាស់ជាច្រើនដងដោយសហព្រះរាជអាជ្ញា ហើយឯកសារនេះគឺឯកសារដែលមានលេខ D91/15 ហើយជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត បើដូច្នេះឲ្យតែជាក់ច្បាស់។ មន្ត្រីរដ្ឋបាលតុលាការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងយកឯកសារក្រដាសទៅជូនសាក្សីពិនិត្យ ហើយចង្អុលបង្ហាញនូវចំណុចដែលពាក់ព័ន្ធនឹងគោលបំណងនៃការសួរដេញដោល ដោយមេធាវីរូបនេះផង។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១៥:១៥:០៨]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី ខ្ញុំសន្មតថាលោកធ្លាប់ឃើញឯកសារនេះ ព្រោះថាលោកបាននិយាយពីឯកសារនេះមក តើលោកមែនដែរឬទេ? តើលោកធ្លាប់ឃើញដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំអត់ឃើញឯកសារនេះទាល់តែសោះ។

**ស៖** គឺឯកសារនេះបង្ហាញលោកនៅថ្ងៃទី១២-- ១១ ខែធ្នូ ឆ្នាំ២០០៧ ហើយវាភ្ជាប់ជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ហើយមេ-- ហើយអ្នកស៊ើបអង្កេតបានសរសេរមតិយោបល់

របស់លោកនៅផ្នែកខាងឆ្វេង គឺមានកំណត់សម្គាល់របស់លោកចំនួនប្រាំបួន ដែលនៅខាងឆ្វេងនៃតារាងទាំងអស់នេះ។ តើលោកប្រាកដទេថា លោកមិនដែលឃើញឯកសារនេះ?

[១៥:១៦:៤០]

**ឆ៖** អ្ហែ! ខ្ញុំដូចជាមិនធ្លាប់បានឃើញទេលោក ហើយឃើញស៊ីញ៉េឈ្មោះខ្ញុំហ្នឹងដូចជា ខ្ញុំមិនធ្លាប់ស៊ីញ៉េលើឯកសារនេះទាល់តែសោះនេះ។ មានគូសអីក្រវេមក្រវាម មានអក្សរអង់គ្លេសខ្វែងខ្វាត់អីពេញតែហ្នឹងបាទ។ អត់។

**ស៖** ខ្ញុំគិតថា ខ្ញុំបន្តទៅទៀត ខ្ញុំមិនបន្តទៀតទេ ប៉ុន្តែដើម្បីជាកំណត់ត្រា គឺសាក្សីហ្នឹងត្រូវបានបង្ហាញឯកសារ-- ត្រូវបានគេបង្ហាញឯកសារហ្នឹងនៅថ្ងៃ១១ ធ្នូ ២០០៧ គឺឯកសារដែលមានលេខ E33/459 ហើយខ្ញុំមិនចាំអំពីលេខERNទេ។ ឥឡូវខ្ញុំសូមបន្តទៅមុខទៀត គឺឯកសារ E3/91។ លោកសាក្សីៗ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើឯកសារនេះ ថាតើលោកអាចប្រាប់ខ្ញុំបានទេ ថាតើមានបង្ហាញអំពីឈ្មោះលោក គាត ឈន់ នៅក្នុងតារាងនេះដែរឬទេ? ហើយថាតើនៅកន្លែងណាអាចបង្ហាញបានទេ?

[១៥:១៨:៣៥]

**ឆ៖** ខ្ញុំមិនអាចបង្ហាញបានទេ ពិតមែនតែមានឈ្មោះខ្ញុំស៊ីញ៉េ ក៏ប៉ុន្តែឯកសារដែលឲ្យខ្ញុំផ្ទាល់ដៃនោះ ខ្ញុំគ្មានឯកសារហ្នឹងទាល់តែសោះ។ ឲ្យខ្ញុំឆ្លើយយ៉ាងម៉េច។

**ស៖** លោកសាក្សីលោកបានចុះហត្ថលេខាទៅលើឯកសារនេះ តើមូលហេតុអ្វីដែលទើបលោកនិយាយដូច្នេះ? ហើយនៅក្នុងនេះ គឺនិយាយអំពី គាត ឈន់ នៅតារាងទី៣ នៅខាងស្តាំ ហើយគឺនៅជួរទីបី នៅតារាងខាងស្តាំ លោកអាចមើលឃើញនៅលើអេក្រង់កុំព្យូទ័រ ហើយគឺថាចង់ថា តើគាត់នៅកន្លែងហ្នឹង គឺត្រឹមត្រូវដែរទេ? ដាក់ឈ្មោះនៅក្នុងប្រអប់ហ្នឹងត្រឹមត្រូវដែរឬទេ ដែលថាគាត់ជាប្រធាននាយកដ្ឋាននេះ?

**ឆ៖** ខ្ញុំសូមជម្រាបម្តងទៀត ឯកសារនេះ រូបភាពឯកសារដែលខ្ញុំមើលនេះ ខ្ញុំមិនបានទទួលនូវដៃទុកខ្លួនឯងទេ។ ដូច្នេះ ខ្ញុំមិនដឹងថា ឯកសារនេះបានមកពីណាទេ ឃើញតែឈ្មោះស៊ីញ៉េខ្ញុំ ប៉ុន្តែរូបភាពខ្ញុំគ្មានទទួលបានឯកសារនេះទេ ហើយខ្ញុំមិនអាចឆ្លើយបានថា ការនេះជាការពិត ខ្ញុំនិយាយនេះ គឺថាខ្ញុំមិនបានទទួលឯកសារហ្នឹងទេបាទ។

[១៥:២០:១៩]

**ស៖** ខ្ញុំសូមបន្តទៅទៀត។ ខ្ញុំមានសំណួរបន្តទៀតទាក់ទងទៅនឹងសំណួរមួយដែរ គឺនិយាយអំពីលោក ហោ ណាំហុង។ ខ្ញុំមានការភ្ញាក់ផ្អើលដែលបង្ហាញពីរដងនៅក្នុងឯកសារនេះ នៅអេក្រង់គឺលោកអាចមើលឃើញឈ្មោះគាត់ គឺនៅខាងក្រោមបំផុតផ្នែកខាងស្តាំ ថាជាទូតប្រចាំប្រទេសគុយបា ហើយបន្ទាប់មកទៀត គឺជានៅផ្នែកកណ្តាលខាងស្តាំដែលថាគាត់ទទួលខុសត្រូវនៅក្នុងផ្នែក ប-៣២ តើលោកអាចពន្យល់បានដែរឬទេ អំពីអង្គហេតុទាំងអស់នេះ? ថាហេតុអ្វីបានជាគាត់មានឈ្មោះដល់ទៅពីរដងបង្ហាញដល់ទៅពីរដងនៅក្នុងតារាងនេះ?

[១៥:២១:១៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ ពាក់ព័ន្ធនឹងរឿងការបង្ហាញឯកសារនេះ តើយើងគួរតែពិនិត្យជាដំបូង ថាតើសាក្សីរូបនេះបានធ្លាប់ឃើញឯកសារនេះហើយមុននឹងយើងសួរទៅដល់ខ្លឹមសារនៃឯកសារនេះ ឬយ៉ាងដូចម្តេចលោកប្រធាន? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ យើង គាត់បានសួរហើយ ហើយសាក្សីបានឆ្លើយបដិសេធថាខ្លួនមិនធ្លាប់ឃើញទេ ប៉ុន្តែនៅក្នុងកំណត់ហេតុនៃការសួរដេញដោលនេះ ឃើញថា-- នែ៎!កំណត់ហេតុឯកសារនេះ គឺមានឈ្មោះគាត់ ហើយនិងហត្ថលេខារបស់គាត់ រួមជាមួយនឹងអ្នកបកប្រែ ហើយនិងអ្នកស៊ើបអង្កេតនៅក្នុងកិច្ចដំណើរការនីតិវិធីនៃការស្តាប់សក្ខីកម្មរបស់គាត់នៅក្នុងដំណាក់កាលស៊ើបសួរ។ អ៊ីចឹងហើយបានយើងចាត់ទុកថា ឯកសារនេះគឺអាចគ្រាន់តែសួរពាក់ព័ន្ធនឹងបង្ហាញទូទៅបាន ដូចឯកសារដែលគាត់មិនធ្លាប់ឃើញ។

[១៥:២២:៣១]

បញ្ហានេះកើតឡើងម្តងរួចមកហើយ អំពីការដេញដោលលើកមុន គឺស្រដៀងគ្នាដែរ។ បានន័យថា ឯកសារដែលធ្លាប់មានការចុះហត្ថលេខាអីអ៊ីចឹង ប៉ុន្តែគាត់មិនទទួលស្គាល់ ក៏យើងដាក់ឲ្យគាត់អាចដេញដោលបាននៅលើខ្លឹមសារទូទៅ។

សូមអញ្ជើញតំណាសហព្រះរាជអាជ្ញាអន្តរជាតិ! យ៉ាងម៉េចទៅ?

[១៥:២៣:០០]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ សំណួរចុងក្រោយនេះ គឺប្រហែលជាមិនស្រពិចស្រពិល ពីព្រោះថាវាជាអង្គការលេខដែលផ្តល់ ឬក៏ដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយបានសួរឈ្មោះថាម៉េចក៏បានជាឈ្មោះបុគ្គលនេះមាននៅពីរកន្លែង? ហើយខ្ញុំយល់ថា សំណួរនេះ ហាក់ដូចជាសំណួរនេះសំដៅថាចាត់ទុកថាសាក្សីនេះ ដូចជាអ្នកធ្វើអង្គការលេខនេះអ៊ីចឹង ជាការសន្និដ្ឋានរបស់អ្នកចោទសំណួរនេះ។ អ៊ីចឹងខ្ញុំថាសូមឲ្យជៀសវាងបញ្ហាបែបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាការត្រឹមត្រូវណាស់ ការបញ្ជាក់ឃើញថាអាចមានការភ័ន្តច្រឡំលើការតាំងសំណួរដោយដ្យាក្រាមដែលគូរនេះ គឺមិនមែនជាដ្យាក្រាមដែលគូរដោយសាក្សីទេ ហើយភាសានេះក៏មិនមែនជាភាសាសាក្សីដែលប្រើប្រាស់ដែរ។ មិនមែនជាភាសាខ្មែរទេ។ ហើយសំណួរដែលនាំឲ្យឆ្លើយ ហើយមានប្រាំបួនចំណុច មានទាំងចំណុចទីប្រាំបីអត់មាន ហើយនិងចំណុចទីប្រាំបួនមិនស្គាល់។ បញ្ហានេះ គឺទំនងជាមិនមានការពាក់ព័ន្ធនឹងស្ថានភាពផ្សេងទៀតដែលគាត់ដឹងទេ ប្រហែលជាទំនងជាគាត់ដឹងតែចំណុចមួយ ចំណុចបី ចំណុចបួន ចំណុចប្រាំ ចំណុចប្រាំមួយ ប្រាំពីរ ហើយចំណុចប្រាំបួនគាត់ឆ្លើយថា គាត់មិនស្គាល់ទេ។

សូមមេធាវីការពារក្តីចាប់អារម្មណ៍លើបញ្ហានេះ ក្នុងការតាំងសំណួរដេញដោលសាក្សីចំពោះឯកសារនេះ។

[១៥:២៥:០៥]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ ហើយខ្ញុំសូមទោស ដែលខ្ញុំមានការច្រឡំទាក់ទងទៅនឹងឯកសារ។ ហើយយើងគិតថា ឯកសារនេះធ្វើឡើងដោយព្រះរាជអាជ្ញា ឬក៏ការិយាល័យព្រះរាជអាជ្ញា ហើយបន្ទាប់មកត្រូវបានប្រើប្រាស់ដោយអ្នកស៊ើបអង្កេត នៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ។ ខ្ញុំប្រាកដហើយថា ឯកសារនេះមិនមែនសាក្សីជាអ្នករៀបចំនោះ ប៉ុន្តែគ្រាន់តែគាត់ជាអ្នកផ្តល់នូវមតិយោបល់មួយចំនួន នៅពេលគាត់-- នៅពេលគេបង្ហាញឯកសារនេះជូនគាត់នៅឆ្នាំ២០០៧។ តើខ្ញុំត្រូវតែនិយាយសំណួរខ្ញុំឡើងវិញសាជាថ្មី ឬមួយក៏យ៉ាងម៉េច?

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកចាំសំណួរដែលខ្ញុំចោទសួរពីមុននេះទេ?

[១៥:២៥:៥៦]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំអត់ចាំទេ ពីព្រោះឯកសារនេះ ខ្ញុំអត់ដែលបានឃើញសរសេរអក្សរដៃ ក៏ខ្ញុំមិនបានឃើញ។ សរសេរអក្សរអង់គ្លេស ក៏ខ្ញុំមិនបានឃើញ។ ខ្ញុំទទួលឯកសារប៉ុន្មាន គឺខ្ញុំចាំបានតែឯកសារនោះទេ ឯកសារក្រៅពីហ្នឹង ខ្ញុំចាំមិនបានទេបាទ។

**ស៖** លោកសាក្សី ប៉ុន្តែលោកអាចពន្យល់បានដែរឬទេ ថាហេតុអ្វីបានជាគេបង្ហាញឈ្មោះលោក ហោ ណាំហុង ពីរដង មានតួនាទីពីរនៅក្នុងឯកសារនេះ?

**ឆ៖** ខ្ញុំមិនយល់ទេ។

**ស៖** ថាតើលោក ហោ ណាំហុង ជាទូតនៅប្រទេសគុយបា មុននឹងគាត់ផ្ទេរតួនាទីទៅមន្ទីរប-១ តើមែនដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ គឺទូតនៅគុយបាមែន។ ប៉ុន្តែនៅប-១ ដូចជា មួយរយៈខ្លីទេបាទ។ នៅបឹងត្របែកដូចជាវែង នៅប-១ ដូចជាខ្លីបាទ។

**ស៖** ចុះ ប-៣២ ថាតើប-៣២ហ្នឹង គឺបឹងត្របែក តើមែនឬទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ឈ្មោះ ប-៣២ ទេលោក។

[១៥:២៨:០១]

**ស៖** ហើយចុះឈ្មោះ ប-៣០ និង ប-៣២ ហ្នឹង លោកដឹងទេ ថាតើមានន័យអ្វី ឬក៏ជាអ្វីដែរ?

**ឆ៖** ខ្ញុំអត់ចាំទេលោក។

**ស៖** លោកបានប្រាប់អ្នកស៊ើបអង្កេតថា គឺបន្ទាប់មកទៀតលោកបានប្រាប់សហចៅក្រមស៊ើបអង្កេត គឺនៅថ្ងៃ០៧ ខែ០៤ ឆ្នាំ២០១០ ហើយលោកបាននិយាយថា ហោ ណាំហុង គឺនៅបឹងត្របែក ថាតើតួនាទីរបស់គាត់ហ្នឹង មានតួនាទីអ្វីដែរនៅទីនោះ?

**ឆ៖** ខ្ញុំដឹងថានៅបឹងត្របែក ប៉ង់ យកទៅដាក់នៅបឹងត្របែក។

**ស៖** ថាតើគាត់ជាប្រធានប-៣២ ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលឮថាគាត់ជាប្រធានទេ។

**ស៖** ហេតុអ្វីបានគេផ្តល់ផ្ទះមួយទៅឲ្យ ហោ ណាំហុង ដើម្បីស្នាក់នៅ? ហើយគាត់-- ហើយផ្ទះហ្នឹងនៅក្បែរវិមានឯករាជ្យ តើហេតុអ្វី?

**ឆ៖** តាមខ្ញុំចាំ សភាពការណ៍ប្រែប្រួល វៀតណាមចូលកៀកមកហើយ។ ហើយដូចជា ប៉ង់បាត់ហើយក៏មិនដឹងទេពេលនោះ។ ដូច្នេះក្រសួងការបរទេស ឲ្យលោក ជាម ហ្នឹងយក១លោកហ្នឹងទៅឲ្យនៅ១វីឡាមួយនៅវិមានឯករាជ្យបាទ។

**ស៖** ថាតើអ្នកដែលគេឃុំខ្លួន ឬក៏គេទុកនៅបឹងត្របែកហ្នឹង តើសុទ្ធតែទទួលបានផ្ទះមួយនៅជិតវិមានឯករាជ្យហ្នឹងទាំងអស់គ្នាម៉េចដែរ? ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ពេលនោះដូចជាបង ហោ ណាំហុង, បង សារិន ឆាក គឺនៅផ្ទះវីឡា។ ឯអ្នកដទៃទៀតនេះគម្រោងរៀបចំឲ្យធ្វើជាខ្លះចូលក្រសួងការបរទេស ខ្លះទៅជាគ្រូបង្រៀនក្មេង១ គឺគម្រោងហ្នឹង គឺពេលនុ៎ងគឺគម្រោងរៀននៅសាលាបច្ចេកទេសស្ទូវៀតសព្វថ្ងៃ។

[១៥:៣១:២៨]

**ស៖** ហេតុអ្វីបានជាលោក ហោ ណាំហុង ទទួលបាននូវការប្រព្រឹត្តដែលល្អប្រសើរបែបនេះ?

**ឆ៖** ខ្ញុំមិនដឹងដែរ។

**ស៖** ថាតើលោកនៅតែទាក់ទងជាមួយគាត់ដែរឬទេ?

**ឆ៖** ដូចខ្ញុំបានជម្រាប លោក ជាម យកទៅទុកទៅ ខ្ញុំអត់មានបានទៅទាក់ទងលោកអីទេលោក ជាម ទេ។ ហើយបន្ទាប់មកគឺខាងផ្នែករណសិរ្ស។

**ស៖** ខ្ញុំនិយាយអំពីបច្ចុប្បន្ននេះ គឺថារយៈពេលក្រោយឆ្នាំ៧៩ រហូតមកដល់បច្ចុប្បន្ននេះ ថាតើលោកនៅ-- ឥឡូវនេះលោកនៅតែមានទំនាក់ទំនងជាមួយគាត់ដែរឬទេ? ថាតើលោកធ្លាប់និយាយជាមួយគាត់ដែរឬទេក្នុងពេលថ្មី១នេះ?

**ឆ៖** សូមបញ្ជាក់ គាត់នេះគឺថា លោក ជាម ឬមួយលោក ហោ ណាំហុង?

**ស៖** ខ្ញុំនិយាយអំពីលោក ហោ ណាំហុង។

**ឆ៖** បាទខ្ញុំមិនដែលទាក់ទងទាល់តែសោះ។

**ស៖** តើលោកនៅធ្វើការទាក់ទងជាមួយនឹងលោក គាត ឈន់ ដែរឬទេ?

[១៥:៣៣:១៦]

**ឆ៖** បាទ ខ្ញុំមិនដែលទាក់ទងទាល់តែសោះ។

**ស៖** តើលោកខ្លាចពួកគាត់ទាំងពីរដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ខ្លាចទេ។

**ស៖** តើលោកដឹងថាលោក ហោ ណាំហុង និងលោក គាត ឈន់ ត្រូវបានចៅក្រមស៊ើបអង្កេតអន្តរជាតិកោះហៅមកផ្តល់សក្ខីកម្មដែរឬទេ? ដោយសារតែចៅក្រមគិតថា សក្ខីកម្មរបស់លោកទាំងពីរនោះគឺមានសារៈសំខាន់អាចលាតត្រដាងការពិត។ តើលោកបានដឹងចំណុចហ្នឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកមិនបាច់ឆ្លើយនឹងសំណួរនេះទេ។

**លោក ម៉ៃខល ផេសមិន៖**

តើលោកប្រធាន ខ្ញុំអាចសុំបញ្ជាក់បំភ្លឺទៅលើចំណុចហ្នឹងបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយនឹងសំណួរនេះទេ ពីព្រោះលោកគ្មានមុខងារអីមកមើលសំណុំរឿងក្នុងការស៊ើបអង្កេតរឿងក្តីទេ។ លោកសាក្សីអាចឆ្លើយពាក់ព័ន្ធទៅនឹងអង្គហេតុដែលកើតមានឡើងពាក់ព័ន្ធនឹងការដឹងបញ្ហាព្រឹត្តិហេតុ ហេតុការណ៍ដែលលោកបានដឹង ជាពិសេសនៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងដីកាចោទប្រកាន់។ ចំពោះនីតិវិធីប្រព្រឹត្តទៅយ៉ាងណានោះ គឺលោកចូលរួមក្នុងនាមជាសាក្សីប៉ុណ្ណោះ។

[១៥:៣៤:៥៨]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន យើងដឹងហើយថា ជំហររបស់ខ្ញុំបញ្ជាក់ថាការជ្រៀតជ្រែកផ្នែកនយោបាយនេះ គឺវាសំខាន់ណាស់ ដែលអនុញ្ញាតឲ្យយើងធ្វើការស៊ើបអង្កេតទៅលើចំណុចនេះ។ ដូច្នេះសាក្សីរូបនេះប្រហែលជាអាចមានព័ត៌មាន ហើយអាចពាក់ព័ន្ធអ្វីដែលខ្ញុំសួរ។

**ប្រធានអង្គជំនុំ៖**

សវនាការនេះមិនមែនសវនាការអំពីការជ្រៀតជ្រែកខាងនយោបាយទេ សវនាការអង្គសេចក្តីដែលសាក្សីរូបនេះបានដឹង បានឮ បានឃើញ បានផ្ទាល់ទៅនឹងអង្គហេតុដែលកើតមានឡើង យើងបានប្រាប់គាត់តាំងពីដំបូងនៃភារកិច្ចរបស់គាត់ក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកដឹងទេ តើហេតុអ្វីបានជាលោក ហោ ណាំហុង និងលោក គាត ឈន់

បដិសេធមិនមកផ្តល់សក្ខីកម្មនៅទីនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយនឹងសំណួរនេះទេ សំណួរនេះក្រៅអង្គហេតុ និងមិនមានការពាក់ព័ន្ធជាមួយនឹងភារកិច្ចសាក្សីឆ្លើយនឹងសំណួរនេះទេ។

[១៥:៣៦:១៩]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សីៗ តើលោកដឹងថាអ្នកទាំងពីរនោះមានការភ័យខ្លាចមិនហ៊ានមកផ្តល់សក្ខីកម្មដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សីថាតើលោកដឹងថាអ្នកទាំងពីរនាក់នោះទទួលការណែនាំពីរដ្ឋាភិបាលមិនឲ្យមកផ្តល់សក្ខីកម្មមកផ្តល់ជាជំនួយដល់តុលាការនេះ ដើម្បីស្វែងរកការពិតដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។

[១៥:៣៧:១០]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** តើនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់អ្នកទាំងពីរមិនឲ្យមកផ្តល់សក្ខីកម្មដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំមើលម៉ោងទៅឃើញម៉ោងនៅសល់តែ២០នាទីទៀត ហើយនៅសល់មេធាវីមួយក្រុមទៀតដែលត្រូវលើកសំណួរចំពោះសាក្សីរូបនេះ។ មិនដឹងថាលោកមេធាវី មេធាវីការពារក្តីលោក នួន ជា អស់សំណួរហើយឬយ៉ាងម៉េច បើមិនដូច្នេះទេ សូមផ្ទេរពេលវេលានេះជូនក្រុមមេធាវីបន្ទាប់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សាក្សីមិនចាំបាច់ឆ្លើយទៅនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្តីលោក នួន ជា ដែលសួរនេះទេ។ បញ្ហាហ្នឹងមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវសួរដេញដោលលោកនាពេលនេះទេ។

[១៥:៣៨:១១]

តើលោកមេធាវី តើលោកត្រូវការពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរ តាមសំណួរដែលលោកសួរនេះ។ តាមអង្គជំនុំជម្រះយល់ ប្រហែលជាអស់សំណួរហើយ គប្បីគិតគូរក្នុងការប្រើប្រាស់ពេលវេលាឱ្យមានប្រសិទ្ធភាពក្នុងការដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ។ លោកទំនងជាត្រូវការពេលវេលាប៉ុន្មានទៀតទៅលោកមេធាវី ម៉ៃខល ផេសមិន?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំនៅសល់សំណួរតែមួយទៀតទេ លោកប្រធាន។ ហើយខ្ញុំដឹងថាចម្លើយប្រាកដជាខ្លី ប្រសិនបើសាក្សីឆ្លើយ។

[១៥:៣៩:០៦]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី យើងដឹងហើយថា លោក គាត ឈន់ និង ហោ ណាំហុង ប្រហែលជាបុគ្គលដែលសំខាន់។ ហើយយើងគិតថា អ្នកទាំងពីរនោះគួរមកផ្តល់ចម្លើយនៅក្នុងតុលាការនេះ។ តើលោកដឹងលោក ហោ ណាំ ហុង និងគាត ឈន់ មានឆន្ទៈមកផ្តល់សក្ខីកម្មក្នុងតុលាការនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ឆ្លើយតបទេ សាក្សីមិនមែនមុខងាររបស់សាក្សីទៅដឹងចិត្តរបស់អ្នកដទៃនោះទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំអធ្យាស្រ័យដែរ ដោយសារតែអត់មានការឆ្លើយពីសាក្សី ហើយដូច្នេះត្រង់ចំណុចនេះ គឺខ្ញុំមិនមានសំណួរបន្ថែមទៀតទេលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៥:៤០:១៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ខ្ញុំមេធាវី គង់ សំអុន ខ្ញុំសូមមានសំណួរមួយចំនួនដើម្បីជម្រាបទៅលោក ហើយលោកសូមជួយឆ្លើយបញ្ជាក់ទៅក្រុមប្រឹក្សាជំនុំជម្រះផង។ ហើយលោកអាចពិនិត្យមើលពេលវេលា ឃើញថាវាកៀកច្រើនដែរហើយ។ ដល់អ៊ីចឹង អ៊ំ លោកឆ្លើយតាមសម្រួលតាមធម្មតាទៅ ហើយអ៊ំ អាចខ្ញុំចង់បានចម្លើយខ្លីៗជាជាងចម្លើយវែង។ បាទ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជាដំបូងខ្ញុំបាទ សូមឲ្យលោកឆ្លើយបញ្ជាក់អំពីតួនាទីរបស់លោកកាលដែលលោកធ្វើជាកងការពាររបស់លោកពូរបស់លោក គឺលោក ប៉ុល ពត នោះ។ ជាពិសេស ខ្ញុំសូមលោកឆ្លើយបញ្ជាក់អំពីពេលវេលាក្នុងរយៈពេលដើមឆ្នាំ១៩៧៥។ តើលោកស្តាប់បានទេ? ពេលវេលាដើមឆ្នាំ១៩៧៥។ សំណួរគឺថា លោកបានបញ្ជាក់ក្នុងពេលសវនាការកន្លងមក នៅពេលដែលសហព្រះរាជអាជ្ញាសួរ លោកបានបញ្ជាក់ថា “លោក ប៉ុល ពត មានកងការពារផ្សេងទៀតក្រៅពីលោក ហើយនិងមានចុងភៅម្នាក់ផង-- អ្នកដាំបាយ (សូមអ្នកទោស) អ្នកដាំបាយម្នាក់ផង ហើយនិងមានកងការពារពីរនាក់”។

[១៥:៤១:៥៤]

តើលោកចាំឈ្មោះ ឬក៏អត្តសញ្ញាណរបស់អ្នកទាំងនោះបានទេថា កងការពារ ឬក៏អ្នកដាំបាយនោះមានឈ្មោះអ្វីដែរ?

**លោក សាឡុត បាន៖**

**ឆ៖** ចិត ឆ្នាំ៧៥ ដើមឆ្នាំ៧៥បន្តិចមានការរៀបចំកន្លែង។ ខ្ញុំយល់ឃើញថា នៅកន្លែងនោះមានអ្នកដាំបាយហ្នឹង គឺមានគ្រួសារខ្ញុំមួយ មានគ្រួសារបង នួន ជា នេះមួយ។ កងការពារនេះមានលោក លឺន មានឈ្មោះលោក លឺន ហើយនិងលោក តាន១ ក្រោមបញ្ជារបស់ ប៉ង់។

**ស៖** បាទ សូមអរគុណ។ តើលោកអាចចាំបានថា មានកងការពារផ្សេងទៀតក្រៅពី លឺន និង តាន នេះទេបាទ?

[១៥:៤៣:១០]

**ឆ៖** មានបីប្អូននាក់ដែរ ប៉ុន្តែគេស្លាប់អស់ទៅ ស្លាប់អស់ទៅហើយ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបាទសូមសួរលោកទាក់ទងទៅនឹងទីបញ្ជាការ ដែល ប៉ុល ពត ធ្វើការនៅមុនវ៉ៃចូលភ្នំពេញបែកឆ្នាំ១៩៧៥។ ខ្ញុំបានស្តាប់ឮលោកបានផ្តល់សក្ខីកម្មជូនក្រុមប្រឹក្សាជំនុំជម្រះថាទីបញ្ជានោះបានផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយជាច្រើន ហើយដែលលោករហូតដល់ឲ្យឈ្មោះថា "កន្លែងចល័ត" ទៅទៀត។ ប៉ុន្តែ ឥឡូវខ្ញុំចង់សួរបញ្ជាក់ឲ្យច្បាស់ពីរយៈពេលនៃការតាំងនៅទីបញ្ជានីមួយៗហ្នឹង ថាមុនចូល-- មុនវ៉ៃកាន់កាប់ទីក្រុងភ្នំពេញ ដែលយើង-- ដែលលោកប្រើពាក្យថារំដោះភ្នំពេញបានហ្នឹង តើមានការផ្លាស់ប្តូរទីតាំងប៉ុន្មានដងដែរ?

**ឆ៖** ដូចជាពីរ ឬបីដងតែប៉ុណ្ណោះបាទ។

[១៥:៤៤:៥២]

**ស៖** ពីរ ឬបីដងអ៊ីចឹងបាទ។ ចុះទីតាំងចុងក្រោយ លោកចាំបានទេថា វាប្រើពេលដែលនៅធ្វើការនៅទីតាំងចុងក្រោយហ្នឹងរយៈពេលប្រហែលប៉ុន្មានដែរ? ឬក៏លោកអាចបញ្ជាក់ថា ចាប់ពីពេលណាមកដល់ពេលណា? រហូតមកដល់ឆ្នាំ១៩៧៥ ពេលរំដោះ១៧ មេសា នេះបាទ។

**ឆ៖** លោកសួរទីតាំងចុងក្រោយលោក?

**ស៖** បាទៗ ទីតាំងចុងក្រោយ!

**ឆ៖** បាទ ទីតាំងចុងក្រោយហ្នឹងប្រហែលជាឆ្នាំ៧០-- អ្ហឺ!៧២, ៧៣, ៧៤ បាទ។

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញ គឺទីតាំងចុងក្រោយ គឺចាប់ផ្តើមប្រើប្រាស់ពីឆ្នាំ១៩៧២, ៧៣, ៧៤ អ៊ីចឹងមែនទេបាទ?

**ឆ៖** បាទ ច្បាស់ជាងគេ គឺ៧៣, ៧៤ ហ្នឹងហើយច្បាស់ជាងគេបាទ។

[១៥:៤៦:១០]

**ស៖** ចុះក្នុងរយៈពេលប៉ុន្មានខែចុងក្រោយ នៃដើមឆ្នាំ១៩៧៥ តើស្ថិតនៅក្នុងទីតាំងចុងក្រោយហ្នឹងដែរទេ?

**ឆ៖** ចំពោះខ្ញុំ?

**ស៖** បាទ។

**ឆ៖** បាទ ខ្ញុំនៅរហូត ដល់៧៥ហើយក៏ខ្ញុំនៅដែរបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចផ្តល់ការពន្យល់បានទេថា ហេតុអ្វីបានជាមានការ

សម្រេចយកទីតាំងចុងក្រោយនេះជាមូលដ្ឋាន?

**ឆ៖** គោលការណ៍ គឺឲ្យវាស្រោល ហើយស្ងាត់ ហើយជិតបញ្ជាការភ្នំពេញបាទ។

[១៥:៤៧:៣៦]

**ស៖** តើមានមូលហេតុផ្នែកយោធាអីផ្សេងទៀតទេ ដែលចាំបាច់សម្រាប់ឲ្យជ្រើសរើសទីតាំងជាទីបញ្ជាការហ្នឹងថាត្រូវការស្ថានភាពបែបម៉េច?

**ឆ៖** មួយទៀត គឺដូចជា នៅត្រង់នុំង! ដូចជាកណ្ដាល ដូចជាកណ្ដាលគេអ៊ីចឹងទៅ កម្មាភិបាលអីចង់ហៅអីមកអ៊ីចឹងទៅ វាជិតបាទ ជិតស្រួល។

**ស៖** បាទ នៅក្នុងសវនាការកន្លងមក លោកបានបញ្ជាក់ថាទីតាំងដែលជ្រើសរើសធ្វើជាទីបញ្ជាការហ្នឹង គឺតែងតែធ្វើឡើងនៅក្នុងព្រៃ គឺមិនមែនស្ថិតនៅក្នុងភូមិទេ។ អ៊ីចឹងការកំណត់ថាស្ថិតនៅក្នុងភូមិនេះ ឬក៏ភូមិនោះ ជាទូទៅមិនត្រឹមត្រូវទេ។ លោកអាចពន្យល់បានទេថា ហេតុអីបានត្រូវជ្រើសរើសនៅក្នុងព្រៃដូច្នេះ?

**ឆ៖** គឺរក្សាការសម្ងាត់បានល្អ។

[១៥:៤៨:៥៨]

**ស៖** រក្សាការសម្ងាត់យ៉ាងម៉េចទៅលោក?

**ឆ៖** ខ្ញុំសូមអត្ថាធិប្បាយ។ បោះទីតាំងនៅហ្នឹង មិនមែនថាបងប្អូនប្រជាជនអត់ដឹងទេ មេភូមិមេអីណ៎ា គេជួយការពារ។ គេប្រាប់កូនភូមិរបស់គេណ៎ា ថា "កុំចូលណ៎ា ត្រង់ហ្នឹងណ៎ា ចូលអត់បានទេណ៎ា"។ បាទ ចូលមិនបានទេ អត់បានទេ។ គេមិនប្រាប់អីថា អង្គការអីនៅហ្នឹងទេ តែមេភូមិប្រាប់ថាកុំឲ្យចូល គឺអត់ចូលតែម្ដង។ ហ្នឹងអ៊ីចឹង។ ដូច្នេះបញ្ហានេះហើយដែលហៅថា "គោលការណ៍រក្សាការសម្ងាត់" ហ្នឹងបាទ។ ហើយបុគ្គលិកនៅក្នុងហ្នឹង អត់មានចេញអីរហេតរហូតបានទេ ខ្ញុំអីនេះ ទាល់តែមាននរណាទិញដូរ គឺថាចាត់តាំងតែម្នាក់ទេទៅ ទាក់ទងបាទ ហើយចេញចូលហ្នឹងគឺថាវាងពីនេះពីនោះ។ ជួនកាលហ្នឹងលុបដានជើងចេញទៀតណ៎។ នេះសូមជម្រាបលោកអ៊ីចឹងបាទ។

[១៥:៥០:១៩]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីស្ថានភាព នៅកន្លែងដែលលោកហៅថាជាទីតាំង ទីបញ្ជាការនោះបានទេបាទ?

**ឆ៖** ស្ថានភាពទីតាំងបញ្ជាការនុំង គឺជាខ្ទមៗ បើមានភ្ញៀវអីអ៊ីចឹងទៅ ដូចជា បង នួន ជា,

បងហែម, បង អៀង សារី អីអញ្ជើញអីទៅ ខ្ទម ធ្វើខ្ទមតូចៗៗមួយប្រលោះសម្រាន្តបានហ្នឹង តែគ្រ ហ្នឹងតូចៗទេ ហើយគ្មានជញ្ជាំងគ្មានអីទាំងអស់ បាទចំហ គឺយកឈើហ្នឹងជាជញ្ជាំងតែម្តងបាទ រុក្ខជាតិ ហ្នឹងជាជញ្ជាំងតែម្តងបាទ។

[១៥:៥១:២២]

**ស៖** លោកអាចជម្រាបក្រុមប្រឹក្សាជំនុំជម្រះផងបានទេថា ខ្ទមដែលធ្វើនៅកន្លែងនោះមានចំនួន ប្រហែលប៉ុន្មានដែរ?

**ឆ៖** ប្រាំ ទាំងផ្ទះបាយបាទ។

**ស៖** ចុះស្ថានភាពនៅខាងក្រៅអគារនោះវិញ ឧទាហរណ៍ទាក់ទងទៅនឹងព្រៃ ឬក៏ដើមឈើអី ផ្សេងៗ តើវាជាវាលស្រឡះ ឬក៏ព្រៃស្តុកបាទ?

**ឆ៖** បាទ គេហៅថា ព្រៃរបោះ មិនធំទេ នៅផ្នែកយើងកំពង់ស្ពឺ កំពង់ឆ្នាំងនេះបាទ ព្រៃរបោះ បាទ។

**ស៖** បើសិនជា យើងឈរសម្លឹងមើលនៅក្នុងខ្ទមនោះ ឬក្នុងបរិវេណនោះ តើយើងអាចមើល ឃើញទៅក្រៅទេ ឬមួយក៏មើលទៅមើលមិនធ្លុះ?

**ឆ៖** យើងមើលឃើញបាទ។

**ស៖** មើលឃើញច្បាស់យ៉ាងម៉េចដែរលោក?

**ឆ៖** យើងមើលឃើញច្បាស់ ដូចថា យើងមើល-- ពិបាកទាល់ទៅដល់កន្លែងតែម្តងទៅបាន វាស្រួល អានេះដូចថា យើងមើលទៅវាអាចច្បាស់ចន្លោះខ្លះទៅ វាបាន៣០ម៉ែត្រ ៥០ម៉ែត្រអីអ៊ីចឹងបាន បាទ។

[១៥:៥៣:០២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឲ្យលោកបញ្ជាក់សាឡើងវិញ អំពីស្ថានភាពរបស់ខ្ទម ដែល លោកអម្បាញ់មិញនេះ មានប្រសាសន៍ថា ពុំមានជញ្ជាំងទេ តើលោកអាចរៀបរាប់ពីស្ថានភាពហ្នឹង សាឡើងវិញឲ្យច្បាស់ជាងហ្នឹងបន្តិចទៀតបានទេ ថាតើគេប្រើអ្វីជាជញ្ជាំង ឬមួយក៏គ្មានជញ្ជាំងទាល់តែ សោះ ឬមួយមានតែសសរយ៉ាងម៉េចបាទ? សូមអញ្ជើញ។

**ឆ៖** បាទ មានសសរ មានដំបូល នែដំបូលប្រក់នែស្លឹកត្នោត ហើយបើមានភ្លៀងម្តងៗ គេមាន កៅស៊ូគេមួយផ្ទាំងៗម្នាក់នេះទៅគេបាំង បាទ។

**ស៖** បាទ សូមអរគុណ។ លោកមានប្រសាសន៍អំមិញថា ខ្ទមប្រក់ អាដំបូលប្រក់ស្លឹកត្នោត តើស្ថានភាពខ្ទមនោះ បើយើងនិយាយអំពីសសររបស់វាហ្នឹង គេធ្វើពីអ្វីដែរ គេធ្វើពីឈើ ឬពីថ្មយ៉ាងម៉េច?

[១៥:៥៤:៤០]

**ឆ៖** គឺឈើតូចៗប៉ុនកដៃប៉ុនកជើង ហើយឫស្សីធ្វើជាដំបូលមិនមានឈើរធំមិនមែនជាស៊ីម៉ងត៍អីទេ ឥដ្ឋអីទេលោក។

**ស៖** បាទសូមអរគុណ។ លោកដឹងថាខ្ទមទាំងអស់នោះគេប្រើប្រាស់សម្រាប់ធ្វើអ្វីខ្លះទេ?

**ឆ៖** គឺនិយាយខ្ទមដែលនៅ-- ខ្ញុំនៅចុងបំផុតហ្នឹង?

**ស៖** បាទ សូមអរគុណ។ សូមលោករៀបរាប់អំពីការប្រើប្រាស់ខ្ទមទាំងអស់ ដែលមាននៅក្នុងបរិវេណទីបញ្ជាការនោះបាទ។

**ឆ៖** គឺខ្ទមនោះសម្រាប់កម្មាភិបាលសម្រាកម្នាក់ពីរនាក់ អត់មានច្រើននាក់ទេបាទ។ ភ្ញៀវដែលមកជួនកាលច្រើននាក់ចងអង្រឹង។ ហើយខ្ទមមួយទៀត គឺកន្លែងដាំបាយបាទ។ ហើយខ្ទមតូចៗដទៃទៀតហ្នឹងចល័ត គឺសម្រាប់ទុកគ្រាប់បន្តិចៗអីចឹងទៅ ដើម្បីបើវាទម្លាក់គ្រាប់បែកអីមកវាខូចអី ខូចតែមួយកន្លែងទៅបានហើយ កុំឲ្យវាខូចទាំងអស់បាទ ចល័តទាំងអស់ គ្រាប់អីៗហ្នឹងបាទ។

[១៥:៥៦:៥០]

**ស៖** បាទសូមអរគុណ។ លោកអាចជម្រាបក្រុមប្រឹក្សាជំនុំជម្រះបានទេថា ខ្ទមដែលធំជាងគេបំផុតនោះមានទំហំប៉ុនណា ហើយដែលតូចជាងគេបំផុតនោះមានទំហំប៉ុនណា?

**ឆ៖** ទៅមិន-- ខ្ទមធំបំផុតមិនហួសពី១០ម៉ែត្របួនជ្រុងទេលោក។ ខ្ទមតូចបំផុតហ្នឹងគឺថា ម៉ាចូលសម្រាកបាន។

**ស៖** បាទ សូមអរគុណ។ ចុះខ្ទមហ្នឹងសង់ឆ្ងាយពីគ្នាប្រហែលប៉ុន្មានម៉ែត្រដែរ?

**ឆ៖** ខ្ទមយុទ្ធជននោះឆ្ងាយពីខ្ទមអ្នកដឹកនាំប្រហែលជា៣០ ទៅ៤០ ម៉ែត្របាទ។ នៅក្រោមដើមឈើណាដែលមាន គេហៅថាមាន គេហៅថាដើមឈើស្គុកណ៉ា ស្គុកៗគឺគេឲ្យតែមានចន្លោះស្គុកហើយគេទៅស៊កខ្ទមនៅនុំងហើយបាទ។

**លោក គង់ សំអុន៖**

បាទសូមអរគុណ។ លោកប្រធានខ្ញុំចប់អាចំណុចនេះ ចង់ចូលចំណុចថ្មីប៉ុន្តែអាចចំណាយពេលលើសនេះ។

E1/70.1

**ប្រធានអង្គជំនុំ៖**

លោកត្រូវការពេលវេលាប្រហែលប៉ុន្មានទៅ?

[១៥:៥៨:៣៤]

**លោក គង់ សំអុន៖**

បាទខ្ញុំជម្រាបជូនខាងដើមថា យើងត្រូវការពេលវេលាមួយម៉ោងកន្លះ ឥឡូវយើងបានប្រើ២០ នាទី។ អ៊ីចេះអាចត្រូវពេលមួយម៉ោងទៀត ប្រហែល។

**ប្រធានអង្គជំនុំ៖**

បាទលោកត្រូវការពេលវេលាគប្បីប្រើតាំងសំណួរហ្នឹង ឲ្យមានប្រសិទ្ធភាពដើម្បីឲ្យចូលជ្រៅទៅលើអង្គហេតុដែលសក្តានុពល ឬក៏ភស្តុតាងសក្តានុពល ដែលលោកមានបំណងតាំងសំណួរទៅ វានឹងអាចបង្រួញពេលវេលា ហើយអ៊ីចេះទេ ដោយសារសាក្សីគាត់មកច្រើនហើយ ជិតពីរសប្តាហ៍ហើយ។ អ៊ីចឹងហើយ ថ្ងៃស្អែកនេះជាថ្ងៃបុណ្យទៀត។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះគិតថា ប្រសិនបើអាចដំណើរការបានហ្នឹង អង្គជំនុំជម្រះនឹងពន្យារពេលរហូតដល់ម៉ោងបួនសាមសិបនាទីនៅថ្ងៃនេះសម្រាប់ឲ្យលោកដេញដោលឲ្យចប់ ប្រសិនបើអាចធ្វើទៅបាន។

[១៥:៥៩:៣៤]

តើធ្វើបានទេ លើពេលវេលាឲ្យពន្យារពេលប៉ុណ្ណឹង?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ គម្រោងរបស់យើងមានបួនចំណុចធំៗ ហើយឥឡូវយើងចប់បានពីរចំណុច អ៊ីចឹងនៅសល់បួនចំណុចទៀត។ អ៊ីចឹងខ្លាចធ្វើកន្លះម៉ោងមិនចប់បាទ។ ហើយម្យ៉ាងទៀតយើងបានទទួលលិខិតពីខាងប្រឹក្សាច្បាប់របស់តុលាការ អង្គជំនុំជម្រះហ្នឹង បានបញ្ជាក់ថាអាចចំណាយពេលនៅថ្ងៃពុធនោះបាន។ ដូច្នេះ យើងគិតថាយកពេលទៅដាក់ទៅថ្ងៃពុធបន្ថែម។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ បាទ ឥឡូវនេះកិច្ចដំណើរការសវនាការឃើញថា មិនចប់ទេ ហើយកិច្ចប្រឹងប្រែងរបស់យើងដើម្បីមានបំណងថា ឲ្យបានចប់នៅក្នុងថ្ងៃនេះ ឃើញថាមិនបានចប់ទេ។ ហើយសូមជម្រាបសាក្សី ហើយសូមសាក្សីអត់ធ្មត់ ហើយនិងខិតខំប្រឹងប្រែងគឺទំនងជានៅសល់មួយម៉ោងដប់នាទីទៀតទេ សាក្សីនឹងផ្តល់សក្ខីកម្មចប់ហើយ។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកសាក្សីមកម្តង

ទៀតនៅថ្ងៃពុធ នៅព្រឹកថ្ងៃពុធ ប្រហែលជាពី ចាប់ផ្ដើមពេលព្រឹករហូតដល់សម្រាក ពេលសម្រាកលើកទីមួយពេលព្រឹកហ្នឹងទំនងជាចប់ហើយ។ ហើយដូចគ្នា សូមអញ្ជើញមេធាវីប្រឹក្សាសាក្សីសូមអញ្ជើញមកជាមួយសាក្សី ដើម្បីបន្តអង្គុយអមសាក្សីក្នុងការផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃពុធ។

[១៦:០១:១៥]

បាទ អង្គជំនុំជម្រះ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះឃើញថា សមល្មមដល់ពេលវេលាសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការត្រូវលើកទៅថ្ងៃពុធ ទី០២ ខែឧសភា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី/អ្នកជំនាញ ដើម្បីផ្ដល់មធ្យោបាយទៅមកសម្រាប់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់ឲ្យមកកន្លែង-- កាន់កន្លែងផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃពុធ ឲ្យបានត្រឹមម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ឲ្យមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃពុធ ទី០២ ខែឧសភា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*